ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
BUDDHIST INSTITUTE

# ប្រស្នាពុទ្ធប្បវត្តិ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

I.S.R.C K.I.D JULY 1990

២០៥.
០៨

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org


www.budinst.gov.kh www.elibraryofcambodia.org

ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

1990年09月

ACKNOWLEDGEMENT

This book is specially printed as a co-operative project of the Japanese Committee of the World Conference on Religion and Peace and Sotoshu Volunteer's Association.

We pray that this book would contribute to the friendship with Cambodian people and their cultural preservation.

SEPTEMBER , 1990

សៀវភៅដែលលោកអ្នកកំពុងកាន់នេះ បោះពុម្ពដោយសហប្រតិការរវាង សមាគម-W.C.R.P. និង S.V.A. ជប៉ុន ។

ខ្ញុំសង្ឃឹមជាយ៉ាងខ្លាំងអស់ពីចិត្តថា សៀវភៅនេះនាំមកនូវមិត្តភាពរវាងប្រជាជន-ខ្មែរ-ជប៉ុន ហើយនិងរក្សាវប្បធម៌ខ្មែរ ឲ្យបានគង់វង្សតទៅ ។

កញ្ញា ១៩៩០

www.budinst.gov.kh www.elibraryofcambodia.org

២០៥.១៨

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត
បណ្ណាល័យ
BUDDHIST INSTITUTE
០៨/៨៥

# ប្រស្នាពុទ្ធប្រវត្តិ

## ពាក្យប្រារព្ធ

១-សំនួរៈ ពុទ្ធប្រវត្តិ គឺអ្វី?

ចម្លើយៈ គឺជារឿងរ៉ាវដែលពោលអំពីការប្រព្រឹត្តិរបស់ព្រះសម្មាសម្ពុទ្ធ ។

២.ស.ការរៀនពុទ្ធប្រវត្តិមានប្រយោជន៍ដូចម្តេច?

ច.មានប្រយោជន៍ជាសំខាន់ក្នុងការប្រតិបត្តិព្រះពុទ្ធសាសនា ព្រោះពុទ្ធប្រវត្តិចង្អុលបំភ្លឺពុទ្ធចរិយាឲ្យឃើញជាក់ស្តែង ដូចគ្នានឹងប្រវត្តិរបស់ជាតិនីមួយ ៗ អាចចង្អុលឲ្យឃើញថាមានដើមកំណើតមកដូចម្តេច ៗ ខ្លះ ។ ព្រះសម្ពុទ្ធជាតំរូល្អយ៉ាងវិសេស ទ្រង់មានឧបាយនិងមានរបៀបចាត់ការក្នុងករណីយកិច្ចដែលជាប្រយោជន៍ដល់ព្រះអង្គឯង ទាំងជាប្រយោជន៍ដល់សត្វដទៃ; ជនណាបានរៀនពុទ្ធប្រវត្តិចប់ហើយ ជននោះតែងបានដឹងនូវពុទ្ធចរិយាថា ព្រះអង្គមានអាការៈយ៉ាងណាៗខ្លះ, នេះទុកដូចជាបានឃើញតំរូយ៉ាងល្អ ដែលជាហេតុឲ្យជីវិតរបស់ខ្លួនឲ្យមានប្រយោជន៍ ទាំងប្រព្រឹត្តឲ្យត្រឹមត្រូវតាមគន្លងសមបាន; ឯប្រយោជន៍នោះបើយ៉ាង

www.budinst.gov.kh www.elibraryofcambodia.org

ហោចណាស់ ក៏គង់ទាញយកបែបយ៉ាងរបស់ព្រះអង្គមក ប្រើក្នុងកិច្ចការខាងផ្លូវលោកនេះបានខ្លះៗ ដូចយើងដែលខំព្យាយាមខំអត់ធន់យកតម្រាប់តាមព្រះអង្គជាដើម ។ មួយទៀត អ្នករៀនពុទ្ធប្រវត្តិកាលបានចេះដឹងរឿងរ៉ាវរបស់ព្រះអង្គច្បាស់លាស់ហើយ រមែងស្គាល់គុណអាចាររបស់ព្រះអង្គរឹតតែខ្លាំងឡើង ជាហេតុបណ្ដុះបសាទសទ្ធាក្នុងព្រះអង្គឲ្យខ្លាំងក្លា ឧបមាដូចយើងនឹករឭកដល់បុព្វបុរស ដែលបានធ្វើផលប្រយោជន៍ទុកក្នុងត្រកូលរបស់យើងៗ នឹករឭកឃើញគុណនៃលោកនោះ ជាហេតុឲ្យយើងយកតម្រាប់តាមលំអានរបស់លោក ។

៣.សំ. ក្នុងពុទ្ធប្រវត្តិ លោកចែងកាលជាប៉ុន្មាន? គឺអ្វីខ្លះ? រាប់ពីត្រឹមណា ទៅដល់ត្រឹមណាហៅថាកាលអ្វី?

ឆ.- លោកចែកជា៣គឺ: បឋមពោធិកាល១, មជ្ឈិមពោធិកាល១ បច្ឆិមពោធិកាល១ ។ ក) រាប់ពីត្រឹមឆ្នាំដែលព្រះអង្គបានត្រាស់ មក-ដល់ឆ្នាំទី ១៥ ហៅថា បឋមពោធិកាល; ខ) រាប់ពីត្រឹមឆ្នាំទី ១៦ ដល់ឆ្នាំទី៣០ ហៅថា មជ្ឈិមពោធិកាល; គ) រាប់ពីត្រឹមឆ្នាំទី ៣១ ដល់ឆ្នាំទី ៤៥ ហៅថា បច្ឆិមពោធិកាល ។

៤.សំ. ពុទ្ធប្រវត្តិ ជាប់ទាក់ទងនឹងការប្រតិបត្តិ ក្នុងព្រះធម្មវិន័យ ដូចម្ដេចទៅ បានជាលោកយកមករួបរួម ទុកក្នុងចំណែកមួយនៃការសិក្សា?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ពុទ្ធប្បវត្តិជាឫសគល់នៃការប្រតិបត្តិ, ជាគ្រឿងនៃសេចក្ដីប្រព្រឹត្តិក្នុងផ្លូវព្រះពុទ្ធសាសនា, ជាឧបាយនាំឲ្យកើតសទ្ធាជ្រះថ្លាក្នុងព្រះរតនត្រ័យ ឲ្យដុះមិត្តដុះគំនិត ចង់ប្រតិបត្តិព្រះវិន័យដោយខ្លួនឯង មិនចាំបាច់មានអ្នកណាបង្ខិតបង្ខំឡើយ ។

៥ សំ. សេចក្ដីក្នុងពុទ្ធប្បវត្តិ បើរួបរួមឲ្យខ្លីមកមានប៉ុន្មានផ្លូវ? គឺអ្វីខ្លះ?

ឆ. មានពីរផ្លូវគឺផ្លូវ១ ជាប់ទាក់ទងដោយរឿងរ៉ាវ, ផ្លូវ១ជាប់ទាក់ទងដោយអភិនិហារ, ផ្លូវមួយទៀតជាប់ទាក់ទងដោយការប្រតិបត្តិធម៌ ។

៦ សំ. បណ្ដាផ្លូវទាំង៣នេះ តើផ្លូវណាអាចសម្រេចផលដល់អ្នកសិក្សាដូចម្ដេច?

ឆ. ផ្លូវដែលទាក់ទងដោយរឿងរ៉ាវ . អាចសម្រេចផលដល់អ្នករៀនឲ្យច្បាស់របស់ព្រះពុទ្ធ; ផ្លូវដែលទាក់ទងដោយអភិនិហារ អាចសម្រេចផលដល់អ្នករៀនឲ្យកើតសេចក្ដីស្ងើចអស្ចារ្យក្នុងពុទ្ធានុភាព ទាំងឲ្យកើតសទ្ធាជ្រះថ្លាចូលចិត្តក្នុងការប្រតិបត្តិធម៌; ផ្លូវដែលជាប់ទាក់ទងដោយការប្រតិបត្តិធម៌ អាចសម្រេចផលដល់អ្នករៀនឲ្យដឹងសេចក្ដីប្រព្រឹត្តិ និងហេតុផលតាមពិតដ៏ល្អិតសុខុម ។

៧ សំ. ពុទ្ធភូមិមានប៉ុន្មាន? គឺអ្វីខ្លះ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. មាន៣ គឺ បញ្ញាធិក ១, សទ្ធាធិក១, វីរិយាធិក ១ ។

៨. ស. ព្រះបរមសាស្តានៃយើងទ្រង់កសាងជាពុទ្ធភូមិអ្វី? កំណត់កាលប៉ុន្មានអសង្ខេយ្យ ទើបបានត្រាស់ជាព្រះពុទ្ធ?

ឆ. ព្រះអង្គកសាងជាបញ្ញាធិកៈ ។ កំណត់កាល ៤ អសង្ខេយ្យនឹង ១ សែនកប្ប ទើបបានត្រាស់ជាព្រះពុទ្ធ ។

៩ ស. ក្នុង ៤ អសង្ខេយ្យនឹង ១ សែនកប្បនោះ តើព្រះសាស្តានៃយើងបានព្យាករណ៍ (បានទំនាយ) ក្នុងសំណាក់នៃព្រះពុទ្ធប៉ុន្មានព្រះអង្គ? ចូររាប់ព្រះនាមព្រះពុទ្ធទាំងនោះមកមើល!

ឆ. ក្នុងសំណាក់នៃព្រះពុទ្ធ ២៤ ព្រះអង្គ គឺព្រះពុទ្ធទីបង្ករ១, កោណ្ឌញ្ញៈ ១, សុមង្គលៈ ១, សុមនៈ ១, រេវតៈ ១, សោភិតៈ ១, អនោមទស្សី១, បទុមៈ ១, នារទៈ ១, បទុមុត្តរៈ ១, សុមេធៈ ១, សុជាតៈ ១, បិយទស្សី១, អត្ថទស្សី១, ធម្មទស្សី ១, សិទ្ធត្ថៈ ១, តិស្សៈ១, ផុស្សៈ ១, វិបស្សី១ សិខី១, វេស្សភូ១, កកុសន្ធៈ១, កោនាគមនៈ ១, កស្សបៈ ១ ។

១០. ស. ក្នុងសម័យព្រះពុទ្ធទីបង្ករទី១នោះ តើព្រះសាស្តានៃយើងសោយព្រះជាតិជាអ្វី? កសាងបារមីដូចម្តេច?

ឆ. ព្រះអង្គសោយព្រះជាតិជាព្រាហ្មណ៍ មាននាមថា សុមេធ ។ ព្រះសុមេធព្រាហ្មណ៍នេះ លះសម្បត្តិចេញបួសជាឫសីបាន

www.budinst.gov.kh www.elibraryofcambodia.org

សម្រេចឈាន និងអភិញ្ញា ។ ថ្ងៃមួយ ព្រះតាបសបានធ្វើផ្លូវថ្វាយ ព្រះពុទ្ធទីបង្ករ ប៉ុន្តែធ្វើពុំទាន់រួចស្រេច ស្រាប់តែព្រះពុទ្ធ ស្តេចមកដល់ ព្រះតាបសក៏ប្រះខ្លួនទ្រាលទៅលើភក់និមន្តព្រះសាស្តានិងភិក្ខុសង្ឃ ឲ្យយាងសួរលើខ្លួនឆ្លងភក់នោះទៅ ។ ព្រះពុទ្ធទីបង្ករទ្រង់ត្រាស់ព្យាករណ៍ថា តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធ នាមថាគោតម ក្នុងអនាគត ។

១១- សំ. ក្នុងសម័យនៃព្រះពុទ្ធកស្សបៈជាគំរប់២៤ ព្រះអង្គនោះ តើព្រះសាស្តានៃយើងសោយព្រះជាតិជាអ្វី? បានកសាងបារមីដូចម្តេច?

ឆ. ព្រះអង្គសោយព្រះជាតិជា ជោតិបាលមាណព ។ ជោតិបាលមាណពនេះចេញបួសក្នុងព្រះពុទ្ធសាសនា បានស្តាប់ព្រះពុទ្ធព្យាករណ៍ហើយ ក៏មានចិត្តជ្រះថ្លាឧស្សាហ៍បំពេញបារមីធម៌ទាំង៣០ប្រការ និងមហាបរិច្ចាគ ៥ ឲ្យបរិបូណ៌ គ្រប់ជាតិដែលព្រះអង្គកើត តាមសំដាប់មកទៀត ។

១២- សំ. បារមីទាំង៣០ប្រការនោះគឺអ្វីខ្លះ? ក្នុងបារមីមួយៗ លោកចែកជាប៉ុន្មាន? ឲ្យឈ្មោះដូចម្តេច? បើមិនហៅថាបារមីទេ និងហៅថាជាអ្វីបានទៀត?

ឆ. ទាន១, សីល១, នេក្ខម្ម១, បញ្ញា១, វីរិយ១, ខន្តិ១, សច្ច១, អធិដ្ឋាន១, មេត្តា១, ឧបេក្ខា១ ។ ក្នុងបារមីមួយៗ លោកចែកចេញជាបីៗ

www.budinst.gov.kh www.elibraryofcambodia.org

ដូចគ្នា ៗ ឲ្យឈ្មោះថា ទានបារមី១, ទានឧបបារមី១, ទានបរមត្ថបារមី១ (តាំងពីសីលដល់ឧបេក្ខាក៏ចែកជាបី ៗ ដូចទានដែរ រួមគ្នាត្រូវជាបារមី-៣០ ប្រការ) ៗ បារមី ៣០ ប្រការនេះនឹងហៅថា ពុទ្ធការកធម៌ក៏បាន ៗ

១៣-ស. មហាបរិច្ចាគ ៥ ប្រការ គឺអ្វីខ្លះ ?

ប. គឺអង្គបរិច្ចាគ (លះបង់អវយវៈណាមួយជាទាន)១, ធន-បរិច្ចាគ (លះបង់ទ្រព្យសម្បត្តិឲ្យជាទាន)១, បុត្តបរិច្ចាគ (លះបង់កូនឲ្យជាទាន)១, ទារបរិច្ចាគ (លះបង់ប្រពន្ធឲ្យជាទាន)១, ជីវិតបរិច្ចាគ (លះបង់ជីវិតឲ្យជាទាន)១ ៗ

១៤-ស. ព្រះសាស្តានៃយើងកាលព្រះអង្គចុតិពីអត្តភាពជាព្រះវេស្សន្តរហើយ តើព្រះអង្គបានទៅកើតនៅទីណា? មានព្រះនាមជាអ្វី ? កំណត់ព្រះជន្មប៉ុន្មានឆ្នាំ ?

ប. ព្រះអង្គទៅកើតនៅស្ថានតុសិតសួគ៌ ៗ មានព្រះនាមថា សន្តុសិតទេវបុត្រ ៗ កំណត់ព្រះជន្ម ៤ ពាន់ឆ្នាំទិព្វ ត្រូវជា ៥៧ កោដិនឹង ៦០ សែនឆ្នាំមនុស្ស ៗ

## ជម្ពូទ្វីបនិងប្រជាជន

១៥ ស. ជម្ពូទ្វីបនៅឯណា? នៅទិសណាប្រទេសយើង? មនុស្សជាតិអ្វីបានចាប់ផ្ដើមតាំងមក ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ជម្ពូទ្វីបគឺផែនដីដែលយើងហៅសព្វថ្ងៃនេះថា ឥណ្ឌាៗ នៅខាងទិសពាយ័ព្យនៃប្រទេសកម្ពុជាយើង ។ មនុស្សជាតិអរិយកៈចាប់ផ្ដើមតាំងជាទីលំនៅមកក្នុងប្រទេសនោះ; ឯមនុស្សពួកអរិយកៈនេះមិនមែនជាម្ចាស់នៃប្រទេសឥណ្ឌានេះទេ បាននាំគ្នាលើកចុះមកអំពីផែនដីខាងជើងនគ្គហិមាល័យ ដោយពិធីកេកនខ្ទ្រានដេញពួកមិលក្ខៈជាម្ចាស់ស្រុកឲ្យថយចុះមកទិសខាងត្បូងបន្តិចម្ដងៗ, ហើយជនជាតិអរិយកៈឯង បានចូលទៅតាំងលំនៅក្នុងជម្ពូទ្វីបគឺប្រទេសឥណ្ឌានោះ ។ ពួកមនុស្សអរិយកៈនោះ ជាអ្នកចំរើនដោយសេចក្ដីចេះដឹងនឹងទំនៀមទំលាប់ ហើយមានឫទ្ធិអំណាចជាងពួកមិលក្ខៈដែលជាម្ចាស់ស្រុកដើម ទើបអាចចាត់ការតាំងស្រុកទេសនិងការគ្រប់គ្រងបានល្អជាង ។

១៦– សំ. ជម្ពូទ្វីបនោះចែកជាប៉ុន្មានភាគ ? ហៅថាអ្វី ?

ឆ. ចែកជា ២ ភាគ ។ គឺ រួមខេត្រខាងក្នុង ហៅថា មជ្ឈិមជនបទ ប្រែថា "ប្រទេសកណ្ដាល", រួមខេត្រខាងក្រៅ ហៅថា បច្ចន្តជនបទ ប្រែថា "ប្រទេសចុងដែន" ។

១៧– សំ. ក្នុងសម័យពុទ្ធកាល គេចែកព្រំដែននៃមជ្ឈិមជនបទនិងបច្ចន្តជនបទផ្សេងគ្នាដូចម្ដេច ? មានគោលកំណត់ក្នុងរឿងអ្វី ?

ឆ. លោកចែកផ្សេងគ្នាដូចមានគោលកំណត់ក្នុងត្រង់បាលីចមកនតក្នុងគម្ពីរមហាវគ្គនៃវិនយបិដកដូច្នេះ ៖

www.budinst.gov.kh www.elibraryofcambodia.org

ក) ទិសបូព៌ា ខាងក្នុង រាប់អំពីមហាសាលនគរចូលមក ។

ខ) ទិសអាគ្នេយ៍ ខាងក្នុង រាប់អំពីស្ទឹងសល្លវតីចូលមក ។

គ) ទិសទក្សិណ ខាងក្នុង រាប់អំពីស្ទឹងសេតកណ្ណិកនិគមចូលមក ។

ឃ) ទិសបស្ចិម " " ថូនគ្រាមចូលមក ។

ង) ទិសឧត្តរ " " ភ្នំឧសិរធជៈចូលមក ។

ទីក្នុងខាងក្នុងនៃគោលកំណត់នេះ ហៅថា មជ្ឈិមជនបទ, ទីខាងក្រៅអំពីគោលកំណត់នេះចេញទៅ ហៅថា បច្ចន្តជនបទ ។

១៨- សំ. អាណាចក្រក្នុងជម្ពូទ្វីប សម័យពុទ្ធកាលដែលមានឈ្មោះប្រាកដ តើអ្វីខ្លះ? មានវិធីគ្រប់គ្រងដូចម្តេច?

ឆ្ល. ជម្ពូទ្វីបនោះចែកចេញជាច្រើនអាណាចក្រ ដែលមានឈ្មោះប្រាកដក្នុងសម័យពុទ្ធកាល តាមដែលលោកបានសំដែងទុកក្នុងបាលីឧបោសថសូត្រក្នុងតិកនិបាតអង្គុត្តរនិកាយថា ចាត់ជាមហាជនបទ ១៦ គឺអង្គៈ, មគធៈ, កាសី, កោសល, វជ្ជី, មល្លៈ, ចេតី, វង្សៈ, កុរុ, បញ្ចាលៈ, មច្ឆៈ, សុរសេនៈ, អស្សកៈ, អវន្តី, គន្ធារៈ, កម្ពោជៈ ។ តែមានសំដែងទុកក្នុងព្រះសូត្រដទៃដែលមិនស្ទួននឹងឈ្មោះខាងដើមនេះ គឺសក្កៈ, កោលិយៈ, ភគ្គៈ, វិទេហៈ, អង្គុត្តរាបៈ រួម ៥ ជនបទនេះទៀត ត្រូវជា ២១ ជនបទ ។ អាណាចក្រសម្បូរណ៍នេះ មានស្តេចម្ចាស់ផែនដីទ្រង់

www.budinst.gov.kh www.elibraryofcambodia.org

៥ យសជាព្រះមហាក្សត្រខ្លះ, ជាព្រះរាជាខ្លះ, ជាគហបតីខ្លះ, ជាអ្នកគ្រប់គ្រងដោយការប្រើសិទ្ធានុភាពដាច់ខាតចំពោះខ្លួនខ្លះ, ដោយសាមគ្គីធម៌ខ្លះ, មានកាលតាំងជាឥស្សរភាពតាមកំឡាំងខ្លួន, មានកាលធ្លាក់ទៅជាអាណានិគមនៃប្រទេសដទៃតាមសម័យដែលមានអានុភាពនិងជយានុភាព ។

១៩ – សំ. ពីបុរាណកាលគេចែកមនុស្សក្នុងជម្ពូទ្វីបជាប៉ុន្មានប្រភេទ? គឺអ្វីខ្លះ? ហើយប្រភេទណា មានមុខការយ៉ាងណា?

ចំ. គេចែកជា ៤ ប្រភេទដែលហៅថា វណ្ណៈ៤ គឺៈ ខត្តិយៈ១, ព្រាហ្មណៈ១, វេស្សៈ១, សុទ្ទៈ១ ។ ខត្តិយៈ= ពួកក្សត្រ មានមុខការខាងផ្លូវគ្រប់គ្រងប្រទេស ត្រូវរៀនសូត្រវិជ្ជាខាងយុទ្ធវិធី; ព្រាហ្មណៈ= ពួកព្រាហ្មណ៍មានមុខការខាងផ្លូវបង្ហាត់បង្រៀនព្រមទាំងធ្វើពិធីផ្សេង ៗ ត្រូវសិក្សាខាងផ្លូវសាសនានិងវិជ្ជាផ្សេងៗ; វេស្សៈ=ពួកវេស្សៈ មានមុខការធ្វើស្រែចំការនិងការលក់ដូរ ត្រូវសិក្សាវិជ្ជាសិល្បកម្ម និងកសិកម្ម ពាណិជ្ជកម្ម; សុទ្ទៈ = ពួកសូទ្រៈ មានមុខការខាងផ្លូវស៊ីឈ្នួលធ្វើការងារគេ ត្រូវសិក្សាក្នុងការងារដែលនឹងធ្វើដោយកម្លាំងកាយ ។ ឯក្សត្រនិងព្រាហ្មណ៍ រាប់ជាជាតិខ្ពង់ខ្ពស់, វេស្សៈ និងសូទ្រៈ រាប់ជាជាតិថោកទាប ។

២០ សំ. មនុស្សក្នុងជាន់នោះយល់ឃើញនូវសេចក្ដីកើត-ស្លាប់និងសុខទុក្ខដូចម្ដេច? ហើយប្រញាទ្រឹមគមានប៉ុន្មាន?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. មនុស្សក្នុងជាន់នោះ សង្ខាតក្នុងវិជ្ជាធម៌ណាស់ បានជាកើត មានពួកអ្នកមេទិដ្ឋិច្រើន, គេយល់ឃើញនូវសេចក្ដីស្លាប់កើតសុខទុក្ខផ្សេងៗគ្នា ។ ប៉ុន្តែបើបំប្រួញសេចក្ដីយល់ឃើញទាំងអស់នោះឲ្យខ្លីមកនៅត្រឹម ២ យ៉ាង គឺ ពួកប្រកាន់ថាស្លាប់ហើយកើតទៀត១, ពួកប្រកាន់ថាស្លាប់ហើយសូន្យ១ ។

ក្នុងពួកដែលប្រកាន់ថាស្លាប់ហើយកើតទៀតនោះ ពួកខ្លះយល់ឃើញថាស្លាប់កើតជាអ្វី ក៏គង់នៅជាយ៉ាងនោះដដែល មិនប្រែប្រួលជាអ្វីទៀតទេ, ពួកខ្លះយល់ឃើញថាកើតហើយច្យុតប្រែប្រួលទៅជាអ្វីៗទៀតបាន ។ ក្នុងពួកដែលប្រកាន់ថាស្លាប់ហើយសូន្យដោយចំណែក ១, ពួកខ្លះយល់ឃើញថាបណ្ដាមនុស្សនឹងបានសុខឬទុក្ខក៏បានឯង សុខទុក្ខនោះឥតហេតុបច្ច័យទេ ។

២១_សួ. ចូរពន្យល់ឲ្យឃើញច្បាស់ថា ព្រោះហេតុអ្វីបានជាក្នុងបុរាណកាលមានពួកគណាចារ្យប្រៀនប្រដៅលទ្ធិផ្សេងៗ ច្រើនគ្នាម៉្លេះ ?

ឆ. ព្រោះមនុស្សក្នុងយុគនោះចូលចិត្តស្វែងរកធម៌ណាស់ ។ មានពួកមុនីលះបង់ទ្រព្យសម្បត្តិក្នុងឃរាវាសចេញបួសជាច្រើន ប្រគល់ជីវិតរបស់ខ្លួនទៅក្នុងការប្រៀនប្រដៅមនុស្សទាំងឡាយ ធ្វើជាគណាចារ្យតាំងទីលំនៅផ្សេងៗគ្នាតាមលទ្ធិ មានបរិវារធ្វើតាមពាក្យបង្គាប់ឲ្យបានផល

www.budinst.gov.kh www.elibraryofcambodia.org

ទីបំផុតនៃលទ្ធិនោះៗ ។ កេរ្តិ៍ឈ្មោះរបស់សាស្តាជាមេលទ្ធិល្បីខ្ទរខ្ទាយទៅមហាជនទាំងពួងមានម្ចាស់ផែនដីជាដើមតែងតែស្រឡាញ់រាប់អានលើកដំកើងយ៉ាងខ្ពង់ខ្ពស់ ព្រោះហេតុនេះបានជាពួកគណាចារ្យប្រាថ្នាចង់បានកេរ្តិ៍ឈ្មោះណាស់ ប្រកាសលទ្ធិរបស់ខ្លួនថាត្រឹមត្រូវជាមានខ្លឹមសារ, ឯលទ្ធិរបស់គណាចារ្យដទៃខុសឥតខ្លឹមសារ ។ ព្រោះហេតុនេះ បានជាមានគណាចារ្យប្រៀនប្រដៅលទ្ធិផ្សេង ៗ គ្នាជាច្រើនរូប ។

## សក្កជនបទ

២២– សំ. សក្កជនបទនោះតាំងនៅក្នុងទីណា ? ហេតុអ្វីបានឈ្មោះជាសក្កជនបទ ?

ឆ្លើ. សក្កជនបទនោះតាំងនៅក្នុងជម្ពូទ្វីប ប៉ែកខាងជើងជិតព្រៃហិមពាន្ត ។ បានជាឈ្មោះថា សក្កជនបទដូច្នោះ ព្រោះមុនដំបូងគេចាប់ផ្តើមកសាងឡើងក្នុងដងនៃព្រៃសក្កៈ ។

២៣– សំ. សក្កជនបទជាប្រទេសធំឬតូច ? មានអ្វីជាគោលល្មមយកមកអាងឲ្យឃើញផង ?

ឆ្លើ. សក្កជនបទជាប្រទេសតូច ។ មានបាលីក្នុងឧបោសថ-សូត្រក្នុងតិកនិបាតអង្គុត្តរនិកាយជាគោលតាង គឺថាសក្កជនបទមិនមានប្រាកដក្នុងមហាជនបទទាំង ១៦ នោះទេ (ចូរមើលត្រង់ប្រស្នាទី ១៨) ។

www.budinst.gov.kh www.elibraryofcambodia.org

២៤ - សំ. ព្រះវង្សនៃព្រះសាស្តារបស់យើងហៅថាអ្វី ? តាំងនៅក្នុងទីណា ? មានមូលហេតុកើតមកដូចម្តេច? ចូររៀបរាប់ដោយសង្ខេបឲ្យល្មមតែស្តាប់បានមកមើល !.

បា. ហៅថា សាក្យៈ ។ តាំងនៅក្នុងសក្កជនបទ នាជម្ពូទ្វីបប៉ែកខាងជើងនៃដែនប្រទេសហិមពាន្ត ។ មានរឿងរ៉ាវដំណាលដោយសង្ខេបថា: ដោយសេចក្តីកាំងក្តាំរបស់ព្រះបាទ ឱក្កាករាជ ។ ដែលព្រះរាជទានព្រះពរដល់ព្រះមហេសីថ្មីឲ្យព្រះនាងរើសយករបស់តាមប្រាថ្នា, ព្រះនាងក៏ទូលសូមរាជសម្បត្តិឲ្យព្រះរាជឱរសរបស់ព្រះនាង ។ ដើម្បីនឹងគ្រងព្រះរាជសម្បត្តិ: ព្រះបាទឱក្កាករាជត្រូវតែបង្គាប់ឲ្យព្រះរាជឱរស ៤ ព្រះអង្គនឹងរាជធីតា ៥ ព្រះអង្គដែលប្រសូតអំពីព្រះមហេសីចាស់ នាំគ្នាលើកចតុរង្គសេនាចេញចាកព្រះនគរ ទៅកសាងព្រះនគរក្នុងដងព្រៃសក្កៈ ប្រទេសហិមពាន្ត បានជាជនបទនោះមានឈ្មោះថា សក្កជនបទ ។ ឯពួកក្សត្រសាក្យៈនោះ គួរតែមានឈ្មោះតាមជនបទ ប៉ុន្តែក្នុងអដ្ឋកថាប្រាប់ថា បានជាឈ្មោះសាក្យៈដូច្នោះ ព្រោះជាអ្នកអាចតាំងស្រុកទេស នឹងតាំងវង្សតាមកម្លាំងខ្លួនបាន ទាល់តែព្រះបាទឱក្កាករាជជាព្រះរាជបិតាលាន់ព្រះឱស្ឋសរសើរថាជាអ្នកអាច ។

២៥ - សំ. ក្នុងសក្កជនបទមាននគរប៉ុន្មាន ? ឈ្មោះអ្វីខ្លះ ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. មាននគរ ៣ ។ គឺនគរដើមរបស់ព្រះបាទឧក្កាកករាជ១, នគរកបិលពស្តុ ១, នគរទេវទហៈ១ ។

២៦– ស. ហេតុអ្វីបានជាឲ្យឈ្មោះថា នគរកបិលពស្តុ ?

ឆ. ហេតុតែព្រះរាជបុត្រាបុត្រីទៅកសាងនគរថ្មី នៅត្រង់ទីលំនៅនៃកបិលតាបស បានជាសន្មតឈ្មោះនគរដែលកសាងថ្មីនោះថា កបិលពស្តុឲ្យត្រូវនឹងនាមនៃតាបស ។

## សាក្យវង្សនិងកោលិយវង្ស

២៧– ស. ចូររៀបរាប់អំពីដើមកំណើតនៃសាក្យវង្សឲ្យឃើញថាមានលំដាប់តគ្នាមកដូចម្តេច ?

ឆ. លំដាប់នៃសាក្យវង្សមានដូច្នេះ កាលចាប់ដើមអំពីព្រះរាជបុត្រា ៤ ព្រះអង្គ និងព្រះរាជបុត្រី ៤ ព្រះអង្គជាបងប្អូនផ្សំផ្គុំគ្នាឯង ជាលំដាប់មកដល់ព្រះបាទជយសេន ។ នោះ មានព្រះរាជបុត្រា ១ អង្គព្រះនាម "សីហហនុ", មានព្រះរាជបុត្រី ១ ព្រះអង្គ ព្រះនាម "យសោធរា" ។ លុះព្រះបាទជយសេនទិវង្គតហើយ ព្រះសីហហនុកុមារបានសោយរាជសម្បត្តិគ្រងព្រះវង្សមក, ទ្រង់មានព្រះមហេសីព្រះនាម "កច្ចានា" ជាព្រះកនិដ្ឋភគិនីរបស់ព្រះបាទអញ្ជនៈជាក្សត្រក្រុងទេវទហៈ ។ ព្រះបាទសីហហនុនេះ មានព្រះរាជបុត្រា ៥ ព្រះអង្គ គឺ សុទ្ធោទនៈ១, សុក្កោទនៈ១,

www.budinst.gov.kh www.elibraryofcambodia.org

អមិតោទនៈ១, ធោតោទនៈ១, ឃនិតោទនៈ១ និងមានព្រះរាជបុត្រី ២ ព្រះអង្គ គឺៈ បមិតា១ អមិតា១ ។ ឯសុទ្ធោទនកុមារបានសោយរាជ្យតព្រះវង្សមក, មានព្រះមហេសីព្រះនាម "មាយា" មានព្រះរាជបុត្រា ១ អង្គ ព្រះនាម "សិទ្ធត្ថ" ។ ខាងក្រោយមក កាលព្រះនាងមាយាទិវង្គតទៅ ទ្រង់មានព្រះមហេសីថ្មី ១ ទៀត ព្រះនាម "បជាបតី" ឬហៅថា "គោតមី", ជួនកាលហៅព្រះនាមភ្ជាប់គ្នាទាំងពីរថា បជាបតីគោតមី ។ កាលទ្រង់បានមហេសីក្រោយនេះមានព្រះរាជបុត្រា ១ អង្គព្រះនាម "នន្ទ", មានព្រះរាជបុត្រី ១ អង្គ ព្រះនាម "រូបនន្ទា" ។ ព្រះសិទ្ធត្ថមានមហេសីព្រះនាម "យសោធរា" (ឬពិម្ពា), មានព្រះរាជបុត្រ ១ អង្គព្រះនាម "រាហុល" ។

២៨-សំ. ចូររៀបរាប់អំពីដើមកំណើតនៃកោលិយវង្ស ឲ្យឃើញថាមានលំដាប់តគ្នាមកដូចម្ដេច ?

ឆ. លំដាប់នៃកោលិយវង្សមានដូច្នេះ: រាប់តាំងដើមអំពីព្រះជេដ្ឋភគិនី ដែលបានរួមរស់សំវាសជាមួយនឹងព្រះបាទទេវទហៈ ជាលំដាប់មករហូតដល់ព្រះបាទអញ្ជនៈ ។ នោះ មានព្រះមហេសីព្រះនាម "យសោធរា", មានព្រះរាជបុត្រា ២ ព្រះអង្គគឺសុប្បពុទ្ធ១, ទណ្ឌបាណិ១; មានព្រះរាជបុត្រី ២ ព្រះអង្គ គឺ មាយា១, បជាបតី (ឬគោតមី)១ ។

២៩-សំ. ហេតុអ្វីបានជាពួកក្សត្រសាក្យវង្សប្រកាន់ខ្លួនខ្លាំងម្ល៉េះ ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ហេតុតែត្រកូលរបស់ពួកសាក្យៈជាត្រកូលខ្ពង់ខ្ពស់ ហើយគេគោរពកោតខ្លាចថាមានជាតិដ៏បរិសុទ្ធ តាំងខាងបិតាតាំងខាងមាតា ដែលហៅថា ឧភតោសុជាត មិនច្របូកច្របល់នឹងជាតិថោកទាបមានជាតិចណ្ឌាលជាដើម ដែលមហាជនមិនគោរពកោតខ្លាច ព្រោះហេតុនេះ បានជាពួកក្សត្រសាក្យៈប្រកាន់ខ្លួនយ៉ាងខ្លាំង ប្រយ័ត្នមិនឲ្យពួកដែលមានជាតិត្រកូលនឹងគោត្រថោកទាបជាងខ្លួនចូលមកច្របូកច្របល់ ដើម្បីរក្សាត្រកូលរបស់ខ្លួនឲ្យបរិសុទ្ធជាទីគោរពកោតខ្លាចរបស់មហាជនតទៅអស់កាលជាអង្វែង ។

៣០-ស. ព្រះសាស្ដានៃយើងកើតក្នុងវង្សអ្វី ? ជាតិអ្វី ? ជាតិនោះមានសេចក្ដីវិសេសដូចម្ដេច ?

ឆ. ព្រះអង្គកើតក្នុងវង្សទាំង ២ គឺក្នុងសាក្យវង្សខាងព្រះបិតា, ក្នុងកោលិយវង្សខាងព្រះមាតា ។ ជាជាតិអរិយកៈ ៗ នេះ ជាអ្នកចំរើនដោយចំណេះវិជ្ជានិងទំនៀមទំលាប់ ស្អាតជំនាញខាងការគ្រប់គ្រងស្រុកទេសព្រមទាំងមានអំណាចច្រើន ។

៣១-ស. ប្រសិនបើ ព្រះសាស្ដានៃយើងមិនកើតក្នុងសាក្យវង្សទេ បែរជាកើតក្នុងត្រកូលថោកទាបជាងនោះទៅវិញ តើនឹងបានផលខុសពីកើតក្នុងសាក្យវង្សដូចម្ដេច ?

ឆ. បើព្រះ អង្គកើតក្នុងត្រកូលថោកទាបជាងសាក្យវង្ស នឹងបានផលខុសគ្នាយ៉ាងនេះ គឺកាលព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធហើយ

www.budinst.gov.kh www.elibraryofcambodia.org

នឹងយាងទៅប្រកាសព្រះសាសនាឲ្យផ្សាយទូលាយ ទៅមិនសូវបានផលប្រយោជន៍ ។ ព្រោះថាមនុស្សដែលមានជាតិត្រកូលខ្ពង់ខ្ពស់ រមែងមានទិដ្ឋិ មានះ ប្រកាន់ជាតិត្រកូលរបស់ខ្លួនថាជាធំ, ក្នុងវេលាដែលព្រះអង្គទ្រង់ទូន្មាន-ប្រៀនប្រដៅ គេក៏មិនជឿស្ដាប់កាន់យកឱវាទទូន្មានរបស់ព្រះអង្គ ព្រោះគេយល់ឃើញថាព្រះអង្គមានជាតិត្រកូលថោកទាបជាងខ្លួនគេ ។ ឧទាហរណ៍ដូចក្នុងសម័យសព្វថ្ងៃនេះសូម្បីមានអ្នកប្រាជ្ញចេះដឹងជ្រៅជ្រះ អាចតែងសៀវភៅ ឬសំដែងធម៌ទូន្មានគេយ៉ាងល្អ យ៉ាងពីរោះក្បោះក្បាយបាន ប៉ុន្តែអ្នកប្រាជ្ញនោះកើតក្នុងត្រកូលថោកទាប ក៏មិនអាចនឹងទូន្មានមនុស្សដែលមានជាតិត្រកូលខ្ពង់ខ្ពស់ឲ្យជឿស្ដាប់ដោយងាយបានទេ ទូន្មានបានតែមនុស្សមានជាតិត្រកូលស្មើនឹងខ្លួន ឬទាបជាងខ្លួន ។ ដូច្នេះក៏ល្មមយល់ឃើញថា មនុស្សដែលមានជាតិត្រកូលខ្ពង់ខ្ពស់ រមែងមិនស្រឡាញ់គោរពរាប់អានអ្នកមានជាតិត្រកូលថោកទាបជាងខ្លួន ។

មួយទៀត មនុស្សដែលមានជាតិត្រកូលថោកទាបជាងព្រះអង្គ ប៉ុន្តែជាអ្នកមានសេចក្ដីគោរពរាប់អានបុគ្គលជាអ្នកមានជាតិត្រកូលខ្ពង់ខ្ពស់ ក៏គង់មានសេចក្ដីជឿស្ដាប់ឱវាទទូន្មានរបស់ព្រះអង្គ តែបន្តិចបន្តួចមិនជាហេតុបណ្ដាលសទ្ធាជ្រះថ្លារបស់មនុស្សបែបនេះឲ្យផុះផុលឡើងបាន ។ ព្រោះហេតុនោះ កាលព្រះអង្គកើតក្នុងជាតិត្រកូលខ្ពង់ខ្ពស់ដែលជាទីនិយមរាប់អានរបស់មនុស្សទាំងឡាយ, សាសនារបស់ព្រះអង្គ ទើបបានចំរើនរីក

www.budinst.gov.kh www.elibraryofcambodia.org

BUDDHIST INSTITUTE LIBRARY

សាយភាយ ជាទីនិយមរាប់អានរបស់ផងទូទៅតាំងសកលជាយូរអង្វែង ។

៣២- សួ. ចូររៀបរាប់តំណវង្សនៃព្រះសាស្ដាឲ្យឃើញថាមានខ្សែស្រឡាយតគ្នាមកដូចម្ដេច ?

ឆ. ព្រះសាស្ដាជាព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនៈនឹងព្រះនាងមាយា; ព្រះបាទសុទ្ធោទនៈជាព្រះរាជឱរសរបស់ព្រះបាទសីហហនុ ។ ជាព្រះរាជឱរសរបស់ព្រះបាទជយសេន; មានរឿងរ៉ាវតំណាលថា ព្រះបាទឱក្កាករាជជាដើមត្រកូលវង្សនៃព្រះសាស្ដា ។

៣៣- សួ. វង្សនៃព្រះសាស្ដាគ្រប់គ្រងនគរណា ?

ឆ. វង្សខាងព្រះបិតា គ្រប់គ្រងនគរកបិលពស្តុ, វង្សខាងព្រះមាតាគ្រប់គ្រងនគរទេវទហៈ ។

## ព្រះសាស្ដាចុះចាប់បដិសន្ធិ

៣៤- សួ. ព្រោះហេតុអ្វីបានជាព្រះសន្តុសិតទេវបុត្រ ច្យុតចាកតុសិតសួគ៌មកចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះមាតា ?

ឆ. ព្រោះទេវតានិងព្រហ្មទាំងឡាយក្នុង ១ ម៉ឺនលោកធាតុនាំគ្នាចូលទៅអញ្ជើញព្រះអង្គឲ្យចុះមកកើតក្នុងមនុស្សលោក ដើម្បីនឹងត្រាស់ដឹងជាព្រះពុទ្ធ ។



www.budinst.gov.kh www.elibraryofcambodia.org

៣៥– សួ. ហេតុអ្វីបានជាទេវតានិងព្រហ្មទាំងនោះដឹងថាព្រះសន្តុសិតទេវបុត្រនឹងបានត្រាស់ជាព្រះពុទ្ធ ?

ឆ. ហេតុតែទេវតានិងព្រហ្មទាំងនោះបានឮពុទ្ធកោលាហល ដែលសុទ្ធាវាសមហាព្រហ្មស្រែកប្រកាសឃោសនាប្រាប់ថា «កន្លងទៅមុខ ១ សែនឆ្នាំទៀត ព្រះសព្វញ្ញុពុទ្ធនឹងកើតឡើងក្នុងលោក» ។

៣៦– សួ. ចុះកោលាហលនោះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ. មាន ៥ យ៉ាង គឺ កប្បកោលាហល ១, ពុទ្ធកោលាហល ១, ចក្កវត្តិកោលាហល ១, មង្គលកោលាហល ១, មោនេយ្យកោលាហល ១ ។

៣៧– សួ. ចូរអធិប្បាយពីកោលាហលទាំង ៥ យ៉ាងនោះមកឲ្យស្តាប់ផងមើល !

ឆ. អធិប្បាយថា នៅវេន ១ សែនឆ្នាំទៅមុខទៀត ភ្លើងនឹងឆេះកប្ប សុទ្ធាវាសមហាព្រហ្មទាំងឡាយបានដឹងហើយ ក៏ចុះមកស្រែកប្រកាសឃោសនា ប្រាប់មនុស្សទូទៅទាំង ១ ម៉ឺនលោកធាតុឲ្យដឹងគ្រប់គ្នា ឲ្យខំធ្វើបុណ្យតាមកុសល នេះហៅថា កប្បកោលាហល ។ នៅ ១ សែនឆ្នាំទៀត ព្រះពុទ្ធនឹងកើតឡើងក្នុងលោក... នេះ ហៅថា ពុទ្ធកោលាហល ។ នៅ ១ សែនឆ្នាំទៀត ស្តេចចក្រពត្តិនឹងកើតឡើងក្នុងលោក... នេះ ហៅថា ចក្កវត្តិកោលាហល ។ នៅ ១ សែនឆ្នាំទៀត

www.budinst.gov.kh www.elibraryofcambodia.org

ព្រះពុទ្ធនឹងទ្រង់សំដែងមង្គល ៣៨ ប្រការ.....នេះហៅថា មង្គលកោលាហល ៗ នៅ ១ សែនឆ្នាំទៀត ព្រះពុទ្ធនឹងទ្រង់សំដែងមោនេយ្យប្បដិបត្តិ នេះហៅថា មោនេយ្យកោលាហល ៗ ក្នុងកោលាហលមួយៗសុទ្ធតែមានសុទ្ធាវាសមហាព្រហ្ម ហោះមកស្រែកប្រកាសឃោសនាប្រាប់មហាជនជួនៗគ្នា ៗ

៣៨ ស.. កាលព្រះសន្តុសិតទេវបុត្រជិតនឹងច្យុតចាកតុសិតសួគ៌នោះ តើមានបុព្វនិមិត្តប៉ុន្មានយ៉ាង កើតឡើងដល់ព្រះអង្គ? គឺអ្វីខ្លះ?

ឆ. មាន ៥ យ៉ាង ៗ គឺ ទិព្វបុប្ផា ដែលប្រដាប់ព្រះកាយស្វិតក្រៀម១, សំពត់ទិព្វដែលទ្រង់នោះមានពណ៌ជាំសៅហ្មង១, ព្រះសេទហូរចេញពីព្រះកច្ឆប្បទេស១, ព្រះសរីរកាយប្រកបដោយអាការចាស់ជរាប្រាកដ ១, មានព្រះទ័យអផ្សុកជាទុក្ខនឿយណាយចាកទេវលោក មិនត្រេកអរនឹងស្ថិតនៅលើអាសនៈជាទិព្វ ១ ៗ

៣៩– ស. កាលព្រះសន្តុសិតទេវបុត្រជិតនឹងច្យុតចាកតុសិតសួគ៌មកកើតក្នុងមនុស្សលោកនោះ តើព្រះអង្គពិចារណាមើលនូវអ្វី? មានប៉ុន្មាន? ហេតុអ្វីបានជាចាំពិចារណាមើលរបស់ទាំងនោះ? ចូរអធិប្បាយមកមើល!

ឆ. ព្រះអង្គពិចារណាមើលនូវមហាវិលោកនៈទាំង៥យ៉ាង គឺ កាល ១, ប្រទេស ១, ទ្វីប ១, ត្រកូល ១, មាតា ១ ៗ អធិប្បាយថា:

www.budinst.gov.kh www.elibraryofcambodia.org

បានជាមហាបុរសពិចារណាមើលនូវកាលនោះ ព្រោះការស្រយ័ហេតុថា ធម្មតាថា បើក្នុងកាលណា សត្វមានអាយុច្រើនជាងមួយសែនឆ្នាំឬថយតិចចុះមកពី ១ រយឆ្នាំ កាលនោះព្រះពុទ្ធមិនដែលចុះមកកើតទេ; កាលអាយុមនុស្សយ៉ាងច្រើនត្រឹម ១ សែនឆ្នាំ ឬយ៉ាងតិចត្រឹម ១ រយឆ្នាំ ទើបព្រះពុទ្ធចុះមកកើតក្នុងលោក ។ ព្រះអង្គរមិលមើលនូវប្រទេសនោះ ដ្បិតថាព្រះពុទ្ធមិនដែលកើតក្នុងបច្ចន្តប្រទេសទេ បុគ្គលទាំងឡាយមានយសច្រើនមានព្រះពុទ្ធជាដើម តែងតែកើតក្នុងមជ្ឈិមប្រទេសប៉ុណ្ណោះ ។ ព្រះអង្គរមិលមើលនូវត្រកូលនោះ ដ្បិតថា ព្រះពុទ្ធមិនដែលកើតក្នុងត្រកូលទាប តែងតែកើតក្នុងត្រកូលពីរ គឺ ខត្តិយត្រកូល១, ព្រាហ្មណត្រកូល១ ។ ព្រះអង្គរមិលមើលនូវមាតានោះ ដ្បិតថា ស្ត្រីដែលជាពុទ្ធមាតា មិនមែនជាស្ត្រី ល្បេះល្បោះ មិនមែនជាអ្នកលេងស្រាជាដើម ឯស្ត្រីជាពុទ្ធមាតានោះជាស្ត្រីមានអភិនីហារកសាងមកអស់ពីគតិកាលមានបារមីធម៌បំពេញគ្រប់ ១ សែនកប្បហើយ ។

៤០–សំ. ព្រះសន្តុសិតទេវបុត្រច្យុតចាកតុសិតសួគ៌ មកចាប់បដិសន្ធិក្នុងផ្ទៃស្រីណា ? ត្រកូលអ្វី ? នៅថ្ងៃ-ខែ-ឆ្នាំអ្វី ? វេលាណា ?

ចំ. ព្រះអង្គចុះចាប់បដិសន្ធិ ក្នុងផ្ទៃនៃព្រះនាងសិរិមហាមាយាក្សត្រិយ៍អគ្គមហេសីនៃព្រះបាទសិរីសុទ្ធោទនមហារាជក្រុងកបិលព័ស្តុ ក្នុងសាក្យត្រកូល, នៅថ្ងៃព្រហស្បតិ៍, ពេញបូណ៌មី ខែអាសាឍ, ឆ្នាំរកា; វេលារាត្រីទៀបភ្លឺ ។

www.budinst.gov.kh www.elibraryofcambodia.org

៤១-សំ. ក្នុងពេលដែលព្រះពោធិសត្វចុះចាប់បដិសន្ធិនោះ ព្រះមាតាទ្រង់សុបិនឃើញដូចម្តេចខ្លះ ?

ឆ. ព្រះមាតាទ្រង់សុបិនថា៖ មហារាជទាំង ៤ មកលើកព្រះនាងទាំងសិរីសយនានាំទៅកាន់ព្រៃហិមពាន្ត ដាក់លើផ្ទាំងសិលាទំហំ ៦០ យោជន៍ ក្រោមដើមរាំងធំ ១ ដើមកំពស់ ១០០យោជន៍ ។ ពួកទេវធីតាមកអញ្ជើញព្រះនាងទៅស្រង់ទឹកក្នុងស្រះអនោតត្ត ។ នៅជិតស្រះនោះមានភ្នំប្រាក់មួយ, មានវិមានមាសមួយ នៅលើភ្នំប្រាក់នោះ ។ ព្រះនាងផ្ទំក្នុងវិមានមាសនោះ បែរព្រះសិរទៅទិសខាងកើត ។ មានភ្នំមាសមួយ នៅជិតភ្នំប្រាក់នោះ ។ មានដំរីសចុះអំពីភ្នំមាសមក ហើយឡើងទៅលើភ្នំប្រាក់ ប្រមោយកាន់ផ្កាឈូកស បន្លឺកោញ្ចនាទចូលមកក្នុងវិមានមាសដើរប្រទក្សិណព្រះនាង ៣ ជុំហើយ ហាក់បីដូចជាចូលទៅក្នុងឧទរព្រះនាងខាងស្តាំ ។ ព្រះបរមពោធិសត្វចុះចាប់បដិសន្ធិក្នុងវេលានោះឯង ។

៤២-សំ. កាលព្រះបរមពោធិសត្វចុះចាប់បដិសន្ធិនោះ មានកើតបុព្វនិមិត្តប៉ុន្មានប្រការ ? គឺអ្វីខ្លះ ? ចូររាប់ឲ្យគ្រប់ដោយសេចក្តីខ្លី ៗ មកមើល ។

ឆ. មានកើតបុព្វនិមិត្ត ៣៦ ប្រការ ។ គឺ ផែនដីកក្រើកញាប់ញ័រ ហើយមានរស្មីភ្លឺពេញលោកធាតុ ១, ក្នុងលោកន្តរមហានរកដែល

www.budinst.gov.kh www.elibraryofcambodia.org

ធ្លាប់តែននឹកជាទិព្វក្រឡប់ក្តី មនុស្សក៏ក្តក្តាក់ថែរទៅជាមើលឃើញ រូបវត្ថុផ្សេង ៗ, មនុស្សត្រចៀកថ្លង់បានឮសូរសម្លេង, មនុស្សគនិយាយបាន, មនុស្សខ្ជីនគមថែរជាលាក្រនិបាន. មនុស្សខ្វិនដើររួច ១, សត្វតាំងឡាយដែលត្រូវគុកច្រវាក់ខ្នោះឃ្នាងថែរជារួចចេញបាន ១, ភ្លើងក្នុងនរក តាំងឡាយមានអវិចនរកជាដើមថែរជារលត់ ១, សេចក្តីស្រេកឃ្លានក្នុងបេតវិស័យក៏រំងាប់ ១, ទ្វារនឹងបង្អួចដែលបិទក៏របើកចេញឯង ១, សំពៅនឹងទូកតាំងឡាយដែលសៀងទៅ ក្នុងទិសផ្សេង ១ ក៏ទៅដល់កំពង់ដែលប្រាថ្នានឹងទៅនោះ ១, ភ័យនៃសត្វតិរច្ឆានតាំងឡាយក៏មិនមានក្នុងខណៈនោះ១, រោគនៃសត្វតាំងឡាយក៏រំងាប់១, សត្វដែលមានពៀរនឹងគ្នាក៏មានមេត្តាចិត្តដល់គ្នា ១, សត្វតាំងឡាយនិយាយសំដីជាទីស្រឡាញ់ដល់គ្នា១, ហ្វូងសេះតាំងឡាយក៏បន្លឺសម្លេងរេគ្គា ១, ហ្វូងដំរីក៏បន្លឺសម្លេងគឹកកង ១, តូរ្យតន្ត្រីតាំងឡាយក៏បន្លឺសូរសម្លេងឡើងឯង ១, គ្រឿងអាភរណៈរបស់មនុស្សតាំងឡាយក៏មានពន្លឺក្តីហើយទន្ទឹមគ្នាបន្លឺសម្លេងប្រាកដ១, ទិសតាំងឡាយក៏ភ្លឺ១, ខ្យល់ព្យុះធំក៏មិនមានបក់ជាំតត១, ខ្យល់បក់តិច ១ ល្មមត្រជាក់ជាសុខដល់សត្វតាំងឡាយ ក៏បង្កើតមានឡើង១, អាកាសមេឃបណ្តាលឲ្យភ្លៀងធ្លាក់ ១, ទឹកចំហាយក៏ធ្លុះផែនដីផុសឡើងមកហូរទៅក្នុងទីតាំងក្នុង ១, ហ្វូងសត្វស្លាបតាំងឡាយលែងហើរទៅក្នុងអាកាសចុះ

www.budinst.gov.kh www.elibraryofcambodia.org

មកដើរក្នុងភូមិភាគ១, ទៀតទឹកក្នុងស្ទឹងមិនបានហូរ នៅនឹងថ្កល់ដូចទឹកក្នុង
ស្រះ១, ទឹកប្រៃក្នុងមហាសមុទ្រទៅប្រែជាផ្អែម១, ផ្កាឈូកមានពណ៌ ៥ ទាំង
អស់ក៏កើតមានដេរដាសទៅក្នុងសមុទ្រស្ទើរនឹងនៅផ្ទៃផែនដី១, ផ្កាដែលកើត
ក្នុងទឹកលើគោកក៏រីកទាំងអស់ ១, ត្រកួលតាវល្លិទាំងឡាយក៏កើតជាផ្កា
ឈូកចេញតាមដើមនឹងមែកនឹងទង ១, ឈូកទាំងឡាយសុទ្ធតែមានដើម
ទំលាយផែនថ្មផុះឡើងមកមួយកន្ទ្រងមានផ្កា ៧ ៗ ត្រួបផ្ទាំងអស់១, ផ្កា-
ឈូកទាំងឡាយក៏កើតប្រាកដសំយុងចុះមកពីលើអាកាស១, រុក្ខជាតិ
ទាំងឡាយ ដែលជាឈើមានផ្កានិងផ្លែ ក៏ផ្កាផ្លែក្នុងខណៈនោះទាំងអស់១,
ភ្លៀងផ្កាទិព្វមានផ្កាមន្ទារពុស្បជាដើម ក៏ធ្លាក់ចុះមកក្នុងទីទាំងពួងដោយ
ជុំវិញ១, តូរ្យតន្ត្រីក៏ធ្វើសម្លេងឡើងឯងក្នុងអាកាស ១, របៀបទន់ដ៏យ
ទិព្វក៏មានប្រាកដពេញទូទៅដូចគ្នាទាំងអស់ ហាក់ដូចលោកធាតុមានពណ៌ នឹង
ពន្លឺក្លិនស្អាប១ ត្រូវជាបុព្វនិមិត្ត ៣២ ប្រការដូច្នេះ ។

២៣ សំ. ព្រាហ្មណ៍ប៉ុន្មាននាក់ ទាយព្រះសុបិននិមិត្តថ្វាយព្រះ
រាជទេវី ? ហើយទាយជាគតិប៉ុន្មានប្រការ ?

ឆ្លើ. ព្រាហ្មណ៍ ៦៤ នាក់ទាយព្រះសុបិននិមិត្តថា ព្រះរាជទេវី
នឹងមានព្រះរាជបុត្រ ១ ដែលមានគតិ ២ ប្រការ គឺ ១- បើនៅជាឃរាវាសនឹង
បានជាស្តេចបរមចក្រពត្តិ; ២- បើចេញទ្រង់ព្រះផ្នួសនឹងបានត្រាស់ជា
អង្គព្រះសម្មាសម្ពុទ្ធ ។

www.budinst.gov.kh www.elibraryofcambodia.org

៤៤- សំ. កាលព្រះពោធិសត្វគង់នៅក្នុងផ្ទៃព្រះមាតានោះ តើមានអ្នកណាមកនៅចាំថែរក្សាព្រះអង្គខ្លះ ?

ច. មានមហារាជទាំង ៤ ក្នុងចក្រវាលនេះ ព្រមទាំងក្នុងចក្រវាលឯទៀត កាន់ព្រះខាន់មកនៅនាំរក្សាព្រះពុទ្ធមាតារហូតដល់គ្រប់ ១០ ខែ ។

៤៥- សំ. ព្រះពោធិសត្វគង់នៅក្នុងផ្ទៃព្រះមាតានោះមានអាការដូចម្ដេច ?

ច. មានអាការដូចនេះ គឺព្រះអង្គគង់ពែនភ្នែនបែរព្រះភក្ត្រទៅខាងផ្ទៃព្រះមាតា បែរព្រះបិដ្ឋទៅខាងព្រះបិដ្ឋមាតា ។ ព្រះមាតាទតឃើញព្រះពោធិសត្វគង់ក្នុងគភ៌, ឯព្រះពោធិសត្វទតព្រះមាតាមិនឃើញទេ ។

## ព្រះសាស្តាប្រសូត

៤៦- សំ. ព្រះពោធិសត្វប្រសូតមុនពុទ្ធសករាជប៉ុន្មានឆ្នាំ ? នៅថ្ងៃ-ខែ-ឆ្នាំអ្វី ? វេលាណា ?

ច. ព្រះអង្គប្រសូតមុនពុទ្ធសករាជ ៨០ ឆ្នាំ, នៅថ្ងៃសុក្រ, ពេញបូណ៌មី ខែពិសាខ, ឆ្នាំច, វេលាជិតថ្ងៃត្រង់ ។

www.budinst.gov.kh www.elibraryofcambodia.org

៤៧– សំ. ព្រះពោធិសត្វប្រសូតនៅកន្លែងណា? ព្រះមាតាមានអាការដូចម្ដេច?

ឆ. ព្រះអង្គប្រសូតនៅព្រៃលុម្ពិនី (ព្រៃសាលព្រឹក្ស) ជាចន្លោះនគរទាំង ២ គឺនគរកបិលពស្តុ និងនគរទេវទហៈ ។ ព្រះមាតាទ្រង់ឈរលើកព្រះហស្តម្ខាងតោងមែកសាលព្រឹក្សហើយប្រសូត មិនមែនដូចប្រសូតដូចស្រីដទៃទេ ។

៤៨– សំ. ហេតុអ្វីបានជាព្រះពោធិសត្វប្រសូតក្នុងព្រៃដូច្នោះ? ចូររកគោលមកអាងឲ្យស្ដាប់បានផងមើល!

ឆ. ហេតុតែព្រះនាងប្រាថ្នានឹងស្ដេចទៅសួរព្រះមាតាបិតានៃព្រះនាងឯទេវទហនគរ, លុះយាងទៅដល់ព្រៃលុម្ពិនី ក៏ស្រាប់តែប្រឈួនព្រះឧទរហើយប្រសូតក្នុងព្រៃនោះឯង ៗ មានគោលជាសំអាងមួយទៀតថា: តាមទំនៀមទំលាប់របស់ព្រាហ្មណ៍តែងប្រកាន់ថា កាលបើកិរិយាមានគភ៌គ្រប់ខែហើយ មិនដែលប្រសូតនៅផ្ទះស្វាមីទេ តែងតែទៅប្រសូតនៅផ្ទះត្រកូលរបស់ខ្លួនវិញ ។

៤៩– សំ. កាលព្រះពោធិសត្វប្រសូតរួចហើយ មានសេចក្ដីអស្ចារ្យដូចម្ដេចខ្លះ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. មានសេចក្ដីអស្ចារ្យផ្សេងៗ គឺមានទឹកក្ដៅ១, ទឹកត្រ-ជាក់១ ហូរធ្លាក់ពីអាកាសមកលាងជម្រះមន្ទិលគភ៌ ។ មានសុទ្ធាវាសមហាព្រហ្ម ៤ អង្គយកបណ្ដាញមាសមកទទួលទ្រព្រះពោធិសត្វ ។ មហារាជទាំង ៤ អង្គទទួលយកពីមហាព្រហ្មទៅទៀត ។ ពួកស្រីស្នំទទួលយកពីមហារាជទៅទៀត ។ ព្រះពោធិសត្វចុះពីដៃស្រីស្នំហើយទ្រង់ឈរលើផែនដីដោយព្រះបាទទាំងពីរ ។ មហាព្រហ្មយកស្វេតច្ឆត្រជាំងថ្វាយ ។ សុយាមទេវរាជយកវាលវិជនីបក់ថ្វាយ ។ ទេវបុត្រ១ អង្គកាន់កែវ ៧ ប្រការ ។ ទេវបុត្រ១ អង្គកាន់សុវណ្ណបាទុកា (ស្បែកជើងមាស) ។ ទេវបុត្រ១ អង្គកាន់គ្រឿងរាជកកុធភ័ណ្ឌ (គ្រឿងសម្រាប់ក្សត្រ) ទាំង ៥ ប្រការគឺ ខគ្គ១, ព្រះខាន់១, ស្វេតច្ឆត្រ១, សុវណ្ណបាទុកា១, វាលវិជនី១ ។ មនុស្សដែលនៅក្នុងទីប្រសូតទាំងអស់គ្នា ក៏បានឃើញសេចក្ដីអស្ចារ្យទាំងនោះជាក់ច្បាស់ ។

៥០-ស. កាលព្រះពោធិសត្វប្រសូតរួចហើយចុះពីដៃស្រីស្នំទៅ ទ្រង់យាងបានប៉ុន្មានជំហាន? មានបន្ទូលថាដូចម្ដេចខ្លះ?

ឆ. ទ្រង់យាងទៅបាន ៧ ជំហានហើយឈប់ឈរនៅនឹង រួចបែរព្រះភក្ត្រទៅរកទិសឧត្ដរ, ទ្រង់បន្លឺអាសភិវាចា (សំដីរបស់សប្បុរស) ថា "ខ្លួនយើងជាកំពូលនៃលោក ជាបុគ្គលប្រសើរជាងគេក្នុងលោក ជា

www.budinst.gov.kh www.elibraryofcambodia.org

ចម្បងជាងគេទាំងអស់ក្នុងលោក ជាតិនេះជាកំណើតចុងបំផុតរបស់យើង កំណើតទៅមុខយើងលែងកើតទៀតហើយ" ។

៥១– សំ. កាលដែលព្រះពោធិសត្វប្រសូតមកភ្លាម យាងទៅបាន ៧ ជំហាន ហើយបន្លឺអាសភិវាចាបានយ៉ាងនេះ ជាការចំឡែកពីសាមញ្ញ-ជនណាស់ រឿងនេះគួរឲ្យសន្និដ្ឋានថាដូចម្ដេច?

ប. គួរឲ្យសន្និដ្ឋានថា ជាការសំដែងសេចក្ដីប្រៀបធៀបនឹងបដិបត្តិក្នុងវេលាដែលព្រះអង្គបានត្រាស់ដឹងហើយ គឺថាការណ៍ដែលព្រះពោធិសត្វយាងទៅបាន ៧ ជំហានហើយឈប់ឈរនោះ ជាបុព្វនិមិត្តនៃការផ្សាយសាសនាឲ្យផ្សាយទូទៅក្នុងជនបទទាំង ៧ ឬក៏យាងទៅដោយព្រះអង្គឯងក្នុងជនបទទាំង ៧ នោះ ។ ឯជនបទទាំង ៧ នោះគឺ កាសីរួមនឹងកោសល ១, មគធរួមនឹងអង្គៈ ១, សក្កៈ ១, វជ្ជី ១, មល្លៈ ១, វង្សៈ ១, កុរុ ១ ក្រៅពីនេះមានតែជនបទតូច ៗ ដែលត្រូវនៅក្បែរជនបទធំ ៗ នោះ ។ ការណ៍ដែលព្រះពោធិសត្វឈប់ឈរត្រឹមប៉ុណ្ណោះ ជាបុព្វនិមិត្តនៃការផុតអស់វេលារបស់ព្រះអង្គត្រឹមណោះ ។ ការណ៍ដែលព្រះពោធិសត្វបន្លឺអាសភិវាចាប្រកាសព្រះអង្គថាជាឯកក្នុងលោកនោះ ជាបុព្វនិមិត្តនៃការត្រូវសំដែងធម៌ឲ្យមហាជនស្គាល់ចាំ ហើយក៏បានឃើញគុណវិសេសថាព្រះអង្គជាកំពូលនៃអ្នកប្រាជ្ញមែន ។

៥២ ៖ សំ. កាលព្រះពោធិសត្វប្រសូតនោះមានមនុស្សសត្វនិងរបស់ប៉ុន្មានយ៉ាងកើតក្នុងថ្ងៃជាមួយនឹងព្រះអង្គ ?

ប. មានមនុស្ស ៤ នាក់ គឺ ព្រះនាងពិម្ពា ១, ព្រះអានន្ទជាបុត្រនៃព្រះបាទសុក្កោទនៈ ១, នាយឆន្នអាមាត្យ ១, កាឡុទាយីអាមាត្យ ១, សេះឈ្មោះកណ្ឋកៈ ១, ដើមពោធិព្រឹក្ស ១, កំណប់ទ្រព្យទាំងបួន ១ រួមជា ៧ យ៉ាង ហៅថាសហជាតវត្ថុ ។

៥៣ សំ. ចុះកំណប់ទ្រព្យទាំង ៤ នោះ មានឈ្មោះនិងទំហំខុសគ្នាដូចម្ដេច ?

ប. ខុសគ្នាដូច្នេះ៖ កំណប់ទ្រព្យ ១ ឈ្មោះសង្ខនិធិ មានសំណុំមាត់មូលជុំវិញ ១ គាវុត ។ កំណប់ទ្រព្យ ១ ឈ្មោះឯលនិធិមានរង្វង់មាត់មូលជុំវិញកន្លះយោជន៍ ។ កំណប់ទ្រព្យ ១ ឈ្មោះឧបលនិធិ មានរង្វង់មាត់មូលជុំវិញ ៣ គាវុត ។ កំណប់ទ្រព្យ ១ ឈ្មោះបុណ្ឌរីកនិធិ មានរង្វង់មាត់មូលជុំវិញ ១ យោជន៍ ។ កំណប់ទ្រព្យទាំង ៤ នេះ មានជម្រៅរហូតដល់ទីបំផុតផែនដីដូចគ្នា ។

៥៤ សំ. ក្នុងពេលដែលព្រះពោធិសត្វប្រសូតនោះ មានកើតហេតុអស្ចារ្យប៉ុន្មានប្រការ ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. មាន ៣២ ប្រការ គឺមានការញាប់ញ័រផែនដីជាដើម ដូចជាក្នុងពេលដែលព្រះអង្គចុះចាប់បដិសន្ធិដែរ ។

៥៥-ស. ព្រះពោធិសត្វកើតក្នុងជនពួកណា ? ក្នុងជនបទនិងទ្វីបដែនឈ្មោះអ្វី ? មានត្រកូលនិងគោត្រដូចម្ដេច ?

ឆ. ព្រះអង្គកើតក្នុងពួកជនជាតិអរិយកៈ, ក្នុងមជ្ឈិមជនបទ ជម្ពូទ្វីបដែនសក្កៈ; ត្រកូលក្សត្រសាក្យៈ ជាគោតមគោត្រ ជាព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនៈ ព្រះរាជាក្រុងកបិលពស្តុ និងព្រះនាងសិរិមហាមាយាទេវី ។

៥៦-ស. មនុស្សក្នុងពួកអរិយកៈ វិសេសយ៉ាងណា បានជាគេសរសើរច្រើនម្ល៉េះ? ឬគេសរសើរដោយសារតែព្រះសាស្ដាកើតក្នុងមនុស្សពួកនោះទេ? ចូរឆ្លើយឲ្យសមតាមហេតុផល!

ឆ. ជាតិអរិយកៈ ជាពួកអ្នកចំរើនដោយចំណេះវិជ្ជានិងទំនៀមទំលាប់ ប៉ុនប្រសប់ខាងយុទ្ធវិធីនិងការគ្រប់គ្រងស្រុកទេសហើយមានឫទ្ធិអំណាចច្រើនៈ មិនមែនគេសរសើរដោយសារតែព្រះសាស្ដាកើតក្នុងវង្សជាតិអរិយកៈនេះទេ សូម្បីពីគ្រាមុនដែលព្រះសាស្ដាមិនទាន់កើតគេក៏បានសរសើរថាជាជាតិចំរើនមកហើយដូចជាកាលពួកអរិយកៈរុករានចេញពួកមិលក្ខៈ ជាម្ចាស់ស្រុកដើមឲ្យរត់ចេញអស់នោះក៏ព្រោះតែគេមានអំ-

www.budinst.gov.kh www.elibraryofcambodia.org

ណា ចនឹងស្ថិតតាំងនៅរឹងប៉ឹង គេបានតាំងជាស្រុកទេសនៅខ្ជាប់ខ្ជួនជារបស់ខ្លួនរហូតមក ល្បីល្បាញ ឈ្មោះថាជាតិអរិយកៈ គាប់គ្រប់គ្រងស្រុកទេស ព្រមទាំងធ្វើឲ្យកើតសេចក្តីចំរើនបានច្រើនជាងពួកមិលក្ខៈ ជាម្ចាស់ស្រុកដើម ហេតុនេះបានជាគេសរសើរថាពួកអរិយកៈ វិសេសមែន មិនមែនដោយសារតែព្រះសាស្តា កើតឡើងក្នុងពួកនោះទេ ។

## ទំនាយព្រះលក្ខណៈនៃព្រះសាស្តា

៥៧– ស. ចូរពណ៌នាអំពីកាឡទេវិលតាបសដែលចូលទៅមើលព្រះមហាបុរស ឲ្យឃើញថាមានសេចក្តីអស្ចារ្យដូចម្តេចខ្លះ !

ឆ. កាលវេលាដែលកាឡទេវិលតាបសចូលទៅសុំព្រះរាជបុត្រមើល នោះព្រះបាទសិរីសុទ្ធោទនៈ ទ្រង់បង្គាប់ឲ្យរាជបុរសឲ្យយកព្រះរាជបុត្រមកថ្វាយបង្គំតាបស, ប៉ុន្តែក្នុងខណៈដែលរាជបុរសនាំយកមកដល់នោះ បែរជាព្រះបាទទាំងពីរនៃព្រះមហាបុរសទៅប្រតិស្ឋានលើជដាតាបសវិញៗ ព្រះតាបសឃើញហេតុអស្ចារ្យដូច្នោះ ក៏ក្រោកចាកអាសនៈធ្វើអញ្ជលីទ្រព្រះបាទាព្រះមហាសត្វ ។ ព្រះបិតាទតឃើញហើយ ក៏ថ្វាយបង្គំព្រះរាជឱរសដោយសំគាល់ថាដូចជាមហាព្រហ្ម ។

៥៨ ស. ចុះកាឡទេវិលតាបសទាយព្រះមហាបុរសជាប៉ុន្មានយ៉ាង?

ឆ. ទាយតែមួយយ៉ាងថា: ព្រះមហាបុរសនឹងបានត្រាស់ជាព្រះពុទ្ធ មិនខានឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

៥៩– សួ. ចុះកាឡទេវិលតាបសប្រាប់អ្នកណាឲ្យចេញបួសរង់ចាំព្រះពោធិសត្វដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខ ?

ឆ្លើ. ប្រាប់នាឡកកុមារជាក្មួយឲ្យចេញបួស ។ នាឡកកុមារក៏ចេញបួសតាមបណ្ដាំតាបស, លុះបានជួបនឹងព្រះសាស្ដាក៏បានទទួលប្រព្រឹត្តមោនេយ្យប្បដិបត្តិអំពីព្រះអង្គ ហើយបានសម្រេចព្រះអរហត្តបរិនិព្វានទៅ ។ ចំណែកកាឡទេវិលតាបសលុះអស់ជីវិតបានទៅកើតក្នុងអរូបភព ។

៦០ - សួ. ព្រះពោធិសត្វប្រសូតកន្លងមកបានប៉ុន្មានថ្ងៃ ទើបព្រះបិតាឲ្យព្រាហ្មណ៍មកទាយលក្ខណៈថ្វាយ ?

ឆ្លើ. រាប់ពីថ្ងៃប្រសូតបាន ៥ ថ្ងៃ ។

៦១ – សួ ចុះព្រាហ្មណ៍ប៉ុន្មាននាក់ ជាអ្នកទាយលក្ខណៈ ? ព្រាហ្មណ៍ទាំងនោះឈ្មោះអ្វីខ្លះ ?

ឆ្លើ. ព្រាហ្មណ៍ទាំង ១០៨ នាក់ ប៉ុន្តែជ្រើសយកតែព្រាហ្មណ៍ដែលចេះដឹងត្រៃវេទស្ទាត់ជាងគេ បាន ៨ នាក់ទុកឲ្យទាយ សល់ពីនេះឲ្យត្រឡប់ទៅផ្ទះខ្លួនវិញ ។ ឯព្រាហ្មណ៍ទាំង៨ នាក់នោះគឺ រាមព្រាហ្មណ៍១, លក្ខណព្រាហ្មណ៍១, យញ្ញព្រាហ្មណ៍១, ធជព្រាហ្មណ៍១, ភោជព្រាហ្មណ៍១, សុទត្តព្រាហ្មណ៍ ១, សុយាមព្រាហ្មណ៍ ១, កោណ្ឌញ្ញព្រាហ្មណ៍១ ។

www.budinst.gov.kh www.elibraryofcambodia.org

៦២ - ស. ចុះបណ្ដាព្រាហ្មណ៍ទាំង ៨ នាក់នោះ តើព្រាហ្មណ៍ណាទាយថា ព្រះមហាបុរសមានគតិប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ. ព្រាហ្មណ៍ ៧ នាក់ ខាងដើមលើកម្រាមដៃពីរឡើង ហើយទាយជាគតិ ២ យ៉ាងថា "ព្រះមហាបុរសបើនៅជាឃរាវាស នឹងបានសោយរាជសម្បត្តិជាស្ដេចចក្រពត្តិ, បើចេញបួសនឹងបានត្រាស់ជាព្រះពុទ្ធ" ។ ចំណែកកោណ្ឌញ្ញព្រាហ្មណ៍ ដែលក្មេងជាងគេលើកម្រាមដៃតែមួយឡើង ហើយទាយតែម្យ៉ាងថា "ព្រះមហាបុរសនឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ" ។

៦៣ - ស. ព្រះមហាបុរសប្រកបដោយលក្ខណៈប៉ុន្មានប្រការ ? គឺអ្វីខ្លះ ? ចូររាប់ឲ្យគ្រប់មកមើល !

ឆ. លក្ខណៈ ៣២ ប្រការ គឺ ១- មានផ្ទៃព្រះបាទទាំងគូរាបស្មើ ។ ២- ត្រង់ផ្ទៃព្រះបាទទាំងគូមានរូបចក្រប្រកបដោយកណ្ដាប់កងនឹងដុំព្រមទាំងកាំមួយពាន់មានចន្លោះស្មើគ្នាគ្រប់អន្លើ ។ ៣- មានព្រះបណ្ហិគឺកែងវែង (បើចែកសរីរប្បទេសត្រង់នោះជា ៤ ភាគ ពីរភាគជាចុងព្រះបាទ, មួយភាគជាកព្រះបាទ, មួយភាគជាព្រះបណ្ហិ) ។ ៤- មានព្រះអង្គុលីគឺម្រាមព្រះហស្ដម្រាមព្រះបាទវែង ១ (ចំណែកម្រាមព្រះហស្ដទាំង ៤ វែងស្មើគ្នា ម្រាមព្រះបាទទាំង ៥ វែងស្មើគ្នា) ម្រាមទាំងអស់

www.budinst.gov.kh www.elibraryofcambodia.org

ត្រង់ក, សរីរប្បទេសទាំង ៧ អន្លើនេះ មានសាច់ពេញគន្លឹកល្អឥតមានឃើញសរសៃតិចតួចឡើយ) ។ ១៧- មានចំណែកកន្លះព្រះកាយខាងដើមស្រដៀងនឹងចំណែកកន្លះកាយនៃរាជសីហ៍ (ត្រង់កន្លែងដែលគួរវែង គួរខ្លី គួរធាត់ គួរស្គម ឬគួររៀវ គួរមូល, ក៏វែង ខ្លី ធាត់ ស្គម ឬរៀវ មូល សមល្អឥតមានខ្ចង) ។ ១៨- មានចន្លោះព្រះប្រឹស្ឋប្រទេសពេញបរិបូណ៌ គឺមានខ្នងពេញស្មើឥតមានចន្លោះផតខូចត្រង់កណ្តាលឡើយ ។ ១៩- មានទ្រង់ទ្រាយព្រះកាយប្រហែលនឹងបរិមណ្ឌលនៃដើមជ្រៃ គឺមានកាយនឹងព្យាមប្រវែងស្មើគ្នា (ដូចជាជ្រៃមានប្រវែងដើមនឹងមែកមិនលើសមិនខ្វះហួសគ្នាប៉ុន្មាន) ។ ២០- មានព្រះខន្ធប្បទេស គឺកមូលសម ។ ២១- មានព្រះប្រសាទគឺសរសៃល្អិតធ្លាក់ក្រៃលែងសម្រាប់ទទួលរសអាហារ គឺមានសរសៃយ៉ាងឆ្មារល្អិត ៧ ពាន់ ប្រជុំស្រោបត្រង់កសម្រាប់ទទួលនាំរសអាហារឲ្យជ្រួតជ្រាបផ្សព្វផ្សាយក្នុងកាយទាំងមូលបានឥតមានទើសទាក់ (សូម្បីអាហារយ៉ាងតូចតិចត្រឹមប៉ុនគ្រាប់ល្ង ១ ក៏អាចជ្រួតជ្រាបសព្វសព្វាង្គកាយបាន) ។ ២២- មានព្រះហនុគឺចង្កាសណ្ឋានស្រដៀងនឹងចង្ការាជសីហ៍ (ពេញបរិបូណ៌ប្រហែលដូចជាព្រះចន្ទត្រង់ថ្ងៃ ១២ កើត) ។ ២៣- មានព្រះទន្តគឺធ្មេញ ៤០ កត់ (ខាងលើ ២០ ខាងក្រោម ២០) ។ ២៤- មានព្រះទន្តរាបស្មើ (មិនប្រជូសឬប្រពើសខ្ពស់ទាបដូចជាធ្មេញនៃមនុស្សសាមញ្ញពួកខ្លះនោះឡើយ) ។ ២៥- មានព្រះទន្តជិតសនិទល្អ ។

www.budinst.gov.kh www.elibraryofcambodia.org

២៦- មានព្រះទាឋាគឺព្រះចង្កូម (ទាំង៤) សស្អាត (ភ្លឺរុងរឿងជាងពន្លឺនៃផ្កាយព្រឹក) ។ ២៧- មានព្រះជិវ្ហាគឺអណ្តាតល្មមល្អ (វែងជាងអណ្តាតនៃមនុស្សទាំងអស់ក្នុងលោក) ។ ២៨- មានព្រះសូរសៀងគឺសូរស័ព្ទសម្លេងក្រានក្រអៅដូចជាសម្លេងនៃព្រហ្ម; កាលបើបញ្ចេញវាចាណាចេញពីពោះដូចជាសម្លេងនៃសត្វករវិក ។ ២៩- មានព្រះនេត្រខៀវស្រស់ (ត្រង់កន្លែងដែលគួរខៀវ ក៏ខៀវស្រស់ដូចផ្កាត្រកៀត ឬផ្កាកណ្តៀង, ត្រង់កន្លែងដែលគួរលឿង ក៏លឿងស្រស់ដូចផ្កាកណ្ណិការ, ត្រង់កន្លែងដែលគួរក្រហាម ក៏ក្រហាមស្រស់ដូចផ្កាចក្សារ, ត្រង់កន្លែងដែលគួរស ក៏សថ្លាត្រចះដូចផ្កាយព្រឹក, ត្រង់កន្លែងដែលគួរខ្មៅ ក៏ខ្មៅស្រស់ដូចផ្លែផ្តិ) ។ ៣០- មានដួងព្រះនេត្រស្រដៀងនឹងដួងភ្នែកនៃគោ គឺមានដួងព្រះនេត្រទាំងពីរថ្លាយង់ ស្រដៀងនឹងដួងភ្នែកនៃកូនគោសម្បុរក្រហមដែលទើបនឹងសម្រាលមួយរំពេចនោះ ។ ៣១- មានព្រះឧណ្ណាលោម គឺរោមដុះត្រង់ចន្លោះព្រះភមូ (ចិញ្ចើម), មានសម្បុរសក្បុសទន់ល្ងន់ដូចជាសំឡី ។ ៣២- មានព្រះសិរហាក់ដូចជាប្រដាប់ដោយក្បាំងស្រេចស្រាប់ (រុងរឿងដូចជាព្រះមហាក្សត្រដែលទ្រង់នូវក្បាំងព្រះភក្ត្រ); មានន័យមួយទៀតថា មានព្រះសិរមូលបរិបូណ៌ល្អដូចជាមកុដ, ឬមូលហាក់ដូចជាវត្ថុដែលគេក្រឡឹងហើយយកមកដំកល់, ពុំនោះសោត មូលហាក់ដូចជាពពុះទឹកដែលប៉ោងឡើង ។

www.budinst.gov.kh www.elibraryofcambodia.org

៦៤-សួ. ព្រះមហាបុរសប្រកបដោយអនុព្យញ្ជនៈប៉ុន្មានប្រការ? គឺអ្វីខ្លះ? ចូររាប់ឲ្យគ្រប់មកមើល !

ឆ. អនុព្យញ្ជនៈ ៨០ ប្រការគឺ ១-ម្រាមព្រះហស្តនិងម្រាមព្រះបាទស្រួចៗ ២-ម្រាមព្រះហស្តនិងម្រាមព្រះបាទទៀវៗ ៣-ម្រាមព្រះហស្តនិងម្រាមព្រះបាទមូល ៗ ៤-ព្រះនខា (ក្រចក) ទាំង ២០ មានពណ៌ក្រហម ៗ ៥-ព្រះនខាទាំង ២០ នោះងស្ដើតឡើងលើ ៗ ៦-ព្រះនខានោះមានពណ៌រលោងរលើបៗ ៧-កព្រះហស្តនិងព្រះបាទគ្រួតនៅក្នុងព្រះមំសៈ ៗ ៨-ព្រះបាទទាំងគូស្មើគ្នា ៗ ៩-ព្រះអាការដំណើរល្អដូចជាដំណើរនៃគុញ្ជរជាតិ ៗ ១០-ព្រះដំណើរល្អដូចជាដំណើរនៃរាជសីហ៍ ៗ ១១-ព្រះដំណើរល្អដូចជាដំណើរនៃហង្ស ៗ ១២-ព្រះដំណើរល្អដូចជាដំណើរនៃគោឧសភរាជ ៗ ១៣-កាលទ្រង់ឈររនឹងយាងទៅនោះទ្រង់លើកព្រះបាទខាងស្តាំឈានទៅមុន ៗ ១៤-ព្រះជាណុមណ្ឌល (ជង្គង់) មូលល្អបរិបូណ៌ ៗ ១៥-មានបុរិសព្យញ្ជនៈបរិបូណ៌ គឺមិនមានកិរិយាមារយាទស្រដៀងនឹងស្ត្រី ៗ ១៦-ព្រះនាភី (ផ្ចិត) មិនខូងផត ហើយមូលល្អ ៗ ១៧-ព្រះឧទរ (ពោះ) មានសណ្ឋានជ្រៅ ៗ ១៨-ព្រះឧទរមានស្នាមខ្ញៅវិលជាទក្ខិណាវដ្ត ៗ ១៩-ព្រះឩរូ (ភ្លៅ) ទាំងគូមូលល្អ ៗ ២០-ព្រះហស្តទាំងគូល្អ ៗ ២១-ព្រះអង្គាពយវៈ ធំតូចទាំងពួងមានចំណែកដ៏ល្អ ៗ ២២-ព្រះមំសៈដែលគួរក្រាស់ក៏ក្រាស់ ៗ ២៣-ព្រះមំសៈ

www.budinst.gov.kh www.elibraryofcambodia.org

មិនជ្រួញជ្រីវ ។ ២៤-ព្រះសរីរកាយទាំងអស់ ប្រាសចាកគាបម៉ុយនឹងពជ្រុយ ។ ២៥-ព្រះកាយល្អបរិសុទ្ធសមគួរដោយលំដាប់តាំងខាងលើខាងក្រោម ។ ២៦-ព្រះកាយបរិសុទ្ធទាំងអស់ប្រាសចាកមន្ទិលទាំងតួង ។ ២៧-មានកម្លាំងច្រើន ។ ២៨-មានព្រះនាសិក (ច្រមុះ) ខ្ពស់ ។ ២៩-សណ្ឋានព្រះនាសិកល្អ ។ ៣០-បបូរព្រះ●ស្ឋខាងក្រោមមិនបានចូលចេញជាងគ្នា ត្រឹមស្មើគ្នាល្អ ។ ៣១-ព្រះទន្តបរិសុទ្ធប្រាសចាកមន្ទិល ។ ៣២-ព្រះទន្តសដូចសម្បុរស័ង្ខ ។ ៣៣-ព្រះទន្តរលីងស្អាតមិនគគ្រាត ។ ៣៤-ព្រះឥន្ទ្រិយទាំង ៥ ល្អបរិសុទ្ធ ។ ៣៥-ព្រះចង្កូមទាំង ៤ មូលបរិបូណ៌ ។ ៣៦-វង់ព្រះភ័ក្ត្រមានសណ្ឋានវែងសមល្អ ។ ៣៧-ព្រះប្រាង្គ (ថ្ពាល់) ទាំងគូភ្លឺថ្លាល្អស្មើគ្នា ។ ៣៨-អញ្ចាញព្រះហស្ដមានស្នាមជ្រៅ ។ ៣៩-អញ្ចាញព្រះហស្ដមានស្នាមវែង ។ ៤០-អញ្ចាញព្រះហស្ដមានស្នាមត្រង់ ។ ៤១-អញ្ចាញព្រះហស្ដមានស្នាមក្រហមរុងរឿង ។ ៤២-រស្មីព្រះកាយឱភាស (ភ្លឺ) ជាបរិមណ្ឌល ។ ៤៣-ព្រះប្រាង្គ (ថ្ពាល់) ទាំងគូពេញកំពុងណែនល្អបរិបូណ៌ ។ ៤៤-ត្របកព្រះនេត្រទូលាយវែងល្អសមគួរ ។ ៤៥-ព្រះនេត្រប្រកបដោយប្រសាទទាំង ៥ មានសផាដើមថ្លាស្អាតបរិសុទ្ធទាំងអស់ ។ ៤៦-ចុងសរសៃព្រះលោមាទាំងឡាយមិនបានវៀចង់ ។ ៤៧-ព្រះជិវ្ហាមានសណ្ឋានដ៏ល្អ ។ ៤៨-ព្រះជិវ្ហាទន់មិនរឹង ។ ៤៩-ព្រះថនៈ (ដោះ) ទាំងគូមានសណ្ឋាន

វែងដូចជាត្របកបទុមជាតិ ។ ៥០- ផ្ចិតព្រះកមានសណ្ឋានមូលល្អ ។ ៥១- របៀបសរសៃទាំងពួងស្អាតល្អមិនបានជ្រួញជ្រីវ ។ ៥២- ផ្លូវសរ-សៃទាំងឡាយក្រគរនៅក្នុងព្រះមំសៈទាំងអស់ ។ ៥៣- ព្រះសិរមានសណ្ឋានល្អដូចផ្លែត្រកៃ ។ ៥៤- បរិមណ្ឌលព្រះនលាដ (ថ្ងាស) ទូលាយវែងល្អមសមគួរ ។ ៥៥- ព្រះនលាដមានសណ្ឋានដ៏ល្អ ។ ៥៦- ព្រះភមូ (ចិញ្ចើម) មានសណ្ឋានដ៏ល្អដូចធ្នូដំកោង ។ ៥៧- ព្រះលោមាត្រង់ព្រះភមូមានសរសៃដ៏ល្អិត ។ ៥៨- សរសៃព្រះលោមាត្រង់ព្រះភមូដុះឡើងហើយដួលកបទៅដោយលំដាប់ ។ ៥៩- ព្រះភមូនោះធំ ។ ៦០- ព្រះភមូនោះវែងផុតចុងព្រះនេត្រ ។ ៦១ ព្រះឆវីវណ្ណល្អិតឆ្មារពេញព្រះកាយ ។ ៦២- ព្រះសរីរកាយរុងរឿងទៅដោយសិរី ។ ៦៣ ព្រះសរីរកាយមិនគាប់សៅហ្មងតែងភ្លឺថ្លាជានិច្ច ។ ៦៤- ព្រះសរីរកាយស្រស់ថ្លាដូចផ្កាបទុម-ជាតិ ។ ៦៥- ព្រះសរីរកាយមានសម្ផស្សទន់ភ្លន់ ។ ៦៦- ក្លិនព្រះសរីរ-កាយក្រអូបឈ្ងុយដូចសុគន្ធជាតិ ។ ៦៧- ព្រះលោមា មានសរសៃស្មើគ្នាទាំងអស់ ។ ៦៨- ព្រះលោមាមានសរសៃល្អិតឆ្មារ ។ ៦៩- មាន-ខ្យល់អស្សាសបស្សាសៈដ៏ល្អិត ។ ៧០ ព្រះឱស្ឋមានសណ្ឋានល្អដូចជាញញឹមញញែម ។ ៧១- ក្លិនព្រះឱស្ឋដូចជាក្លិនផ្កាឧប្បល ។ ៧២- ព្រះកេសាខ្មៅរលោងស្រិល ។ ៧៣- ក្លិនព្រះកេសាក្រអូបឈ្ងុយ ។ ៧៤- ព្រះកេសាមានក្លិនដូចជាផ្កាកោមល (ផ្កាឈូក) ។ ៧៥- ព្រះកេសា

www.budinst.gov.kh www.elibraryofcambodia.org

មានសណ្ឋានមូល ។ ៧៦- ព្រះកេសាខ្មៅស្និទ្ធ ។ ៧៧- សរសៃព្រះកេសាឆ្មារល្អិត ។ ៧៨- សរសៃព្រះកេសាស្លូតមិនក្រញាញ់ ។ ៧៩ សរសៃព្រះកេសាវិលជាទក្ខិណាវដ្ត ។ ៨០- ល្អដោយព្រះរស្មីគុម្ពុះលើព្រះសិរ ។

៦៥ – ស. ព្រះមហាបុរសប្រកបដោយមង្គលប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? ចូររាប់ឲ្យគ្រប់មកមើល !

ច. ព្រះមហាបុរសមានផ្ទៃបាតព្រះបាទទាំងគូប្រកបដោយលាយ-លក្ខណ៍កង់ចក្រមួយម្ខាងនៅត្រង់ពាក់កណ្ដាលបាតព្រះបាទ ។ ឯកង់ចក្រនោះមានកាំ ១ ពាន់ប្រកបដោយកង់និងផុំបរិបូណ៌ដោយអាការទាំងពួងខាងក្រៅជុំវិញកង់ចក្រនោះប្រដាប់ទៅដោយរូបមង្គល ១០៨ យ៉ាងគឺ ៖ រូបលំពែង១, រូបកញ្ចក់ខ្ទុះរូប១, រូបផ្កាខ្លួនស្រើច១, រូបខ្សែបយ១, រូបសង្វារ១, រូបថាសមាស១, រូបជើងតាំង១, រូបមច្ឆាទាំងគូ១, រូបប្រាសាទ១, រូបកង្វេរ១, រូបសសរខៀន១, រូបស្វេតច្ឆត្រ១, រូបព្រះខាន់១, រូបផ្លិតស្លឹកត្នោត១, រូបផ្លិតកន្ទុយក្ងោក១, រូបផ្លិតវាលវីជនី១, រូបមកុដ១, រូបបាត្រ១, រូបកម្រងផ្កាម្លិះ១, រូបផ្កាឧប្បលខៀវ១, រូបផ្កាឧប្បលស១, រូបផ្កាឧប្បលក្រហម១, រូបផ្កាឈូកក្រហម១, រូបផ្កាឈូកស១, រូបឆ្នាំងពេញដោយទឹក១, រូបថាសពេញដោយទឹក១, រូបមហាសមុទ្រទាំងបួន១, រូបភ្នំចក្រវាល១, រូបព្រៃហិមពាន្ត១, រូបភ្នំសិនេរុ១, រូបព្រះចន្ទ្រ១, រូបព្រះអាទិត្យ១,

www.budinst.gov.kh www.elibraryofcambodia.org

រូបពួកផ្កាយនក្ខត្តឫក្ស១, រូបទ្វីបធំទាំងបួន១, រូបទ្វីបតូចទាំងពាន់១, រូបស្តេចបរមចក្រពត្តិព្រមទាំងរាជបរិវារ១, រូបស័ង្ខទក្ខិណាវដ្ដ១, រូបសុវណ្ណមច្ឆា១, រូបចក្រទាំងគូ១, រូបស្ទឹងទាំងប្រាំពីរ១, រូបស្រះធំទាំងប្រាំពីរ១, រូបភ្នំបរិភណ្ឌទាំងប្រាំពីរ១, រូបស្តេចគ្រុឌ១, រូបក្រពើ១, រូបទង់ជ័យទង់សំពត់ទាំងផ្គត់១, រូបរាជបល្ល័ង្ក១, រូបកៅអី១, រូបភ្នំកៃលាស១, រូបរាជសីហ៍១, រូបព្យគ្ឃរាជ១, រូបដំរីឯករ័ណ្ណ១, រូបស្តេចវលាហក១, រូបព្រះបាទវាសុកីនាគរាជ១, រូបស្តេចហង្ស១, រូបមាន់ព្រៃ១, រូបគោឧសភរាជ១, រូបស្តេចដំរីឧបោសថ១, រូបស្តេចដំរីឆទ្ទន្ត១, រូបមករមាស១, រូបមហាព្រហ្មបួន១, រូបផ្ទះមាស១, រូបអណ្តើកមាស១, រូបមេគោព្រមទាំងកូន១, រូបកិន្នរឈ្មោល១, រូបកិន្នរញី១, រូបសត្វករវិក១, រូបសត្វក្រៀល១, រូបសត្វក្ងោក១, រូបសត្វចាក្រពាក១, រូបស្តេចសត្វគ្រលីត១, រូបឆកាមាវចរទេវលោកទាំង៦ជាន់១, រូបសោឡសមហាព្រហ្មទាំង ១៦ ជាន់ ១ ត្រូវជារូបមង្គល ១០៨ ប្រការជាបរិវារហោមរោមកង់ចក្រធំត្រង់កណ្តាលបាតព្រះបាទទាំងគូឆ្វេងស្តាំដូចគ្នា ៗ(១)

---

១ - ក្នុងធាតិកាប្រាប់ជាមង្គលមាន ១០៨ ប៉ុន្តែរាប់មើលទៅឃើញតែត្រឹម ៧២ យ៉ាងប៉ុណ្ណោះ ស្វែងរកក្នុងច្បាប់ផ្សេង ៗ ក៏មិនឃើញមានលើសពីនេះទៀត មិនដឹងជាលោករាប់ចំនួនយ៉ាងណា សូមលោកអានជួយរិះរកផងចុះ ៗ

www.budinst.gov.kh www.elibraryofcambodia.org

៦៦– សំ. មហាបុរិសលក្ខណៈ ៣២ ប្រការក្ដី អនុព្យញ្ជនៈ ៨០ ប្រការក្ដី រូបមង្គល ១០៨ ក្ដី មានចំពោះតែព្រះសាស្ដានៃយើងមួយព្រះអង្គប៉ុណ្ណោះទេឬ ឬក៏ព្រះពុទ្ធទាំងឡាយមានដូចគ្នាដែរ ?

ឆ្លើ. មានដូចគ្នាគ្រប់ព្រះអង្គទាំងអស់ ។

៦៧– សំ. ការសរសើរលក្ខណៈព្រះកាយនៃព្រះមហាបុរសទាល់តែជាហេតុឲ្យមានពាក្យទំនាយ ២ យ៉ាងនោះតើមានប្រយោជន៍ដូចម្ដេច ?

ឆ្លើ. សេចក្ដីត្រាស់ដឹងមិនមែនជាប់ជំពាក់នឹងរូបកាយក៏ពិតមែនហើយ ប៉ុន្ដែគុណធម៌សេចក្ដីល្អរបស់មនុស្សដោយច្រើនៗ តែមានក្នុងសន្ដាននៃអ្នកមានរូបកាយ ដែលនាំឲ្យកើតសេចក្ដីស្រឡាញ់រាប់អានមិនសូវមានក្នុងសន្ដាននៃមនុស្សអ្នកមានរូបពិការមិនសមរម្យទេ; ការមានរូបកាយប្រកបដោយលក្ខណៈដ៏ល្អនោះ រមែងនាំឲ្យកើតសេចក្ដីជ្រះថ្លារបស់ពួកជនអ្នកធ្ងន់ក្នុងរូប ដែលហៅថា រូបប្បមាណិកា ជាហេតុនាំឲ្យមនុស្សពួកដទៃទៀតកើតសេចក្ដីជ្រះថ្លាជាខាងដើម; ការសរសើរលក្ខណៈនៃព្រះកាយមានប្រយោជន៍ក្នុងការចង្អុលឲ្យឃើញថា ជាភាជនៈដែលគួរទទួលរាប់រងព្រះពោធិញាណទាំងនាំឲ្យកើតសេចក្ដីជ្រះថ្លាក្នុងខាងដើមយ៉ាងនេះ ។ ព្រះជាតិទទួលរាប់រងព្រះពោធិញាណបានដូចម្ដេច ព្រោះ

www.budinst.gov.kh www.elibraryofcambodia.org

កាយដ៏ប្រកបដោយព្រះលក្ខណៈគំទទួលរាប់នៃព្រះពោធិញ្ញាណបាន ដូច្នោះ ហេតុនោះបានជាលោកសរសើរទុកមក ។

## រាជាភិសេក

៦៨– សំ ព្រះមហាបុរសមានព្រះនាមថាអ្វីខ្លះ? ហេតុអ្វីបានជាគេថ្វាយព្រះនាមដូច្នោះ ?

ឞ. ព្រះអង្គមានព្រះនាមថា ''អង្គីរស'' ។ ព្រោះហេតុមានព្រះរស្មីភ្លឺចេញពីព្រះសរីរកាយ ។ មានព្រះនាមម្យ៉ាងទៀតថា ''សិទ្ធត្ថ'' ព្រោះហេតុព្រះអង្គជាអ្នកធ្វើឲ្យសម្រេចប្រយោជន៍ដល់សត្វលោកទាំងពួង។ ខាងក្រោយមកមានព្រះនាមម្យ៉ាងទៀតថា ''គោតម'' ដោយអំណាចគោត្រ ។

៦៩– សំ. ហេតុដូចម្តេចបានជាព្រះបាទសុទ្ធោទនៈបង្គាប់ឲ្យរក្សាព្រះរាជបុរសយ៉ាងមាំមួនម្ល៉េះ ?

ឞ. ហេតុតែព្រះអង្គទ្រង់ជ្រាបដោយសារពួកព្រាហ្មណ៍ក្រាបទូលថា ព្រះរាជកុមារនឹងចេញទ្រង់ព្រះផ្នួស ព្រោះបានឃើញទេវទូតទាំង៤ គឺមនុស្សចាស់ជរា១, មនុស្សឈឺ១, មនុស្សស្លាប់១, គេចអ្នកបួស១ ទើបទ្រង់ត្រាស់ហាមប្រាមមិនឲ្យមនុស្សទាំង ៤ ពួកនេះ ទៅជិតព្រះរាជបុត្រសោះ ។

www.budinst.gov.kh www.elibraryofcambodia.org

៣០ – សំ. ចូរពិចារណាមើល ! បើព្រះសាស្តានៃយើងសោយរាជសម្បត្តិជាស្តេចចក្រពត្តិហើយនឹងធ្វើជាព្រះសាស្តាឯកក្នុងលោក តើខាងណាមានប្រយោជន៍ច្រើនជាង ? កាលបើដូច្នោះ ហេតុអ្វីក៏ព្រះបិតាជាដើមឃាត់ខាំងទុកឲ្យនៅក្នុងកាមសុខវិញ ?

ឆ. ការសោយរាជ្យជាស្តេចចក្រពត្តិដែលមានសមុទ្រធំទាំង ៤ ជាអាណាខេត្ត នឹងធ្វើប្រយោជន៍ដល់មហាជនក្នុងទ្វីបនោះៗ បានតែត្រឹមសម្បត្តិមនុស្សនឹងសម្បត្តិសួគ៌ ដែលរាប់ថាជាលោកិយសុខប៉ុណ្ណោះ ។ បើលោកធ្វើជាព្រះសាស្តាឯកក្នុងលោក នឹងបានយាងទៅទេសនាប្រោសសត្វឲ្យបានសម្រេចសម្បត្តិទាំងបី គឺសម្បត្តិមនុស្ស, សម្បត្តិសួគ៌ នឹងសម្បត្តិព្រះនិព្វាន តាមឧបនិស្ស័យ ដែលរាប់ថាជាលោកុត្តរសុខ ដ៏ខ្ពង់ខ្ពស់ជាងលោកិយសុខ ។ ប៉ុន្តែព្រះញាតិវង្សមានព្រះរាជបិតាជាដើមប្រាថ្នានឹងឲ្យរាជកុមារគងព្រះរាជសន្តតិវង្ស ទាំងមិនទ្រង់ជ្រាបថា ការដែលបានត្រាស់ជាព្រះពុទ្ធធ្វើជាព្រះសាស្តាឯកក្នុងលោកនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍នឹងសេចក្តីសុខខ្ពង់ខ្ពស់ត្រឹមណាផងហេតុនោះបានជាធ្វើការការពារមិនឲ្យព្រះរាជកុមារចេញទ្រង់ព្រះផ្នួស ។

៣១ – សំ. ព្រាហ្មណ៍ទាំង ៨ នាក់ដែលទាយលក្ខណៈថ្វាយព្រះមហាបុរសតើប៉ុន្មាននាក់ស្លាប់មុនទៅ ? ប៉ុន្មាននាក់នៅរស់ទាន់ព្រះអង្គ ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ព្រាហ្មណ៍ ៧ នាក់ខាងដើម (ចូរមើលប្រស្នាលេខ ៦១) ស្លាប់ទៅមុនព្រះមហាបុរសបានត្រាស់ដឹង, ប៉ុន្តែបានផ្ដាំកូនគ្រប់គ្នាឲ្យចេញបួសតាមព្រះសាស្ដា ។ ចំណែកកោណ្ឌញ្ញព្រាហ្មណ៍នៅរស់ចេញបួសបានជួបនឹងព្រះសាស្ដា ។

៧២. ស. ព្រះញាតិវង្សនៃព្រះមហាបុរសមានចំនួនប៉ុន្មាន ? បានគោរពកប់អានព្រះមហាបុរសដែរឬទេ ?

ឆ. ព្រះញាតិវង្សខាងព្រះមាតាចំនួន ៨០ ពាន់, ខាងព្រះបិតា ៨០ ពាន់ រួមជា ១៦.០០០ ព្រះអង្គ ។ បានគោរពកប់អានព្រះមហាបុរសទាំងអស់អង្គ បានថ្វាយបុត្រមួយៗ នាក់ឲ្យធ្វើជាបរិវារនៃព្រះមហាបុរស ។

៧៣ ស. ព្រះនាងសិរីមហាមាយាប្រសូតព្រះមហាបុរសគន្លងមក បានប៉ុន្មានថ្ងៃទើបទិវង្គត ? ទិវង្គតហើយបានទៅកើតនៅស្ថានណា ? ទិវង្គតដោយហេតុអ្វី?

ឆ. រាប់ពីថ្ងៃប្រសូតមកបាន ៧ ថ្ងៃ ។ បានទៅកើតក្នុងតុសិតសួគ៌ ។ ដោយហេតុព្រះនាងអស់ព្រះជន្មត្រឹមប៉ុណ្ណោះ មិនមែនដោយហេតុដែលប្រសូតព្រះមហាបុរសទេ ។

៧៤. ស. ចុះព្រះនាងណាទទួលថែរក្សាបំបៅព្រះមហាបុរសតមកទៀត ?

www.budinst.gov.kh www.elibraryofcambodia.org

បា. ព្រះបាទសុទ្ធោទនៈទ្រង់លើកព្រះនាងបជាបតិគោតមីជាព្រះកនិដ្ឋភគិនី នៃព្រះនាងមហាមាយាជាព្រះអគ្គមហេសីឲ្យថែរក្សាព្រះមហាបុរសតមក ។.

៣៥ – សួ. ព្រះមហាបុរសមានបង ឬ ប្អូនរួមឧទរជាមួយដែរឬទេ ?

បា. គ្មានទេ ។ មានតែរួមបិតាជាមួយ គឺព្រះនន្ទកុមារ១, ព្រះនាងរូបនន្ទា ១ ដែលប្រសូតអំពីព្រះនាងបជាបតិគោតមី ។ ព្រះនន្ទកុមារប្អូនព្រះមហាបុរសតែបីថ្ងៃប៉ុណ្ណោះ ។

៣៦ – សួ. កាលព្រះមហាបុរសនៅជាព្រះកុមារ បានសម្រេចគុណវិសេសអ្វីដែរឬទេ ? ក្នុងព្រះជន្មប៉ុន្មាន ? មានរឿងរ៉ាវដូចម្ដេច ?

បា. ព្រះមហាបុរសបានសម្រេចបឋមជ្ឈាន ។ ក្នុងព្រះជន្មាយុ ៧ ថ្ងៃ ។ មានរឿងដំណាលថា ថ្ងៃមួយ ព្រះបាទសុទ្ធោទនៈស្ដេចចេញច្រត់ព្រះនង្គ័លទ្រង់អញ្ជើញព្រះមហាបុរសទៅផង ឲ្យផ្ទំក្រោមដើមព្រីងធំ ស្រីស្នំនឹងបរិវារចេញទៅមើលពិធីច្រត់ព្រះនង្គ័លអស់ ទោលព្រះមហាបុរសឲ្យផ្ទំនៅតែ ១ អង្គឯង ។ គ្រានោះ ព្រះមហាបុរសមានសេចក្ដីស្ងាត់ព្រះកាយស្ងាត់ព្រះទ័យ ទ្រង់គង់ពែនភ្នែនតាំងសមាធិ កំណត់ខ្យល់អស្សាសបស្សាសៈជាអារម្មណ៍ គង់ចំរើនអានាបានស្សតិកម្មដ្ឋាន ក៏បានសម្រេចបឋមជ្ឈាន មានវិតក្កៈ, វិចារ, បីតិ, សុខ កើតអំពីវិវេក

www.budinst.gov.kh www.elibraryofcambodia.org

ចាត់ជាអភិសម្ពោធិនិមិត្តជាគ្រាដំបូង ។ ព្រះរាជាយាងមកថ្វាយបង្គំព្រះរាជបុត្រម្ដងទៀតជាគំរប់ ២ ដង ។

៣៧ - ស. កាលព្រះមហាបុរសមានព្រះជន្មាយុប៉ុន្មានឆ្នាំ ទើបព្រះបិតាឲ្យជីកស្រះបោក្ខរណីថ្វាយ ?

ឆ. កាលព្រះអង្គមានជន្មាយុ ៧ ឆ្នាំ ព្រះវេស្សកម្មទេវបុត្រចុះមកនិម្មិតស្រះបោក្ខរណីប្រកបដោយកែវ ៧ ប្រការថ្វាយ ។

៣៨ - ស. ព្រះមហាបុរសមានព្រះជន្មប៉ុន្មានឆ្នាំ ព្រះបិតាឲ្យសាងប្រាសាទប៉ុន្មានថ្វាយ ? ឈ្មោះប្រាសាទអ្វីខ្លះ ?

ឆ. ព្រះមហាបុរសមានព្រះជន្ម ១៦ ឆ្នាំ ព្រះបិតាឲ្យសាងប្រាសាទ ៣ ថ្វាយ ។ គឺឈ្មោះចន្ទប្រាសាទ ១, កោកនទប្រាសាទ ១, កោញ្ចប្រាសាទ ១ ដើម្បីឲ្យព្រះអង្គគង់គ្រប់រដូវទាំងបី ។

៣៩ - ស. ព្រះមហាបុរសបានសោយរាជសម្បត្តិក្នុងព្រះជន្មប៉ុន្មាន? នៅថ្ងៃ-ខែ-ឆ្នាំអ្វី ? ស្ត្រីណាបានធ្វើជាព្រះអគ្គមហេសីនៃព្រះមហាបុរស?

ឆ. ក្នុងព្រះជន្ម ១៦ ឆ្នាំ ។ នៅថ្ងៃសៅរ៍, ពេញបូណ៌មី ខែអាសាឍ, ឆ្នាំឆ្លូវ មុនពុទ្ធសករាជ ៦៤ ឆ្នាំ ។ ព្រះនាងយសោធរា (ពិម្ពា) ព្រះរាជធីតានៃព្រះបាទសុប្បពុទ្ធ ក្នុងក្រុងទេវទហៈ ដែលប្រសូតអំពីព្រះនាងអមិតាជាព្រះកនិដ្ឋភគិនីនៃព្រះបាទសុទ្ធោទនៈមកធ្វើជាព្រះអគ្គមហេសី។

www.budinst.gov.kh www.elibraryofcambodia.org

# ព្រះសាស្តាចេញទ្រង់ព្រះផ្នួស

៨០– សំ. ព្រះគន្ថរចនាចារ្យពណ៌នាអំពីការសោយកាមសុខរបស់ព្រះមហាបុរសថាជាការអស្ចារ្យណាស់តើដើម្បីប្រាថ្នាប្រយោជន៍ដូចម្តេច?

ប. ដើម្បីសំដែងឲ្យឃើញថា សូម្បីព្រះអង្គបានទទួលសេចក្តីសុខដូច្នោះដែលមនុស្សរាប់អាន ប្រកាន់ថាជារបស់ល្អ ព្រះអង្គក៏អាចលះបង់ចោលបាន គ្មានសេចក្តីក្រេកអរអាឡោះអាល័យសោះ ព្រមទាំងដើម្បីនឹងឲ្យបុគ្គលដែលមានសេចក្តីស្រវឹង ក្នុងកាមសុខសម្បត្តិនឹងសរសើរកាមសុខថាជារបស់ល្អនោះ កើតសេចក្តីនឿយណាយធុញទ្រាន់ដោយអាស្រ័យហេតុលើកយកព្រះសាស្តាមកប្រៀបធៀប ហើយនឹងកើតសទ្ធាជ្រះថ្លាចំពោះព្រះអង្គ មានយល់ឃើញតាមហេតុពិត អាចនឹងឲ្យបានសម្រេចគុណធម៌តាមសមគួរដល់សេចក្តីប្រតិបត្តិរបស់ខ្លួន ។

៨១– សំ. ហេតុអ្វីបានជាព្រះសាស្តាមិនស្រវឹងវង្វេងក្នុងកាមសុខនោះត្រឡប់ជានឿយណាយធុញទ្រាន់ទៅវិញ ?

ប ធម្មតាកាមសុខជារបស់ដែលមហាជនត្រូវតែស្រឡាញ់ចង់បានគ្រប់គ្នា ៗ មានបណ្តាជនជាច្រើនដែលនៅជាបុថុជ្ជនតែងសរសើរថាកាមសុខជារបស់ល្អ គួរឲ្យចង់បាន ។ ប៉ុន្តែចំណែកលោកអ្នកមានបញ្ញាត្រិះរិះពិចារណាទៅហើយ ក៏បានឃើញតាមសេចក្តីកើតពិតរបស់ធម្មតាចៀសមិនផុតពីធម្មតា ។ បន្តិះបំកំណត់ទុកស្រេចមកហើយថា សភាវៈតាំង

ពួនរមែងមានជាគូ ៗ គ្នា ដូចមានក្តៅហើយត្រូវមានត្រជាក់ជាគ្រឿងរែក ជាដើម ។ ព្រោះហេតុនោះ កាលបើទីណាមានសុខ ទីនោះរមែងមានទុក្ខនៅលាយឡំផង នេះឯងជាធម្មតាកំណត់ទុកមក ។ ហេតុដូច្នេះ ការដែលនឹងបានដឹងអ្វីជាទុក្ខ ក៏ត្រូវអាស្រ័យបានទទួលសេចក្តីសុខយ៉ាងពេញលេញរួចពីមុនមកហើយ ។ ក៏កាលព្រះមហាបុរសលោកនឹងបានជ្រាបថា កាមសុខជាទុក្ខ ក៏ព្រោះតែព្រះអង្គធ្លាប់សោយកាមសុខបរិបូណ៌រួចមកហើយតាំងពីក្នុងវាំងដែលព្រះអង្គនៅក្នុងឃរាវាសសម្បត្តិនោះ ពួកព្រះញាតិវង្សទាំងឡាយ មានសេចក្តីខ្វល់ខ្វាយជួយអភិបាលរក្សា នឹងយាងទៅទីណា ក៏មានស្វេតច្ឆត្រផ្ទាំងដើម្បីនឹងការពារនូវសម្ផស្សផ្សេង ៗ មានតាំងប្រាសាទ ៣ ខ្នង ជាទីគង់នៅដ៏សមគួរផ្តល់សេចក្តីសប្បាយក្នុងរដូវទាំង ៣ ។ កាលព្រះអង្គមានព្រះជន្មល្មមនឹងមានព្រះជាយាបានហើយ ព្រះវរបិតាក៏បញ្ជូនទូតឲ្យទៅសូមព្រះនាងពិម្ពា ដែលជាព្រះរាជធីតានៃព្រះបាទក្រុងទេវទហៈ មកផ្សំផ្គុំឲ្យជាព្រះជាយាដរាបដល់បានបង្កើតបុត្រ ១ អង្គ ហៅថា រាហុល ។ ព្រះមហាបុរសបានសោយកាមសុខបរិបូណ៌មកដូច្នេះហើយ ទើបព្រះអង្គបានជ្រាប តាមសេចក្តីកើតពិតរបស់ធម្មតាថា មានទុក្ខនៅប្រឡូកប្រឡំ ទើបធ្វើឲ្យព្រះអង្គនឿយណាយក្នុងកាមសុខ ។

៨២ - ស. ព្រះមហាបុរសទ្រង់ឃើញអ្វី ទើបស្តេចចេញទ្រង់ព្រះផ្នួស ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ព្រះអង្គបានឃើញទេវទូតទាំង ៤ គឺមនុស្សចាស់ ១, មនុស្សឈឺ ១, មនុស្សស្លាប់ ១, ភេទអ្នកបួស ១ ។

៨៣–ស. ព្រះអង្គឃើញទេវទូតទាំង ៤ នោះ នៅទីណា? អ្នកណាមកនិម្មិតថ្វាយ? ឃើញតែម្ដងគ្រប់ទាំង ៤ ឬដូចម្ដេច?

ឆ. ព្រះអង្គឃើញនៅក្នុងឧទ្យាន ។ សុទ្ធាវាសទេវតាមកនិម្មិតថ្វាយ ។ មិនមែនឃើញម្ដងគ្រប់ទេវទូតទាំង ៤ នោះទេ គឺក្នុងពេល ៤ ខែ ។ ទើបឃើញទេវទូតមួយៗ ។

៨៤– ស. ចុះទេវទូតប៉ុន្មានជាហេតុឲ្យព្រះអង្គនឿយណាយចាកកាមសុខ? ប៉ុន្មានជាហេតុឲ្យព្រះអង្គជ្រះថ្លាក្នុងការចេញទ្រង់ព្រះផ្នួស?

ឆ. ទេវទូត ៣ ខាងដើម គឺមនុស្សចាស់, ឈឺ និង ស្លាប់ ជាហេតុឲ្យព្រះអង្គនឿយណាយចាកកាមសុខ ។ ទេវទូតទី ៤ គឺភេទអ្នកបួស ជាហេតុឲ្យព្រះអង្គជ្រះថ្លាក្នុងការចេញទ្រង់ព្រះផ្នួស ។

៨៥–ស. ព្រះអង្គចេញទ្រង់ព្រះផ្នួសក្នុងព្រះជន្មប៉ុន្មាន? នៅថ្ងៃ-ខែ-ឆ្នាំអ្វី? ពេលវេលាណា?

ឆ. ក្នុងព្រះជន្មគម្រប់ ២៩ ឆ្នាំ ។ នៅថ្ងៃព្រហស្បតិ៍, ពេញបូណ៌មី ខែអាសាឍ, ឆ្នាំថោះ ។ វេលាអធ្រាត្រ ។

៨៦–ស. កាលព្រះអង្គចេញទ្រង់ព្រះផ្នួសនោះ ព្រះរាហុលកុមារប្រសូតហើយឬនៅ?

www.budinst.gov.kh www.elibraryofcambodia.org

ច. ព្រះរាហុលកុមារប្រសូតក្នុងថ្ងៃដែលព្រះមហាបុរសចេញទ្រង់ព្រះផ្នួសនោះឯង គឺក្នុងពេលដែលព្រះអង្គនៅក្រសាលក្នុងឧទ្យាន ព្រះរាហុលកុមារប្រសូតក្នុងថ្ងៃនោះ លុះដល់ពាក់កណ្ដាលអធ្រាត្រទើប ព្រះអង្គចេញទ្រង់ព្រះផ្នួស ។

៨៧-ស. ចុះព្រះមហាបុរសគង់អ្វីចេញទៅទ្រង់ព្រះផ្នួស ? មានអ្នកណាតាមហែទៅផងដែរឬទេ ?

ច. ព្រះអង្គគង់សេះកណ្ឋកៈមានជន្ទួនប្រមាណ ១៨ ហត្ថ ។ មាននាយឆន្នអាមាត្យតោងកន្ទុយសេះតាមហែទៅផង ។

៨៨-ស. កាលព្រះមហាបុរសចេញផុតពីនគរទៅ បានជួបប្រទះនឹងអ្នកណាដែរឬ ? អ្នកនោះមកនិយាយថាម៉េច ?

ច. ព្រះអង្គបានជួបនឹងទេវបុត្តមារចុះពីទេវលោកមកស្ថិតនៅក្នុងអាកាស, មកនិយាយហាត់ព្រះអង្គថា "នែសិទ្ធត្ថ! អ្នកកុំចេញទៅបួសឡើយ, នៅតែ ៧ ថ្ងៃទៀតទេ សម្បត្តិចក្រពត្តិនឹងមកដល់អ្នកហើយ" ។ ព្រះអង្គឆ្លើយថា "យើងដឹងហើយ យើងមិនអាល័យទេ" ។ មារព្ហួយខ្ញោះចៀសចេញបាត់ទៅ ។

៨៩-ស. ចុះព្រះអង្គយាងទៅក្នុងរាត្រីនោះ កន្លងនគរប៉ុន្មាន ? ឈ្មោះអ្វីខ្លះ ? ចម្ងាយផ្លូវប៉ុន្មាន ? ទៅគង់នៅទីកន្លែងណា ?

www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

ឫ. កន្លងនគរ ៣ គឺនគរកបិលពស្តុ ១, សាវត្ថី ១, វេសាលី ១; អស់រយៈផ្លូវចម្ងាយ ៣០ យោជន៍ ៗ ទៅគង់នៅឆ្នេរស្ទឹងអនោមាខាងត្រើយនាយ ។

៩០– ស. សេះកណ្ឋកៈស្លាប់ហើយទៅកើតនៅទីណា ? ឈ្មោះអ្វី?

ឫ. ទៅកើតក្នុងទេវលោកជាន់តាវត្តិង្ស ។ ឈ្មោះកណ្ឋកៈទេវបុត្រ ។

៩១– ស. ចុះព្រះមហាបុរសទ្រង់បព្វជ្ជាដោយអាការដូចម្ដេច ?

ឫ. កាលព្រះអង្គប្រគល់សេះនិងគ្រឿងប្រដាប់ឲ្យនាយឆន្នអាមាត្យនាំទៅនគរវិញហើយ ទ្រង់គង់នៅលើផ្ទៃខ្សាច់ស ១ ព្រះអង្គឯងទ្រង់ព្រាថ្នានឹងកាត់ព្រះកេសា ។ គ្រានោះ ព្រះខាន់ទិព្វធ្លាក់មកថ្វាយ ។ ព្រះអង្គកាត់ព្រះកេសាទុកឲ្យសល់ប្រវែងពីរធ្នាប់វិលជាទក្ខិណាវដ្ត រួចទ្រង់អធិដ្ឋានមោលីហើយបោះទៅក្នុងអាកាស ។ ព្រះឥន្ទ្រយកប្រអប់កែវមកទទួលយកទៅបញ្ចុះទុកក្នុងចូឡាមណីចេតិយនៅស្ថានតាវត្តិង្ស ។

៩២– ស. ចុះព្រះមហាបុរសបានគ្រឿងបរិក្ខារសម្រាប់អ្នកបួសមកពីណា ? បរិក្ខារនោះមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

ឫ. ព្រះអង្គបានអំពីឃដិការមហាព្រហ្ម នាំយកមកថ្វាយ ។ បរិក្ខារនោះមាន ៨ យ៉ាងគឺ៖ ស្បង់ ១, ចីពរ ១, សង្ឃាដី ១, បាត្រ ១, កាំបិតកោរ ១, បំពង់ម្ជុល ១, វត្ថពន្ធចង្កេះ ១, ជម្រងទឹក ១ ។

www.budinst.gov.kh www.elibraryofcambodia.org

៩៣-ស. ចុះព្រះពស្ត្រទាំង ១ គូដែលព្រះអង្គធ្លាប់ទ្រង់កាលនៅជាឃរាវាសនោះ តើទៅឯណាទៅ ?

ឆ. មហាព្រហ្មយកទៅបញ្ចុះ ក្នុងទុស្សចេតិយ កំពស់ ១២ យោជន៍ក្នុងព្រហ្មលោក ។

៩៤-ស. ព្រះមហាបុរសបានសិក្សាចេះដឹងក្នុងយុទ្ធវិធីសមគួរដល់ជាតិក្សត្រហើយ គួរតែទ្រង់ត្រេកអរក្នុងរាជសម្បត្តិ ហេតុអ្វីទើបចាប់ព្រះទ័យក្នុងការទ្រង់ព្រះផ្នួសវិញ ?

ឆ. ហេតុតែព្រះអង្គមានព្រះករុណាក្នុងមហាជនជាយ៉ាងធំ ទើបផ្លាស់ប្ដូរសេចក្ដីប្រព្រឹត្តិរបស់ព្រះអង្គ ដើម្បីនឹងធ្វើប្រយោជន៍ដល់មហាជនបានពេញទី ហើយបានឆ្ងាយទូលាយផង ។

៩៥-ស. ត្រង់រឿងថា: ព្រះមហាបុរសឃើញផ្ទៃប្រាសាទដ៏ចង្អៀត វិការនានាកាន់តែដោយបរិវារស្ត្រីដូចព្រៃសុសាននោះ តើមានអធិប្បាយដូចម្ដេច ?

ឆ. មានអធិប្បាយថា: ព្រះអង្គទ្រង់ឃើញលោកយល់ភាពនៃក្សត្រជាអ្នកសម្បូណ៌ដោយកាមគុណ រមែងស្រវឹងស្រពោនក្នុងកាមគុណ នៅជាមួយតែនឹងស្ត្រី មិនចុះចេញពីប្រាសាទ ដែលគេឃើញថាជាសុខ ប៉ុន្តែធ្វើជីវិតឲ្យផលទំនើបកើតឡើងមិនជាទីគាប់ព្រះទ័យ ហាក់ដូចជា

www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងព្រៃផុតភ្នែកនឹងនៅផ្លូវណា ក៏ចេះតែជួបប្រទះ នឹងរបស់ដែលជាទី
តាំងនៃសេចក្ដីសង្វេគ ទាំងអស់ ។

៥៦-សួ. បើមានគេនិយាយថា ការណ៍ដែលព្រះមហាបុរសស្ដេច
ចេញបព្វជ្ជា ព្រោះតែចង្អៀតចង្អល់ព្រះទ័យដោយហេតុព្រះនាងប្រជាបតិ
គោតមីជាព្រះមាតុច្ឆាទុកកូនប្រៀតបៀននឹងឱ្យរាជសម្បត្តិដល់ព្រះនន្ទកុមារ
ជាព្រះឱរស, តើរឿងនេះមានគោលនៃសេចក្ដីពិតដូច្នោះឬទេ? ចូរឆ្លើយមក

ឆ. រឿងនេះគ្មានគោលនៃសេចក្ដីពិតដែលគួរស្ដាប់បានទេ ។
តាមព្រះចរិយាដែលមានប្រាកដក្នុងប្រវត្តិនៃព្រះមហាបុរសនោះថា: កាល
ព្រះអង្គនៅជាយុវរាជ ទ្រង់បរិបូណ៌ដោយគុណសម្បត្តិជាទីគាប់ប្រាស់ដល់
ប្រជាជន ។ ព្រះញាតិទាំងឡាយប្រាថ្នានឹងយកព្រះអង្គជាទីពឹង ដោយ
ហេតុបានស្ដាប់ពាក្យព្យាករណ៍នៃកាឡទេវិលតាបស បានព្រមព្រះទ័យគ្នា
ថ្វាយព្រះអង្គថ្វាយព្រះកុមារឱ្យជាបរិវារខ្លះ ជួយធ្វើកិច្ចធុរៈដទៃទៀតខ្លះ ៗ
ចំណែកព្រះមាតុច្ឆាក៏ទទួលនាទីជាអ្នកថែរក្សាព្រះអង្គ ។ ព្រះបិតាក៏ទ្រង់
បង្ហាត់ដោយប្រការផ្សេង ៗ ដើម្បីឱ្យព្រះអង្គត្រេកត្រអាលនៅក្នុងកាម-
សុខ ព្រោះត្រូវការឱ្យសោយរាជ្យជាស្ដេចចក្រពត្តិ ដែលជាហេតុឱ្យ
ព្រះអង្គស្ដេចចេញបព្វជ្ជាបានដោយលំបាកដូចមានដំណាលក្នុងពុទ្ធប្រវត្តិ
ស្រាប់ហើយ ។ មួយទៀត កាលព្រះបាទសុទ្ធោទនៈទិវង្គតហើយ ព្រះ
នាងបានទៅទូលសូមបព្វជ្ជាជាភិក្ខុនីក្នុងសំណាក់ព្រះអង្គផង ។ រឿងនេះ

www.budinst.gov.kh www.elibraryofcambodia.org

បន្ទូលឲ្យឃើញថា ព្រះនាងមានព្រះទ័យស្រឡាញ់ព្រះអង្គតាំងពីដើមមកមែន ។ ។ ហេតុផលទាំងឡាយដូចបានបរិយាយមកនេះ នាំឲ្យសន្និដ្ឋានបានថា ព្រះអង្គស្តេចចេញបព្វជ្ជាដោយទ្រង់ប្រាថ្នាស្វែងរកមោក្ខធម៌មិនមែនចេញទៅដោយសេចក្តីចង្អៀតចង្អល់ទាល់ព្រះរាជហឫទ័យទេ ។

៩៧–សួ. កាលព្រះមហាបុរសចេញបព្វជ្ជានោះ មិនមានអ្នកណាហាមឃាត់ទេឬ ?

ឆ. មិនមានអ្នកណាហាមឃាត់ទេ ព្រោះព្រះញាតិទាំងឡាយមានព្រះបិតាជាដើម មានព្រះទ័យស្រឡាញ់ព្រះអង្គណាស់ចង់ឲ្យតែព្រះអង្គនៅគ្រប់គ្រងរាជសម្បត្តិ ព្រោះព្រះអង្គក៏ជារជ្ជទាយាទសមគួរនឹងបានសោយរាជ្យស្នងព្រះបិតាតទៅ, ការចង់ឲ្យនៅគ្រប់គ្រងរាជសម្បត្តិទាំងនេះជាងការព្រមឲ្យព្រះអង្គចេញទ្រង់ព្រះផ្នួសចាប់តាំងពីថ្ងៃដែលកាឡទេវិលតាបសបានទាយថា "ព្រះមហាបុរសមានគតិតែមួយយ៉ាង គឺប្រាកដជានឹងចេញបួសហើយបានជាសាស្តាឯកក្នុងលោក ព្រោះព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈត្រូវតាមតម្រាព្រាហ្មណ៍" ។ ប៉ុន្តែកាលព្រះអង្គនឹងចេញទ្រង់ព្រះផ្នួសនោះ ពួកព្រះញាតិទាំងឡាយមានព្រះបិតាជាដើមស្មានថាជាការចេញបួសដើម្បីបំពេញវត្តមួយជំនួយកាល តាមសាសនាព្រាហ្មណ៍ប៉ុណ្ណោះ បានជាព្រមបណ្តោយឲ្យចេញបួសតាមប្រាថ្នាមិនហាមឃាត់ ទាំង

www.budinst.gov.kh www.elibraryofcambodia.org

ដើម្បីថ្វាយព្រះទ័យនៃព្រះអង្គផង លុះកាលព្រះអង្គចេញទៅបួសហើយ មិនបានត្រឡប់មកវិញ បេះតែបាត់សូន្យឈឹងទៅ ៗ ពួកព្រះញាតិមិនដឹងគិតធ្វើម្ដេច ៗ ថែមទាំងព្រះអង្គកាត់ព្រះមោលីចេញទៀត ដើម្បីនឹងឲ្យព្រះញាតិលែងចង់ឲ្យព្រះអង្គត្រឡប់មកវិញ ។ ព្រោះមនុស្សក្នុងសម័យនោះប្រកាន់ថា ការកោរសក់ជាការអប្រិយចង្រៃ ៗ ព្រោះហេតុនេះឯងទើបធ្វើឲ្យព្រះអង្គចេញបួសបានដោយងាយ ឥតមានអ្នករាំងឃាត់ ៗ

៩៨– ស. ហេតុអ្វីបានជាព្រះមហាបុរសមិនស្វែងរកមោក្ខធម៌ក្នុងឃរាវាសវិស័យវិញ ?

ប. ហេតុតែឃរាវាសជាទីចង្អៀតចង្អល់ណាស់ ជាទីតាំងនៃអារម្មណ៍ធ្វើចិត្តឲ្យសៅហ្មងដោយសេចក្តីស្រឡាញ់ - ស្អប់និងការរង្កើន ដូចជាផ្លូវសម្រាប់ឲ្យធូលីហុយចូលមក បានជាព្រះអង្គមិនស្វែងរកមោក្ខធម៌ក្នុងឃរាវាសវិស័យ ។

៩៩– ស. ព្រះមហាបុរសបានរៀនសូត្រចេះដឹងសមគួរដល់វង្សត្រកូលនៃព្រះអង្គហើយ គួរណាស់តែព្រះអង្គជាប់ព្រះទ័យត្រេកអរក្នុងឃរាវាសគ្រប់គ្រងរាជាណាចក្រមែនឬទេ ? ប៉ុន្តែហេតុអ្វីក៏សព្វព្រះទ័យក្នុងការចេញទ្រង់ព្រះផ្នួសជាសមណៈទៅវិញ ?

ប. ព្រះអង្គបានរៀនសូត្រចេះដឹងជ្រៅជ្រះមែនហើយ ដូចជាកាលទ្រង់សំដែងឲ្យប្រាកដក្នុងពួកព្រះញាតិ ព្រមទាំងទ្រង់សំដែងធម៌ទេសនា

ជាប់ចាក់ចិត្តដោយការសិក្សារបស់ឃរាវាសក៏មាន ។ ប៉ុន្តែព្រោះហេតុព្រះអង្គមានព្រះទ័យពេញទៅដោយព្រះករុណាដូចអន្លង់ទឹកដ៏ធំ ទើបចេញទ្រង់ផ្នួសប្រកាសសាសនាតាំងក្នុងអាណាចក្រនឹងក្រៅអាណាចក្រ ទ្រង់ប្រាថ្នាប្រយោជន៍ដ៏ធំទូលាយយ៉ាងខ្ពង់ខ្ពស់បំផុតឲ្យមានផលវែងឆ្ងាយជិតរទូ-ទៅគ្រប់កាលជាយូរអង្វែងដែលអ្នកនៅគ្រប់គ្រងផ្ទះ សូម្បីជាស្តេចចក្រក៏មិនអាចនឹងបំពេញឲ្យស្មើបាន ហេតុនេះ ទើបព្រះអង្គសព្វព្រះទ័យក្នុងការទ្រង់ព្រះផ្នួស ។

១០០– សំ. ព្រះមហាបុរសទ្រង់ប្រារព្ធហេតុអ្វីទើបស្តេចចេញបព្វជ្ជា ?

ឆ. តាមបាលីមជ្ឈិមនិកាយសំដែងថា ទ្រង់ប្រារព្ធជរា=សេចក្តីចាស់, ព្យាធិ = ការឈឺ, មរណៈ = សេចក្តីស្លាប់ ជាដើមហេតុ ។

១០១– សំ. គ្រង់ពាក្យថា ព្រោះព្រះមហាបុរសទ្រង់ប្រារព្ធផល់ជរា ព្យាធិ មរណៈ ដែលធ្លាប់ជួបធ្លាប់ឃើញមកដោយប្រក្រតីអំពីមុនមកនោះឯង ជាហេតុឲ្យស្តេចចេញបព្វជ្ជា ; បើប្រកាន់យកសេចក្តីតាមពាក្យខាងលើនោះឃើញថាខុសគ្នានឹងពាក្យដែលថា កាលព្រះអង្គនៅជាឃរាវាសមិនដែលបានឃើញមនុស្សចាស់, ឈឺ, ស្លាប់នោះ ព្រោះព្រះបិតាប្រយ័ត្នការពារមិនឲ្យព្រះអង្គឃើញ បើដូច្នេះតើយើងនឹងសន្និដ្ឋានថាដូចម្តេច ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ខុសគ្នាមែន, សន្និដ្ឋានថា ព្រះមហាបុរសមានព្រះជន្មដល់ទៅ ២៩ ឆ្នាំហើយ, ក្នុងរយៈវេលាប៉ុណ្ណោះគង់តែធ្លាប់ឃើញព្រះញាតិវង្សចាស់ៗ ជរាខ្លះ ប្រឈួនខ្លះនឹងអស់ព្រះជន្មខ្លះមិនខាន សូម្បីព្រះបិតាក៏គង់ព្រះជរាជរាល់ថ្ងៃ ដែលព្រះអង្គត្រូវតែជ្រាប ។ ឯការឈឺចាប់នោះព្រះអង្គឯងផ្ទាល់ក៏គង់មានព្រះរោគកើតឡើងដែរ ដែលជាហេតុឲ្យទ្រង់ជ្រាបថាការឈឺចាប់នោះជាយ៉ាងណា ហេតុនោះពាក្យដែលថា ព្រះអង្គមិនធ្លាប់ឃើញមនុស្សចាស់ឈឺស្លាប់សោះនោះ ជាពាក្យខុស ។

១០២- សួ. បើសន្និដ្ឋានថា ព្រះមហាបុរសធ្លាប់បានឃើញមនុស្សចាស់, ឈឺ, ស្លាប់មកហើយ, ត្រង់រឿងដែលព្រះអង្គត្រាស់ឬជាក្នុងព្រះធម្មចក្រនៅវេលាត្រាស់ដឹងហើយថា «តថាគត បានកើតដឹងឃើញឡើងក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ស្ដាប់មកហើយក្នុងកាលមុនជានេះទុក្ខ», ឯទុក្ខនោះគឺជាតិ ជរា ព្យាធិ មរណៈ ជាដើមនុ៎ះ បើដូច្នេះតើនឹងឆ្លើយដូចម្ដេច ?

ឆ. ជាតិ ជរា ព្យាធិ មរណៈ ដែលព្រះអង្គធ្លាប់បានឃើញមកហើយនោះគ្រាន់តែត្រឹមថ្នាក់សន្មតិ មិនមែនជាថ្នាក់បរមត្ថទេ ។ ចំណែកដែលទ្រង់ប្ដេជ្ញាក្នុងព្រះធម្មចក្រទេសនានោះ ជាសេចក្ដីដឹងឃើញថ្នាក់បរមត្ថដោយព្រះវិចារណញ្ញាណដ៏ល្អិតសុខុម ។ មុនដំបូងទ្រង់

www.budinst.gov.kh www.elibraryofcambodia.org

ឃើញថាជាតិ គឺជាសេចក្តីប្រាកដនៃបញ្ចក្ខន្ធ, ជរាគឺសេចក្តីប្រែប្រួលនៃបញ្ចក្ខន្ធ, មរណៈ គឺសេចក្តីបែកធ្លាយនៃបញ្ចក្ខន្ធ ដែលជាជាន់សេចក្តីដឹងឃើញក្នុងផ្លូវពោធិញាណ ។ ពាក្យដែលថាឃើញទុក្ខ គឺឃើញទុក្ខយ៉ាងល្អិត ដែលកាលពីដើមព្រះអង្គមិនធ្លាប់បានឃើញថាជាទុក្ខសោះឡើយ ។

១០៣ សំ. ព្រះមហាបុរសចេញទ្រង់ព្រះផ្នួសដោយការលបរត់ទៅឬមួយដោយការទូលលាព្រះបិតា ? ចូរឆ្លើយដោយមានគោលដាំសំអាងមកផង !

ឆ. រឿងដែលចេញបព្វជ្ជានេះ លោកអាចារ្យអ្នកតែងអដ្ឋកថាសំដែងថា ព្រះអង្គរត់ចេញទៅក្នុងវេលាអធ្រាត្រគង់សេះកណ្ឋកៈ មាននាយឆន្នអាមាត្យតាមហែទៅផង ។ ចំណែកលោកអាចារ្យអ្នករចនាព្រះបាលីសំដែងថា បានលាព្រះបិតាមាតាតែទ្រង់មិនអនុញ្ញាត, ក្នុងសម័យខាងក្រោយមកព្រះមហាបុរសទ្រង់ឈ្លៀងយល់ថា ព្រោះតែគាត្អូនញូនៅក្មេងមានសក់ខ្មៅស្និទ្ធស្និតនៅក្នុងបឋមវ័យ បានជាព្រះបិតាមាតាមានព្រះភ័ក្ត្រទទឹកជោកដោយទឹកព្រះនេត្រទ្រង់ព្រះកន្សែងមិនអនុញ្ញាត ឃាត់ហាមមិនឲ្យចេញបព្វជ្ជា ដូច្នេះទើបព្រះអង្គកោរព្រះកេសានិងព្រះមស្សុហើយទ្រង់គ្រងសំពត់កាសាយៈដល់នូវភាវៈជាបព្វជិត នៅចំពោះព្រះភ័ក្ត្រ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះមាតាបិតា ហើយមានលាស្តេចចេញទៅតាំងព្យាយាមក្នុងឧរុវេលា-សេនានិគម ។

១០៤– ស. កាលព្រះមហាបុរសស្តេចចេញបព្វជ្ជា តាមរឿងក៏លោកពោលថាបានសំពត់កាសាយៈមកអំពីណា ? រឿងនោះនឹងសន្និដ្ឋានថាម៉េច ?

ប. លោកពោលថា ឃដិការព្រហ្មនាំមកថ្វាយ ។ សន្និដ្ឋានថា ត្រូវតែបានមកអំពីសំណាក់បព្វជិតអ្នកបានសមាបត្តិ ព្រោះសមាបត្តិជាហេតុនៃការកើតជាព្រហ្ម, ដែលថាបានមកអំពីឃដិការព្រហ្មក៏គឺបានមកអំពីបព្វជិតអ្នកបានសមាបត្តិនោះ ។

## ព្រះសាស្តាធ្វើទុក្ករកិរិយា

១០៥– ស. កាលព្រះមហាបុរសបព្វជ្ជាហើយ បានចូលទៅសិក្សាក្នុងសំណាក់អ្នកណា ? បានរៀនដឹងដូចម្តេច ? ហេតុអ្វីបានជាថាព្រះអង្គត្រាស់ដឹងឯង ?

ប. កាលព្រះអង្គបព្វជ្ជាហើយ បានចូលទៅសិក្សាក្នុងសំណាក់អាឡារតាបសកាលាមគោត្រ និងឧទកតាបសរាមបុត្រ, បានរៀនដឹងក្នុងរូបឈានទាំង ៤ និងអរូបឈាន ៤ ចំណេះដែលបានរៀនដឹងក្នុងសំណាក់តាបស ទាំងពីរនោះគ្រាន់តែត្រឹមលោកិយធម៌ ។ ចំណេះដែលត្រាស់ដឹង

www.budinst.gov.kh www.elibraryofcambodia.org

ថ្មីនោះ គឺអរិយសច្ចៈ ៤ ជាលោកុត្តរធម៌ ហេតុនោះបានជាថាត្រាស់ដឹងដោយគំនិតព្រះអង្គឯង ។

១០៦-សំ. ទុក្ករកិរិយាបានសេចក្ដីថាម៉េច ? ហេតុអ្វីបានជាព្រះមហាបុរសធ្វើ ? ឬព្រះអង្គយល់ខុសទេ ?

ឆ. ទុក្ករកិរិយានោះបានសេចក្ដីយ៉ាងខ្លីថា "ការបំពេញអត្តកិលមថានុយោគ" គឺការព្យាយាមធ្វើខ្លួនឲ្យលំបាកវេទនា ។ ដែលមិនមែនជាផ្លូវឲ្យបានសម្រេចមគ្គផល (មានច្បាស់នៅក្នុងពុទ្ធប្រវត្តិស្រាប់ហើយ) ។ បានជាព្រះអង្គធ្វើទុក្ករកិរិយានោះ ដោយហេតុទ្រង់ស្មានយល់ថាទុក្ករកិរិយានេះជាផ្លូវនៃសេចក្ដីត្រាស់ដឹងបានខ្លះ, មួយទៀតព្រោះក្នុងយុគនោះ ពួកអ្នកប្រព្រឹត្តវត្តប្រកាន់ការបំពេញទុក្ករកិរិយាថាជាវត្តយ៉ាងសំខាន់បំផុត ដែលជាហេតុឲ្យព្រះអង្គត្រូវប្រព្រឹត្តល្បងមើលហើយ ឲ្យលើសគេទៅទៀត ។ មិនមែនទ្រង់យល់ខុសទេ ។

១០៧-សំ. កាលព្រះមហាបុរសចេញបព្វជ្ជាហើយ មុនត្រាស់ដឹង ព្រះអង្គបានយាងទៅកាន់ដែនសក្កជនបទវិញខ្លះទេ ? ដឹងដោយអ្វីបានជាឆ្លើយយ៉ាងនោះ ?

ឆ. ព្រះអង្គបានយាងទៅដែរ ។ ដឹងដោយសារឃើញក្នុងពុទ្ធប្រវត្តិដំណាលថា ព្រះអង្គបានយាងទៅសិក្សាលទ្ធិក្នុងសំណាក់អាឡារ-

www.budinst.gov.kh www.elibraryofcambodia.org

តាបស និងឧទកតាបសដែលជាគណាចារ្យធំ មានទីលំនៅ ១ កន្លែង សក្កជនបទ ។

១០៨_សំ. ព្រះមហាបុរសធ្វើទុក្ករកិរិយាក្នុងកន្លែងណា ? មានអ្នកណាខ្លះដឹងឮឃើញជាប់ផ្ទាល់ថាបានធ្វើមែន ? ចូរឆ្លើយដោយមានការឲ្យសព្វគ្រប់ !

ឆ្លើយ. ព្រះអង្គធ្វើនៅតំបន់ឧរុវេលាសេនានិគម ដែនមគធជនបទ ។ មានអ្នកដឹងឃើញច្រើនជាង ៥ នាក់ឡើងទៅ ប៉ុន្តែអ្នកដែលបាននៅជាមួយ ៥ នាក់គឺព្រះកោណ្ឌញ្ញៈ១, ព្រះវប្បៈ១, ព្រះភទ្ទិយៈ១, ព្រះមហានាម១, ព្រះអស្សជិ ១ ក្រៅពីនេះមានពួកអ្នកស្រុកដែលមកនិយាយសរសើរព្រះវីរិយនៃព្រះអង្គផងទៀត ។

១០៩_សំ. គំនិតឬកិច្ចការអ្វីដែលភ្លាត់ខុសទៅហើយ ជារបស់គួរបិទបាំង មិនគួរបញ្ចេញឲ្យគេឯងដឹងឮមែនឬទេ ? ការដែលព្រះអង្គធ្វើទុក្ករកិរិយានោះជាអំពើភ្លាត់ខុសទៅហើយ ហេតុម្តេចបានជាព្រះអង្គលើកយកមកសំដែងប្រាប់ឲ្យគេដឹងឮក្នុងវេលាសំដែងបឋមទេសនា ដោយហេតុព្រះអង្គយល់ឃើញថាជាព្រះកិត្តិយសឬអ្វី ?

ឆ្លើយ. មិនមែនព្រះអង្គយល់ឃើញថាជាព្រះកិត្តិយសទេ, ទ្រង់យល់ឃើញថាជាប្រយោជន៍ក្នុងការទេសនា ដើម្បីនឹងពន្យល់ឲ្យឃើញថាការធ្វើដូច្នោះ ជាអត្តកិលមថានុយោគមិនមែនជាផ្លូវត្រូវទេ ដោយសារថា

ព្រះអង្គឆាប់ល្បងមើលដឹងរសជាតិមករហើយឥតបានផលប្រយោជន៍អ្វីសោះ ។ មួយទៀតដើម្បីពន្យល់ព្រះបញ្ចវគ្គិយភិក្ខុឲ្យឃើញច្បាស់ថា ការធ្វើទុក្ករកិរិយានោះជាទោសទេ ត្រូវលះបង់ការប្រកាន់ដូច្នោះចេញ ។

១១០–សំ. ព្រះមហាបុរសប្រាថ្នាប្រយោជន៍ដូចម្ដេច បានជាទ្រង់បំពេញទុក្ករកិរិយា ? ចុះការណ៍ដែលព្រះអង្គធ្វើទុក្ករកិរិយាហើយបែរជាលះបង់ចោលទៅវិញ មិនគឺព្រះអង្គយល់ឃើញថាទ្រង់ធ្វើខុសមែនឬទេ ? បើដូច្នោះ មិនខុសគ្នានឹងពាក្យដែលថាព្រះអង្គមានបញ្ញាលើសសាមញ្ញជនទៅហើយឬ ?

ឆ. ព្រះអង្គប្រាថ្នាប្រយោជន៍ដើម្បីនឹងតាមបរក់ចិត្តកុំឲ្យបង្អោនទៅក្នុងកាមារម្មណ៍ ។ ការណ៍ដែលព្រះអង្គលែងធ្វើទុក្ករកិរិយាទៅវិញនោះព្រោះទ្រង់យល់ឃើញថាជាផ្លូវខុសមែន ប៉ុន្តែមិនខុសពីពាក្យថាព្រះអង្គមានបញ្ញាលើសសាមញ្ញជនទេ ព្រោះព្រះអង្គមិនវង្វេងដូចមនុស្សទាំងឡាយដទៃដែលយល់ឃើញថាជាបុណ្យកុសលដោយជាប់ខាត ឯព្រះអង្គត្រិះរិះយល់ឃើញថាជាផ្លូវខុសហើយ ទើបលះបង់ចេញ ហេតុនោះ ទើបត្រូវឲ្យបសរសើរថាមានបញ្ញាយ៉ាងជ្រាលជ្រៅទៅវិញ ។

១១១–សំ. ចូរគិតមើល ! បើព្រះសាស្ដាត្រាស់ដឹងបានឆាប់ៗ មិនបាច់ធ្វើទុក្ករកិរិយា ទាំងដែលទ្រង់ធ្វើទុក្ករកិរិយាដូច្នោះ តើវេលាព្រះអង្គបានត្រាស់ដឹងហើយបានផលខុសគ្នាដូចម្ដេចខ្លះ ?

www.budinst.gov.kh www.elibraryofcambodia.org

ឫ- បានផលខុសគ្នាយ៉ាងនេះ ៖ បើព្រះអង្គបានត្រាស់ដឹងដោយមិនបាច់ធ្វើទុក្ករកិរិយាសោះ វេលាយាងទៅសំដែងធម៌ប្រដៅវេនេយ្យសត្វអ្នកប្រកាន់ការប្រតិបត្តិទូន្មានកាយឲ្យលំបាក (ដែលហៅថាអត្តកិលមថានុ-យោគ) បែរមកធ្វើដំណើរឲ្យប្រព្រឹត្តទៅក្នុងផ្លូវត្រូវ (ដែលហៅថាមជ្ឈិមា-បដិបទា)វិញ កម្រនឹងធ្វើឲ្យគេជឿបានឆាប់រហ័ស ព្រោះគេធ្លាប់ជឿការប្រតិបត្តិដ៏ខ្នះខ្នែងជាយូរណាស់មកហើយ សាសនារបស់ព្រះអង្គក៏នឹងមិនផ្សាយទៅបានឆាប់រួសរាន់; ការមិនធ្វើទុក្ករកិរិយាបានផលដូចអធិប្បាយមកហើយនេះ ។ ឯការដែលព្រះអង្គធ្វើទុក្ករកិរិយាចាត់ជាផ្លូវខុសនោះ អាចចង្អុលឲ្យឃើញជាបន្ទាល់មុនហើយទើបបានត្រាស់ដឹងជាខាងក្រោយ ; ការទូន្មានវេនេយ្យសត្វដែលប្រកាន់រឹងរូសជាប់ស្អិតក្នុងការទូន្មានកាយក៏បានងាយស្រួល ព្រោះអាស្រ័យលើកយកព្រះអង្គឯងមកតាំងជាបន្ទាល់ថា ការទូន្មានខ្លួនបែបនេះ មិនមែនជាផ្លូវនៃសេចក្តីត្រាស់ដឹងទេ ព្រះអង្គធ្លាប់បានធ្វើល្បងមើលមកទាល់តែអស់ចិត្តហើយ អ្នកដែលចំព្យាយាមយ៉ាងខ្លាំងក្លាបំផុតមិនហួសពីសេចក្តីព្យាយាមរបស់ព្រះអង្គទៅដែរ ។ ព្រោះហេតុនោះ កាលបើបុគ្គលដែលមានសេចក្តីប្រកាន់រប់អានក្នុងការទូន្មានកាយបានស្តាប់ឪវាទរបស់ព្រះអង្គហើយ ក៏នឹងផ្លាស់ទិដ្ឋិសេចក្តីប្រកាន់មាំនោះចោលបាន ដោយអាស្រ័យលើកយក ព្រះអង្គមកធ្វើជាបន្ទាល់ ។

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះ ត្រូវយល់ថាការណ៍ដែលព្រះអង្គធ្វើទុក្ករកិរិយានោះមិនឥតអំពើទេ គឺជួយឲ្យព្រះអង្គទេសនាប្រដៅមហាជនឲ្យបានយល់ងាយៗ ។

១១២_សួ. ព្រះអង្គគង់បំពេញសមណធម៌នៅកន្លែងណា ? ហេតុអ្វីបានជាព្រះអង្គទ្រង់សព្វព្រះទ័យគង់ក្នុងទីនោះ ?

ឆ្លើ. ទ្រង់គង់នៅតំបន់ឧរុវេលាសេនានិគមក្នុងមគធជនបទ ។ បានជាព្រះអង្គសព្វព្រះទ័យគង់ក្នុងទីនោះ ព្រោះបានទតឃើញថាផ្ទៃផែនដីរាបស្មើឈើនិងស្មៅខៀវស្រស់ ជាទីរីករាយចិត្ត ស្ទឹងហូរមានទឹកថ្លាស្អាត មានកំពង់ស្រួលល្អគួរឲ្យសប្បាយ គោចរគ្រាមគឺស្រុកភូមិជាទីត្រាច់ទៅដើម្បីភិក្ខាក៏តាំងនៅជិតជុំវិញ ជាកន្លែងស្ងាត់ មិនរីករវល់ដោយពួកជនត្រាច់ទៅមក ទ្រង់ព្រះតំរិះឃើញថាប្រទេសនោះគួរជាទីតាំងនៅនៃសេចក្តីព្យាយាមរបស់កុលបុត្រ អ្នកមានសេចក្តីប្រាថ្នានឹងបំពេញព្យាយាមបាន ។

១១៣_សួ. ក្នុងវេលាដែលព្រះអង្គទ្រង់បំពេញទុក្ករកិរិយានោះ លោកជាអស់កាលជាយូរដល់ ៦ ឆ្នាំ, ក្នុងវេលានោះបើព្រះអង្គនឿយណាយព្រះទ័យលះបង់ព្យាយាមហើយយាងចូលមកនគរវិញ ដូច្នេះតើព្រះអង្គនឹងទទួលផលល្អ ឬអាក្រក់យ៉ាងណា ?

www.budinst.gov.kh www.elibraryofcambodia.org

ថ. បើព្រះអង្គលះបង់ទុក្ករកិរិយាចេញហើយត្រឡប់ចូលមកនគរវិញ ក៏គង់មិនបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធអ្នកប្រតិស្ឋានព្រះពុទ្ធ-សាសនាឡើយ ។ ចំណែកគ្រួនយករាសក៏មិនបានទទួលផលវិសេសអ្វីដែរ ព្រោះមនុស្សទាំងឡាយ មើលងាយថាជាអ្នកគ្មានសេចក្តីព្យាយាម ធ្វើអ្វីមិនទៀនទាត់ មិនចប់ចុងដើម; គប្បីឃើញតួយ៉ាងកូនទេវោដែលព្រះអង្គឈប់បំពេញទុក្ករកិរិយា ជាហេតុឲ្យព្រះបញ្ចវគ្គិយ នាំគ្នាសំគាល់ថាព្រះអង្គត្រឡប់ទៅជាអ្នកប្រាថ្នាច្រើនវិញ ហើយមុខជាមិនបានសម្រេចធម៌វិសេសណាមួយទេ ទើបនាំគ្នារត់ចោលលែងបំរើព្រះអង្គ ។

១១៤_ស. ព្រះមហាបុរស បើពោលតាមព្រះពុទ្ធដីកាថាមានព្រះបញ្ញាជ្រាលជ្រៅណាស់ ទ្រង់ជ្រាបហេតុគន់ផ្លូវលោកគួរឲ្យអស្ចារ្យដូច្នេះជាដើម, ចុះដែលព្រះអង្គមានព្រះបញ្ញាច្រើននោះ ព្រោះទ្រង់បានរៀនសូត្រចេះដឹងអំពីបណ្តូបមកហើយឬ ឬក៏លុះបានត្រាស់ដឹងធម៌ពិសេសជាព្រះសព្វញ្ញុតហើយ ទើបទ្រង់ជ្រាបហេតុទាំងអស់បាន?

ថ្ម. ព្រោះព្រះអង្គបានរៀនសូត្រចេះដឹងយ៉ាងធំតាំងពីកុងខត្តិយ-ធម៌និតតិលោកដទៃៗជាច្រើនមកហើយ ដូចមានរឿងដំណាលថាព្រះរាជបិតាបាននាំយកទៅឲ្យរៀនក្នុងសំណាក់គ្រូវិស្វាមិត្រ ដើម្បីឲ្យរៀនអក្សរសម័យនិងសិល្បវិជ្ជា ព្រះអង្គទ្រង់រៀនបានចេះដឹងស្ទាញស្ទាត់ទាល់តែអស់



www.budinst.gov.kh www.elibraryofcambodia.org

ចំណោះរបស់គាថាទេ បានសំដែងឲ្យប្រាកដ ក្នុងពួកព្រះញាតិមិនមានរាជ-កុមារដទៃប្រៀបផ្ទឹមបាន, មួយទៀតមានរឿងប្រាកដក្នុងពុទ្ធចរិយាថា កាលព្រះអង្គបានត្រាស់ជាព្រះសម្មាសម្ពុទ្ធហើយ ទ្រង់ប្រោសសេចក្តីប្រព្រឹត្តទៅ របស់ស្រុកទេស និងការគ្រប់គ្រងយ៉ាងដទៃៗ ព្រះអង្គអាចទាញយកមកសំដែង ជាឧបមាក្នុងព្រះធម៌ដោយអនេកប្រការបាន, លុះត្រាស់ដឹងធម៌វិសេសហើយ ឈ្មោះថាជាការចម្លងព្រះបញ្ញាក្នុងផ្លូវបរមត្ថ ឲ្យរីកកៃចំរើនច្រើនឡើងមួយជាន់ទៀត បានជាព្រះអង្គមានព្រះបញ្ញាញាណយ៉ាងអស្ចារ្យ ។

១១៥– សំ. កាលព្រះមហាបុរសទ្រង់ព្រះផ្នួសហើយ ទ្រង់ស្វែងរកសេចក្តីត្រាស់ដឹងដោយឧបាយយ៉ាងណាខ្លះ ?

ឆ. ព្រះអង្គទ្រង់ព្រះផ្នួសរួចហើយស្តេចចារិកទៅកាន់សំណាក់អាឡារតាបសនិងឧទកតាបសដែលមហាជនរាប់អានថាជាគណាចារ្យធំ សូមសិក្សាលទ្ធិសម័យ ដើម្បីល្បងមើលឲ្យឃើញថាជាឧបាយនឹងឲ្យបានសម្រេចដូចប្រាថ្នាឬទេ ។ កាលទ្រង់សិក្សាអស់ចំណេះគ្រូទាំងពីរនោះហើយ ទ្រង់យល់ឃើញថាមិនមែនជាផ្លូវនៃសម្មាសម្ពោធិញ្ញាណ ទើបទ្រង់ចេញចាកសំណាក់តាបសទាំង ២ នោះយាងទៅទៀត បានទៅដល់ឧរុវេលាប្រទេសជាទីសប្បាយ គួរជាទីតាំងនៃសេចក្តីព្យាយាម ទើប

www.budinst.gov.kh www.elibraryofcambodia.org

គង់ធ្វើសេចក្តីព្យាយាមក្នុងទីនោះ ទូន្មានព្រះកាយបំពេញទុក្ករកិរិយាដើម្បី ហាមឃាត់ចិត្តដោយប្រការផ្សេងៗ មានខាំសង្កត់ព្រះទន្តដោយព្រះទន្ត និងអត់ដង្ហើមនិងអត់អាហារជាដើម បានសោយទុក្ខវេទនាយ៉ាងខ្លាំងក្លា ប៉ុន្តែព្រះទ័យមិនរេរារាយ មានព្រះស្មារតីតាំងមាំមួន ។ កាលទ្រង់យល់ឃើញថាផ្លូវយ៉ាងនេះមិនមែនជាផ្លូវត្រូវ ក៏ទ្រង់ផ្លាស់បោលចេញ ហើយរិះរកផ្លូវថ្មីទៀត មិនរួញរា ក្នុងទីបំផុតទ្រង់ធ្វើព្យាយាមតាមផ្លូវចិត្ត រាប់តាំងពីទ្រង់ព្រះផ្នួសមកបាន ៦ ឆ្នាំ ទើបបានត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណគឺជ្រាបអរិយសច្ច ៤ ដូច្នេះ ។

១១៦- សំ. កាលព្រះមហាបុរសបព្វជ្ជារួចហើយ ទ្រង់គង់ក្នុងទីណា? សោយអាហារដែរឬទេ? បានទទួលពាក្យប្តេជ្ញារបស់អ្នកណាដែរឬ?

ឆ. ទ្រង់គង់ក្នុងអនុបិយម្ពវ័ន ។ មិនសោយអាហារអស់ ៧ ថ្ងៃ, លុះដល់ថ្ងៃទី ៨ ទើបព្រះអង្គយាងទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ។ ព្រះអង្គបានទទួលពាក្យប្តេជ្ញារបស់ព្រះបាទពិម្ពិសារថា បើបានត្រាស់ដឹងហើយ និមន្តទៅប្រោសមុនគេ ។

១១៧- សំ. កាលព្រះមហាបុរសកំពុងធ្វើទុក្ករកិរិយានោះ មានអ្នកណាខ្លះនៅបំរើព្រះអង្គ?

ឆ. មានកូនព្រាហ្មណ៍ ៥ នាក់ ឈ្មោះកោណ្ឌញ្ញៈ ១, ភទ្ទិយៈ ១,

www.budinst.gov.kh www.elibraryofcambodia.org

វប្បៈ១, មហានាម១, អស្សជិ១ ដែលចេញបួសតាមព្រះមហាបុរស ហៅថា បញ្ចវគ្គិយភិក្ខុ បាននៅគាល់បំរើព្រះអង្គ ។

១១៨–សំ. កាលព្រះមហាបុរសជិតនឹងបានត្រាស់ដឹង ទ្រង់សុបិននិមិត្តប៉ុន្មានយ៉ាងគឺអ្វីខ្លះ ?

ឆ. ៥ យ៉ាង គឺទី ១ ទ្រង់ឃើញថាទ្រង់ផ្ទំផ្ងារលើមហាប្រឹថពី ព្រះសិរកើយភ្នំហិមពាន្ត ព្រះបាទាទាំងទ្វេស្ដោកចុះក្នុងមហាសមុទ្រខាងទិសទក្សិណ, ព្រះហស្តខាងឆ្វេងស្ដោកចុះក្នុងមហាសមុទ្រខាងទិសបូព៌, ព្រះហស្តខាងស្ដាំស្ដោកចុះក្នុងមហាសមុទ្រខាងទិសបស្ចិម ។ ទី ២ ទ្រង់ឃើញស្មៅចិញ្ចៀនដុះចេញពីព្រះនាភីឡើងទៅគ្របទល់នឹងអាកាស ។ ទី ៣ ទ្រង់ឃើញដង្កូវច្រើន ខ្លួនស ក្បាលខ្មៅ វារឡើងពីចុងព្រះបាទាគ្របដល់ព្រះជង្ឃា ។ ទី ៤ ទ្រង់ឃើញសត្វបក្សី ៤ ពួកមានពណ៌ខុសគ្នា ហើរពីទិសទាំង៤មកក្រាបទៀបព្រះបាទហើយត្រឡប់ជាមានពណ៌សទាំងអស់ ។ ទី ៥ ទ្រង់ឃើញថាព្រះអង្គយាងចង្ក្រមលើភ្នំលាមកដ៏ធំតែព្រះបាទាមិនបានប្រឡាក់ដោយលាមកឡើយ ។

១១៩–សំ. ព្រះមហាសុបិនទាំង ៥ ប្រការនេះ ជាបុព្វនិមិត្តប្លែកគ្នាដូចម្ដេច ?

ឆ. ទី ១ ការផ្ទំលើផែនដី ជាបុព្វនិមិត្តនៃការបានឆ្ពុំអនុត្តរ-

សម្មាសម្ពុទ្ធញ្ញាណ ។ ព្រះសិរកើយភ្នំហិមពាន្ត ជាបុព្វនិមិត្តនៃការបាននូវខ្នើយ គឺ សព្វញ្ញុតញ្ញាណ ។ ការសណ្ឋាកព្រះហស្តនិងព្រះបាទចុះក្នុងសមុទ្រនោះ ។ ជាបុព្វនិមិត្តនៃកិរិយាសំដែងនូវធម្មចក្រ ដល់ទេវតានិងមនុស្ស ។ ការផ្ទុំផ្កាភក្សីផែនដី ជាបុព្វនិមិត្តនៃកិរិយាធ្វើសត្វដែលមានមុខផ្កាប់ចុះឲ្យផ្ងារឡើង ។ កិរិយាផ្ទុំលើកព្រះនេត្រជាបុព្វនិមិត្តនៃកិរិយាបាននូវទិព្វចក្ខុ ។ ការឃើញនូវពន្លឺភ្លឺផ្សាយដល់ភវគ្គព្រហ្មជាបុព្វនិមិត្តនៃអនាវរណញ្ញាណ ។ ទី ២ ទ្រង់ឃើញស្មៅចិញ្ចៀនដុះលេចពីព្រះនាភីនោះជាបុព្វនិមិត្តនៃការសំដែងនូវអដ្ឋង្គិកមគ្គ ។ ទី ៣ ទ្រង់ឃើញដង្កូវប្រែកាយជាបុព្វនិមិត្តនៃបរិស័ទទាំង ៤ ដល់នូវត្រៃសរណគមន៍ស្មើដោយជីវិត ។ ទី ៤ ទ្រង់ឃើញសត្វបក្សី ៤ ពួក ជាបុព្វនិមិត្តនៃត្រកូលទាំង ៤ ចេញបួសប្រព្រឹត្តតាមធម្មវិន័យ ។ ទី ៥ ទ្រង់ឃើញចង្ក្រមលើភ្នំលាមកជាបុព្វនិមិត្តនៃចតុប្បច្ច័យដែលកើតឡើងដល់ព្រះអង្គ តែព្រះទ័យមិនជាប់ជំពាក់ក្នុងបច្ច័យទាំង ៤ នោះឡើយ ។

១២០ ស. ចុះនរណា ទាយមហាសុបិនទាំង ៥ នោះ ថ្វាយព្រះអង្គបានជាទ្រង់ជ្រាបដូច្នោះ ?

ឆ. គ្មានអ្នកណាទាយថ្វាយទេ គឺព្រះអង្គទ្រង់សន្និដ្ឋានក្នុងព្រះទ័យថា "អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ" , រួចទ្រង់

www.budinst.gov.kh www.elibraryofcambodia.org

ទាយដោយព្រះអង្គឯងសព្វគ្រប់ប្រការ (ដូចបានឆ្លើយខាងលើនោះហើយ) ។

## ពុទ្ធបូជា

១២១-ស. ក្នុងថ្ងៃដែលព្រះមហាបុរសបានត្រាស់ដឹង ព្រះអង្គបានទទួលមធុបាយាសអំពីស្ត្រីណា ? ជាកូនអ្នកណា ? នៅស្រុកឈ្មោះអ្វី ?

ឆ. ព្រះអង្គបានទទួលមធុបាយាសអំពីនាងសុជាតា ជាធីតានៃសេនកុដុម្ពិក, នៅស្រុកសេនានិគមក្នុងឧរុវេលាប្រទេស ។

១២២-ស. ចុះមធុបាយាសនោះ ព្រះអង្គពូតបានប៉ុន្មានពំនូត ? សោយនៅកន្លែងណា ? លុះសោយរួចហើយទ្រង់ធ្វើដូចម្តេចទៀត ?

ឆ. ព្រះអង្គពូតមធុបាយាសបាន ៤៩ ពំនូតប៉ុនៗ គ្រាប់ត្នោត ។ ទ្រង់សោយក្បែរឆ្នេរស្ទឹងនេរញ្ជរា ។ សោយស្រេចទ្រង់បណ្តែតថាសមាសនោះទៅក្នុងស្ទឹង ថាសមាសក៏អណ្តែតច្រាស់ទឹកទៅបាន ៨០ ហត្ថ ដោយអំណាចទ្រង់អធិដ្ឋាន ថាសនោះលិចទៅដល់ពិភពកាឡនាគ ទៅទង្គិចនឹងថាសនៃព្រះពុទ្ធ ៣ ព្រះអង្គពីបុរាណ ហើយសៀតស៊កពីក្រោមថាសទាំង ៣ នោះ ។

១២៣-ស. កាលព្រះមហាបុរសសោយមធុបាយាសហើយទ្រង់យាងទៅទីណា ? បានទទួលស្មៅអំពីអ្នកណា ?

www.budinst.gov.kh www.elibraryofcambodia.org

ឫ. ដល់វេលារសៀលព្រះអង្គយាងទៅកាន់ពោធិព្រឹក្ស ។ តាមផ្លូវទៅទ្រង់បានទទួលស្បូវភ្លាំង(១)អំពីសោត្ថិយព្រាហ្មណ៍ ទ្រង់ក្រាលស្បូវភ្លាំងក្រោមដើមពោធិព្រឹក្ស ។

១២៤– ស. រតនបល្ល័ង្កមានកំពស់ប៉ុន្មានហត្ថ ? ដើមពោធិព្រឹក្សមានកំពស់ប៉ុន្មានហត្ថ ?

ឫ រតនបល្ល័ង្កកំពស់ ១៤ ហត្ថ ។ ដើមពោធិព្រឹក្សកំពស់ ៥០ ហត្ថ ។

១២៥– ស. ចុះរតនបល្ល័ង្កនោះកើតមកអំពីស្បូវភ្លាំងមែនឬទេ ?

ឫ. មិនមែនទេ, គឺផុសឡើងឯកឯងត្រង់នោះ ដោយអំណាចព្រះបារមីនៃព្រះមហាបុរស ។

១២៦– ស. កាលព្រះមហាបុរសគង់លើរតនបល្ល័ង្កទ្រង់អធិដ្ឋានព្យាយាមមានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ទ្រង់អធិដ្ឋានថាម៉េច ?

ឫ. មានអង្គ ៤ ។ គឺ ស្បែក១, សរសៃ១, ឆ្អឹង១, ឈាម១ ។ ព្រះអង្គទ្រង់អធិដ្ឋានថា "ស្បែក សរសៃ ឆ្អឹង ឈាម នៃយើងចូរនឹង

---

១ បាលីថា កុស ប្រែតាមទំលាប់ថា "ស្បូវភ្លាំង" នៃសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក ជួន-ណាត កាលនិមន្តទៅនគរស្យាមបានជ្រាបថា៖ ស្មៅស្លា អ្នកនគរស្យាមហៅថា កុស ។ ដូច្នេះ កុស គួរប្រែថា "ស្មៅស្លា" វិញ ។

ស្ងួតអស់ទៅចុះ បើអាត្មាអញមិនបានត្រាស់ទេ នឹងមិនក្រោកចេញពីរតនបល្ល័ង្កនេះឡើយ” ។

## មារវិជ័យ

១២៧– ស. ក្នុងពេលដែលព្រះមហាបុរសគង់លើរតនបល្ល័ង្កនោះ មានអ្នកណាមកផ្ចាញ់ព្រះអង្គដែរឬទេ ? មកផ្ចាញ់នោះតើដោយអាការដូចម្ដេចខ្លះ ?

ឆ. មានទេវបុត្តមារមកផ្ចាញ់ ។ ដោយអាការលើកទ័ពមកពលខាងមុខនិងខាងឆ្វេងខាងស្ដាំ កម្រាស ១២ យោជន៍ដូចគ្នា ខាងលើកម្រាស ៩ យោជន៍ ។ ទេវបុត្តមារជិះដំរីមេខលកំពស់ ១៥០ យោជន៍ និម្មិតដៃមួយពាន់កាន់អាវុធផ្សេងៗ ចំណែកពលមារនិម្មិតខ្លួនប្លែកគ្នាមានពណ៌ខៀវលឿងជាដើម ពលខ្លះខ្លួនជាសត្វក្បាលជាយក្ស ពលខ្លះខ្លួនជាយក្សក្បាលជាម្រឹគបក្សីជាដើម ។

១២៨– ស. ចុះទេវបុត្តមារសំដែងឫទ្ធិផ្ចាញ់ព្រះមហាបុរសដូចម្ដេចខ្លះ ?

ឆ. ទេវបុត្តមារសំដែងឫទ្ធិ ៩ ប្រការ គឺ ខ្យល់ព្យុះ១, ភ្លៀងធំ១, ភ្លៀងថ្ម១, ភ្លៀងគ្រឿងប្រហារ១, ភ្លៀងរងើកភ្លើង១, ភ្លៀងផេះក្ដៅ១, ភ្លៀងដីខ្សាច់ ១, ភ្លៀងភក់ ១, ធ្វើឲ្យងងឹតកាំផ្សែងគ្រប់ទិស

www.budinst.gov.kh www.elibraryofcambodia.org

ទាំងបួន ១ ។ ប៉ុន្តែហេតុទាំង ៩ យ៉ាងនេះមិនអាចបៀតបៀនព្រះមហាបុរសបានឡើយ ត្រឡប់ក្លាយទៅជាគ្រឿងបូជាព្រះអង្គវិញ ។

១២៩–ស. ចុះព្រះមហាបុរសឈ្នះក្រុងមារដោយអំណាចអ្វី? មានប៉ុន្មានយ៉ាង?

ឆ. ព្រះអង្គឈ្នះដោយអំណាចព្រះបារមី ៣០, មហាបរិច្ចាគ ៥និងចរិយា ៣ ប្រការ ។

១៣០–ស. ចុះក្រុងមារមានអ្វីជាសាក្សី? ព្រះមហាបុរសមានអ្វីជាសាក្សី?

ឆ. ក្រុងមារមានពលយោធាជាសាក្សី ។ ព្រះមហាបុរសមានមហាប្រឹថពីជាសាក្សី ។

១៣១–ស. កាលក្រុងមារចាញ់ព្រះមហាបុរសហើយ បានធ្វើកិរិយាដូចម្ដេច?

ឆ. បានលើកដៃទាំង ១ ពាន់ដាក់លើសិរសី ហើយពោលសរសើរដោយគាថាដ៏ឈ្មោះថា នមោ តេ បុរិសាជញ្ញ ជាដើម នមស្ការយ៉ាងនេះ ហើយហោះរត់បាត់ទៅ ។

## អភិសម្ពោធិ

១៣២–ស. រាប់តាំងពីព្រះមហាបុរសទ្រង់ព្រះផ្នួសមកប៉ុន្មានឆ្នាំទើបព្រះអង្គបានត្រាស់ដឹង? ហេតុអ្វីក៏យូរដល់ប៉ុណ្ណោះ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ៦ ឆ្នាំ ។ បានជាយូរដល់ប៉ុណ្ណោះ ព្រោះធម្មតានិយមឲ្យព្រះអង្គស្វែងរកសេចក្ដីត្រាស់ដឹងក្នុងលទ្ធិចាស់ទាល់តែឃើញច្បាស់ថាជាផ្លូវខុស ទើបបានស្វែងរកតាមបញ្ញារបស់ព្រះអង្គ ដើម្បីជាឧបការដល់ការទូន្មានវេនេយ្យនិករក្នុងវេលាដែលបានត្រាស់ដឹងហើយ ។

១៣៣ ស. កាលព្រះមហាបុរសផ្ចាញ់ក្រុងមារស្រេចហើយ ក្នុងរាត្រីនោះព្រះអង្គបានញាណប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ. ក្នុងបឋមយាមព្រះអង្គបាននូវបុព្វេនិវាសានុស្សតិញាណ គឺរឭកឃើញជាតិតាំងពីទី ១ ទី ២ រហូតដល់អនេកជាតិ, ក្នុងយាមទី ២ ព្រះអង្គបាននូវចុតូបបាតញាណ គឺឃើញសត្វច្យុតនិងកើត, ក្នុងយាមទី ៣ ព្រះអង្គបាននូវអាសវក្ខយញាណ គឺជ្រាបការធ្វើឲ្យអស់អាសវៈ ។

១៣៤ – ស. ក្នុងយាមទី ៣ ព្រះមហាបុរសបានពិចារណាធម៌អ្វី ?

ឆ. ព្រះអង្គពិចារណាបច្ចយាការមានអង្គ ១២ យ៉ាង គឺបដិច្ច-សមុប្បាទធម៌ ។

១៣៥ – ស. បដិច្ចសមុប្បាទធម៌នោះ មានអធិប្បាយដូចម្ដេច ?

ឆ. អធិប្បាយថា ធម៌មានបច្ច័យអាស្រ័យគ្នាហើយកើតឡើង គឺជរាមរណៈមានជាតិជាបច្ច័យ, ជាតិមានភពជាបច្ច័យ, ភពមានឧបា-ទានជាបច្ច័យ, ឧបាទានមានតណ្ហាជាបច្ច័យ, តណ្ហាមានវេទនាជាបច្ច័យ,

វេទនាមានផស្សៈជាបច្ច័យ, ផស្សៈមានសឡាយតនៈជាបច្ច័យ, សឡាយ-តនៈមាននាមរូបជាបច្ច័យ, នាមរូបមានវិញ្ញាណជាបច្ច័យ, វិញ្ញាណមានសង្ខារជាបច្ច័យ, សង្ខារមានអវិជ្ជាជាបច្ច័យ ។ ជរានិងមរណៈរលត់ទៅបានព្រោះរលត់ជាតិ ជាតិរលត់ទៅបាន ព្រោះរលត់ភព ។ល។ សង្ខាររលត់ទៅបាន ព្រោះរលត់អវិជ្ជា ។

១៣៦– ស. ព្រះមហាបុរសបានត្រាស់ដឹងនៅស្រុកណា ? ក្នុងថ្ងៃខែ–ឆ្នាំអ្វី ? វេលាណា ? ក្នុងព្រះជន្មប៉ុន្មាន ?

ឆ. នៅឧរុវេលាប្រទេសសេនានិគមក្បែរឆ្នេរស្ទឹងនេរញ្ជរា, ក្នុងថ្ងៃពុធ, ពេញបូណ៌មីខែពិសាខ, ឆ្នាំរកា, វេលាជិតអរុណរះ; ក្នុងព្រះជន្មគំរប់ ៣៥ ឆ្នាំ ។

១៣៧– ស. កាលព្រះមហាបុរសបានសម្រេចនូវសព្វញ្ញុតញ្ញាណហើយ ទ្រង់បន្លឺនូវឧទានគាថាដូចម្តេច ?

ឆ. ដូច្នេះ អនេកជាតិសំសារំ ។ល។ តណ្ហានំ ខយមជ្ឈគា "គឺថាតថាគតកាលមិនទាន់បានជួបប្រទះ (នូវពោធិញ្ញាណ) វល់តែស្វែងរកនូវជាងផ្ទះគឺតណ្ហាអ្នកធ្វើនូវផ្ទះគឺអត្តភាព ហើយអន្ទោលទៅអស់សង្សារមានជាតិមិនតែមួយ, ជាតិគឺកិរិយាកើតរឿយៗ រមែងនាំមកនូវសេចក្តីទុក្ខ; ម្នាលជាងផ្ទះគឺតណ្ហា (ឥឡូវនេះ) តថាគតបានឃើញអ្នកច្បាស់ហើយ,

www.budinst.gov.kh www.elibraryofcambodia.org

អ្នកនឹងធ្វើនូវផ្ទះគឺអត្តភាព (នេះ) ទៀតថាគតពុំបានឡើយ. ឆ្អឹងជំនីរគឺកិលេសទាំងឡាយទាំងអស់របស់អ្នក តថាគតបានបំបាក់ចោលហើយ, ទាំងកំពូលនៃផ្ទះគឺអវិជ្ជារបស់អ្នក តថាគតក៏បានបំបាក់បង់ហើយ; ចិត្ត-របស់តថាគតបានដល់ហើយនូវព្រះនិព្វាន ដែលមានសង្ខារទៅប្រាសហើយ, តថាគតបានដល់ហើយនូវព្រះអរហត្តគឺការអស់ទៅនៃតណ្ហាទាំងឡាយ” ។

១៣៨–ស. ព្រះអង្គជ្រាបធម៌អ្វី បានជាប្ដេជ្ញាព្រះអង្គថាត្រាស់ដឹង ?

ឆ. ព្រះអង្គជ្រាបហេតុជ្រាបផល បានដល់អរិយសច្ចទាំងបួន គឺព្រះអង្គជ្រាបថា សេចក្ដីកើតចាស់ឈឺស្លាប់និងយំសោក សេចក្ដីចង្អៀតចង្អល់ចិត្តទាំងអម្បាលនេះជាទុក្ខ, ជ្រាបថាតណ្ហាគឺសេចក្ដីអន្ទះអន្ទែងចង់បានជាហេតុឲ្យកើតទុក្ខ ដែលហៅថា សមុទ័យ, ជ្រាបធម៌ជាគ្រឿងរំលត់តណ្ហា ដែលហៅថា និរោធ, ជ្រាបបដិបទាដែលជាផ្លូវបដិបត្តិឲ្យដល់នូវសេចក្ដីរំលត់ទុក្ខ ដែលហៅថា មគ្គ (មានអង្គ ៨ គឺបញ្ញាឃើញត្រូវ ១, សេចក្ដីត្រិះរិះត្រូវ ១, និយាយត្រូវ ១, ធ្វើការងារត្រូវ ១, តាំងចិត្តត្រូវ១, ចិញ្ចឹមជីវិតត្រូវ១, សេចក្ដីព្យាយាមត្រូវ១, រឭកត្រូវ១) រួមជាអរិយសច្ច ៤ គឺទុក្ខ១, សមុទ័យ១, និរោធ១, មគ្គ១ ។

www.budinst.gov.kh www.elibraryofcambodia.org

១៣៩– សំ. ចុះអរិយសច្ចទាំង ៤ នោះ ចាត់ប៉ុន្មានជាហេតុ ប៉ុន្មានជាផល ?

ច. ចាត់សមុទ័យនិងមគ្គ ២ នេះជាហេតុ, ទុក្ខនិងនិរោធ ២ នេះជាផល ; សមុទ័យជាហេតុនៃទុក្ខ, មគ្គជាហេតុនៃនិរោធ ។

១៤០– សំ. ហេតុអ្វីបានជាព្រះអង្គមានព្រះនាមថា អរហំ សម្មាសម្ពុទ្ធោ ?

ច. ហេតុតែព្រះអង្គបានជ្រាបអរិយសច្ចទាំង ៤ (ដូចបានឆ្លើយខាងដើមហើយ) ។

១៤១ សំ. ដែលដឹងថាព្រះអង្គជ្រាបអរិយសច្ចទាំង ៤ នោះតើមានអ្វីជាគ្រឿងសាធក ?

ច. មានព្រះធម្មចក្កប្បវត្តនសូត្រជាសំគាល់, ត្រង់ព្រះពុទ្ធដីកាថា "កាលណា បញ្ញាការដឹងការឃើញតាមសភាវៈពិត ក្នុងអរិយសច្ចទាំង ៤ នេះរបស់តថាគតហ្មត់ចត់ល្អហើយ កាលនោះតថាគតអាចប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ឥតអ្នកណាប្រៀបស្មើក្នុងលោក"។

## ពោធិសព្វញ្ញូ

១៤២– សំ. កាលព្រះសាស្តាបានត្រាស់ដឹងថ្មីៗ ទ្រង់គង់នៅកន្លែងណាខ្លះ ? ចំនួនប៉ុន្មានថ្ងៃ ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ទ្រង់គង់នៅក្នុងទីតាំង ៧ ដែលហៅថាសត្តមហាឋាន គឺ ទី ១ គង់លើរតនបល្ល័ង្ក ក្រោមពោធិព្រឹក្ស ៧ ថ្ងៃ ។ ទី ២ គង់ក្នុងអនិមិសលក្ខណចេតិយដ្ឋាន ទតរតនបល្ល័ង្កនោះ ដោយព្រះនេត្រមិនបព្រិចអស់ ៧ ថ្ងៃ ។ ទី ៣ គង់ក្នុងរតនៈចេតិយដ្ឋាន គឺព្រះអង្គយាងចង្ក្រមលើទីចង្ក្រមកែវអស់ ៧ ថ្ងៃ ។ ទី ៤ គង់ក្នុងរតនឃរចេតិយដ្ឋាន គឺផ្ទះកែវទ្រង់ពិចារណានូវបិដកទាំង ៣ អស់ ៧ ថ្ងៃ ។ ទី ៥ គង់ក្រោមដើមអជបាលនិគ្រោធ ទ្រង់ពិចារណាធម៌ដែលព្រះអង្គបានត្រាស់ដឹងអស់៧ថ្ងៃ។ ទី ៦ គង់ក្បែរឆ្នេរមុច្ចលិន្ទស្រះអស់ ៧ ថ្ងៃ ។ ទី ៧ គង់ក្រោមដើមកែសអស់ ៧ ថ្ងៃ ។ រួមថ្ងៃក្នុងទីតាំង ៧ នោះ ត្រូវជា ៤៩ ថ្ងៃ ។

១៤៣ - ស. ចុះក្នុង ៤៩ ថ្ងៃនោះព្រះអង្គសោយចង្ហាន់ដែរឬទេ? ព្រោះហេតុអ្វី?

ឆ. ឥតសោយចង្ហាន់ទេ, ព្រោះព្រះអង្គឆ្អែតទៅដោយវិមុត្តិសុខ ។

១៤៤ - ស. កាលព្រះសាស្ដាគង់ក្រោមអជបាលនិគ្រោធ មានអ្នកណាចូលទៅគាល់ព្រះអង្គដែរឬទេ ?

ឆ មានទេវបុត្តមារ ចូលទៅក្រាបទូលអារាធនាឱ្យព្រះអង្គបរិនិព្វាន ។ បន្ទាប់ពីនោះមក មារធីតាទាំង ៣ នាក់ គឺនាងតណ្ហា ១, អរតី ១, រាគា ១ ចូលមកបៀតបៀនព្រះអង្គទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

១៤៥- ស. ត្រង់ដែលថា ព្រះសាស្ដាគង់ក្នុងផ្ទះកែវនោះ គឺមានផ្ទះកែវមែនឬទេ ?

ឆ. មិនមែនទេ ។ ផ្ទះកែវរបស់ព្រះអង្គជាវិហារៈនៃព្រះសទ្ធម្មទាំងអស់គឺសតិបដ្ឋាន ៤ ជាភូមិភាគ, ឥទ្ធិបាទ ៤ ជាសសរ, វិនយបិដកជាជញ្ជាំង, សម្មប្បធាន ៤ ជាក្រប, សមាបត្តិ ៨ ជារតនវិថ្ម, សុត្តន្តបិដកជាគ្រឿងដំបូល, អភិធម្មបិដកជាគ្រឿងប្រក់ ។

១៤៦ ស. ដែលថាព្រះសាស្ដាមានរស្មី ៦ ពណ៌នោះ តើគឺពណ៌អ្វីខ្លះ ?

ឆ. គឺពណ៌ខៀវ១, លឿង១, ក្រហម១, ស១, ហង្សបាទ ១, ផ្លេក ៗ ១ ។

១៤៧- ស. កាលព្រះសាស្ដាគង់ក្រោមដើមកែស មានអ្នកណាយកវត្ថុអ្វីមកថ្វាយដែរឬទេ ?

ឆ. ព្រះឥន្ទ្រយកផ្លែសម៉ ឈើស្ទន់និងទឹកមកថ្វាយព្រះសាស្ដា ។ បន្ទាប់ពីព្រះឥន្ទ្រមក ពាណិជ ២ នាក់ ជាបងប្អូននឹងគ្នា បងឈ្មោះតបុស្សៈ ប្អូនឈ្មោះភល្លិកៈ បានយកសត្តុផុសសត្តុផង់មកថ្វាយព្រះសាស្ដា ។ ទ្រង់ប្រទានព្រះកេសធាតុ ៨ សរសៃឲ្យពាណិជនោះយកទៅបញ្ចុះទុកក្នុងសិង្គុត្តរចេតិយ ដើម្បីធ្វើសក្ការបូជា ។

www.budinst.gov.kh www.elibraryofcambodia.org

១៤៨. ស. កាលដែលព្រះសាស្ដាទទួលសត្តុវត្ថុពីពាណិជនោះ តើទ្រង់ទទួលដោយអ្វី ?

ឆ. ទ្រង់ទទួលដោយបាត្រថ្មដែលស្ដេចចតុលោកបាលយកមកថ្វាយ ។

១៤៩ – ស. ទីសិទ្ធត្ថចេតិយនោះ គេបានបញ្ចុះវត្ថុអ្វីខ្លះ ?

ឆ. គេបានបញ្ចុះគ្រឿងបរិក្ខារនៃព្រះពុទ្ធ ៤ ព្រះអង្គ ក្នុងភទ្ទកប្បនេះគឺបញ្ចុះធមក្រករបស់ព្រះពុទ្ធកកុសន្ធៈ១, វត្តពន្ធរបស់ព្រះពុទ្ធកោនាគមនៈ ១, សាដករបស់ព្រះពុទ្ធកស្សបៈ ១, ព្រះកេសធាតុ ៨ សរសៃរបស់ព្រះពុទ្ធគោតម ១ ។

១៥០ – ស. សិទ្ធត្ថចេតិយ គេធ្វើនៅស្រុកណា ?

ឆ. នៅក្នុងស្រុកភូមា ។

១៥១ – ស. អ្នកណាជាឧបាសកមុនគេបំផុត ? ហៅថាអ្វី ?

ឆ. ពាណិជ ២ នាក់ គឺតបុស្សៈ និងភល្លិកៈ ។ ដល់នូវសរណគមន៍ ២ គឺព្រះពុទ្ធនិងព្រះធម៌ ហៅថា ទ្វេវាចិកសរណគមន៍ ។

## ព្រហ្មជ្ឈេសនៈ

១៥២ – ស. ព្រះទ័យនៃព្រះសាស្ដាពេញពោរទៅដោយព្រះមហាករុណាមែនឬទេ ? ហេតុម្ដេចកាលព្រះអង្គបានត្រាស់ដឹងហើយ ក្រឡប់

www.budinst.gov.kh www.elibraryofcambodia.org

ជារួញរាព្រះទ័យក្នុងការសំដែងធម៌ទៅវិញ ? ខាងក្រោយមកទ្រង់ព្រះតម្រិះដូចម្ដេច បានជាទ្រង់អធិដ្ឋានព្រះទ័យថា នឹងទ្រង់សំដែងធម៌ប្រោសសត្វ ?

ច. រឿងនេះជាសេចក្ដីពិត ព្រះសាស្ដានៃយើងទ្រង់ពេញពោរទៅដោយព្រះមហាករុណាមែន ។ ប៉ុន្តែ កាលព្រះអង្គបានត្រាស់ដឹងហើយ ត្រឡប់ជាមានព្រះទ័យរួញរាទៅវិញនោះ គ្រាន់តែមានក្នុងមួយខណៈចិត្តប៉ុណ្ណោះទេ ដោយទ្រង់ព្រះតម្រិះថា ធម៌ដែលតថាគតបានត្រាស់ដឹងហើយនោះជ្រាលជ្រៅណាស់ តម្រូវពួកសត្វអ្នកមានកិលេសដូចធូលីមានរាគៈជាដើម នឹងដឹងបានដោយងាយហើស ។ ក្នុងករណីដូច្នេះ ក៏ជាតែព្រះបរមសាស្ដាដែលបានត្រាស់ដឹងធម៌ដ៏ល្អិតសុខុមហើយទ្រង់អល់ឯកក្នុងការសំដែងធម៌នេះឡើយ សូម្បីតែអ្នកដែលស្លិតចិត្តនឹងប្រព្រឹត្តតាមព្រះអង្គហើយ គេកំគត់ធ្វើតាមទៅបានដោយលំបាក ព្រោះការប្រាស់ក្រ-ផែលកិលេសរបស់សត្វអ្នកក្រាស់ទៅដោយរាគៈ ទោសៈ មោហៈមិនមែនជាវិស័យគំចាត់បានងាយទេ ។ ហេតុនេះ កាលព្រះសាស្ដាបានត្រាស់ដឹងហើយ ត្រូវមានព្រះទ័យរួញរាជាធម្មតា ។ សូម្បីតែសាមញ្ញជនអ្នកបានសិក្សាវិជ្ជាការណាមួយ ឬ ធ្វើការងារប្រភេទខ្លះដែលត្រូវរងទុក្ខលំបាកយ៉ាងច្រើន លុះបានសម្រេចហើយគង់តែមានចិត្តរួញរាគ្រាន់ខ្លះដូចគ្នាថា



www.budinst.gov.kh www.elibraryofcambodia.org

ការងារបែបនេះ អ្នកមិនមានព្យាយាមទំនងមិនមានអំណត់ទេ មុខជាមិនអាចនឹងធ្វើឱ្យសម្រេចបានឡើយ ។

វេលាខាងក្រោយ ព្រះអង្គទ្រង់ពិចារណាឃើញថា វេនេយ្យ-សត្វមានប្រភេទច្រើនយ៉ាង គឺបុគ្គលខ្លះមានកិលេសស្រាលស្តួច ខ្លះមានកិលេសក្រាស់ ខ្លះមានឥន្ទ្រិយ គឺសទ្ធា, វីរិយ, សតិ, សមាធិ, បញ្ញា, ខ្លះមានឥន្ទ្រិយទន់ ខ្លះមានអាការល្អ ខ្លះមានអាការអាក្រក់ ខ្លះប្រដៅងាយ ខ្លះប្រដៅក្រ ខ្លះអាចនឹងដឹងបាន ខ្លះមិនអាចនឹងដឹងបាន អ្នកមានគុណសម្បត្តិដូច្នោះជាប្រមាណ យ៉ាងកណ្តាល បានទទួលអប់រំក្នុងបដិបទាដ៏ជាបុព្វភាគទាល់តែមានឧបនិស្ស័យ ក៏នៅតែត្រូវបានទទួលការណែនាំក្នុងធម៌ជាន់ទាបជាមុន ដើម្បីឱ្យកើតមានឧបនិស្ស័យ កាលបើដូច្នោះ ការទ្រង់សំដែងធម៌មុខជាមិនឥតផល អាចឱ្យសម្រេចប្រយោជន៍ដល់មនុស្សគ្រប់ពួកបាន វៀរលែងតែពួកដែលមិនមែនជាវេនេយ្យសត្វ ។ ព្រះសាស្តាមានព្រះញាណឃើញហេតុនោះ ទ្រង់ព្រះចិន្តាដូចបានពោលមកហើយនេះ បានជាទ្រង់តាំងព្រះទ័យថានឹងសំដែងធម៌ប្រោសសត្វ ។

១៥៣ សួ. ព្រះបរមសាស្តា កាលនឹងទ្រង់ទេសនាប្រោសវេនេយ្យ-ជនទ្រង់ប្រៀបនឹងផ្កាឈូក ៤ យ៉ាង រឿងនេះ ដោយមានព្រះពុទ្ធបំណងដូចម្តេច ? ចូររៀបរាប់មកមើល !

www.budinst.gov.kh www.elibraryofcambodia.org

ឬ. ដោយព្រះអង្គមានព្រះបំណងថា ទីនឹងមិនទេសនាទូន្មានសត្វទេ ព្រោះទ្រង់ឃើញថា ធម៌ដែលព្រះអង្គត្រាស់ដឹងនោះជ្រាលជ្រៅណាស់ សត្វដែលមានអាល័យតិកិលេសកម្រនឹងដឹងតាមបាន ។ តែខាងក្រោយព្រះអង្គនឹកដល់បុគ្គល ៤ ពួក គឺឧគ្ឃដិតញ្ញូ បានដល់បុគ្គលដែលបានស្ដាប់ធម៌លោកអ្នកប្រាជ្ញសំដែងចប់ហើយ ក៏បានដឹងយល់ភ្លាម ប្រៀបដូចផ្កាឈូកគ្រាន់តែត្រូវកំដៅព្រះអាទិត្យក៏រីកមួយរំពេច នេះចាត់ជាពួកមួយ ។ វិបច្ចិតញ្ញូ បានដល់បុគ្គលដែលបានស្ដាប់ធម៌អ្នកប្រាជ្ញសំដែង ទាល់តែលោកចែករំលែកសេចក្ដីធម៌នោះឲ្យល្អិតបញ្ចេញទៅទៀត ទើបបានដឹងយល់ ប្រៀបដូចផ្កាឈូកដែលនឹងរីកក្នុងថ្ងៃស្អែក នេះចាត់ជាពួកមួយ ។ នេយ្យបុគ្គល បានដល់វេនេយ្យសត្វដែលលោកជាសាស្ដាដឹកនាំពន្យល់ទូន្មានរឿយៗ ទៅ ដើម្បីឲ្យបានសម្រេចមគ្គផល ដូចផ្កាឈូកដែលនឹងរីកក្នុងថ្ងៃខាងមុខៗ ទៅ នេះចាត់ជាពួកមួយ ។ បទបរមបុគ្គល បានដល់សត្វអ្នកស្ដាប់ធម៌ចាំមិនបាន ទាំងមិនបដិបត្តិតាម ប្រៀបដូចផ្កាឈូកដែលនឹងទៅជាចំណីនៃត្រីនិងអណ្ដើកដូច្នោះ នេះចាត់ជាពួកមួយ ។

១៥៤-សំ. អ្នកណាចូលទៅអារាធនាព្រះសាស្ដាឲ្យសំដែងធម៌ប្រោសសត្វ ? កាលព្រះអង្គគង់ក្នុងទីណា ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. សហម្បតិព្រហ្មទូលអារាធនា ។ ក្នុងគ្រាព្រះអង្គគង់ក្រោមដើមអជបាលនិគ្រោធ ។

## ធម្មចក្កប្បវត្តនទេសនា

១៥៥-សួ. កាលព្រះសាស្តាតាំងព្រះទ័យថានឹងសំដែងធម៌ប្រោសសត្វ ហើយទ្រង់នឹកដល់អ្នកណាមុនគេ ?

ឆ. ទ្រង់នឹកដល់អាឡារតាបសកាលាមគោត្រ និងឧទ្ទកតាបសរាមបុត្រមុនគេ ប៉ុន្តែទ្រង់ជ្រាបថា តាបសទាំង ២ រូបនោះក្ស័យជីវិតហួសទៅហើយ ។

១៥៦-សួ. ព្រះសាស្តាសំដែងធម៌ប្រោសអ្នកណាមុនគេបំផុត ?

ឆ. ប្រោសបញ្ចវគ្គិយភិក្ខុមុនគេបំផុត ។

១៥៧-សួ. ចុះព្រះអង្គសំដែងធម៌អ្វី ប្រោសបញ្ចវគ្គិយភិក្ខុនោះ? នៅកន្លែងណា ? ក្នុងស្រុកណា ?

ឆ. ទ្រង់សំដែងព្រះធម្មចក្រ ។ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន, ទៀបនគរពារាណសី ។

១៥៨-សួ. ចុះបណ្ដាបញ្ចវគ្គិយភិក្ខុទាំងនោះ តើលោកណាបានឃើញធម៌មុនគេ ? ហើយលោកឃើញដូចម្ដេច ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ព្រះអញ្ញាកោណ្ឌញ្ញៈជាប្រធាននៃពួកភិក្ខុបញ្ចវគ្គិយបាន ធម្មចក្ខុឃើញធម៌មុនគេ ៗ លោកឃើញថា របស់ណាមួយ ដែលបង្កើយ ប្រជុំតាក់តែងហើយ របស់នោះទាំងអស់សុទ្ធតែជាទុក្ខមិនមែនខ្លួនប្រាណ របស់ណាមួយកើតឡើងហើយ របស់នោះទាំងអស់ មានសេចក្ដីរលត់វិញជាធម្មតា ៗ

១៥៩– ស. ភិក្ខុបញ្ចវគ្គិយទាំងនោះបានសម្រេចព្រះអរហត្ត ព្រោះបានស្ដាប់ធម៌ទេសនាអ្វី? ធម៌នោះនិយាយពីអ្វី? ចូរឆ្លើយឲ្យល្មមស្ដាប់បាន!

ឆ. ព្រោះបានស្ដាប់ធម៌ទេសនា ហៅថា អនត្តលក្ខណសូត្រ ៗ និយាយពីខ្លួនមិនទៀងថា: ពពួកកាយរបស់យើងនេះ ជារបស់មិនទៀងទាត់ មានសេចក្ដីរលត់ និងសេចក្ដីបែកធ្លាយទៅជាធម្មតា កាលបើមិនទៀងហើយ ក៏ជាទុក្ខ កាលជាទុក្ខហើយនឹងប្រកាន់ថា ជាខ្លួនជាប្រាណ ជាយើង ជារបស់យើងក៏ជាការមិនសមគួរ ៗ

១៦០– ស. ហេតុដូចម្ដេចក៏ព្រះធម៌ទេសនានោះ បានជាព្រះអង្គលើកខ្លួនឡើងបដិសេធ?

ឆ. ហេតុតែសេចក្ដីចូលចិត្តរបស់មនុស្សទូទៅថា មានធម្មជាតិមួយ ដែលហៅថា អត្តា ប្រែថា ខ្លួន ជាសភាពទៀងទាត់ស្ថិតស្ថេរ

www.budinst.gov.kh www.elibraryofcambodia.org

មិនបេះស្លាប់ សឹងនៅក្នុងកងកាយរបស់សត្វ, ដល់វេលាមរណៈ កងកាយនោះទ្រុឌទ្រោមបាត់ទៅ ចំណែកអត្តានោះ បេញចាកកងកាយទៅ ចូលក្នុងសរីរៈដែលតាំងឡើងថ្មី ។ ព្រះអង្គត្រាស់បដិសេធអត្តានេះ ដើម្បីនឹងសំដែងឲ្យឃើញហេតុនិងផល ដូចអាស្រ័យអាយតនៈខាងក្នុងមានចក្ខុជាដើម អាយតនៈខាងក្រៅមានរូបជាដើមមកខ្ទប់គ្នា កើតវិញ្ញាណឡើង ហើយកើតសម្ផស្ស វេទនា សញ្ញា សញ្ចេតនា វិតក្ក វិចារ តទៅ ប្រព្រឹត្តទៅដោយធម្មតា អ្នកណានឹងប្រាជ្ញាធ្វើឲ្យខុសពីធម្មតាទៅមិនបាន តែជាបញ្ចក្ខន្ធនេះមានអ្វីជាមូលហេតុដើមមិនបាន ដែលហៅថា កោដ្ឋ ខាងដើមរបស់កោដ្ឋ មិនប្រាកដ ។

១៦១–សំ. សួរឲ្យត្រូវដែរ, បើព្រះអង្គទ្រង់ប្រកប អត្តកិលមថានុយោគ មកជាយូរហើយ ដល់វេលាទេសនាជាដំបូងហេតុម្ដេចក៏បែរជាទ្រង់តិះដៀលអត្តកិលមថានុយោគទៅវិញ ?

ឆ. ហេតុតែទ្រង់ប្រកបមកជាយូរហើយ ពុំបានសម្រេចប្រយោជន៍អ្វីសោះ ទើបទ្រង់តិះដៀលដូច្នោះ ។

១៦២–សំ. ព្រះសាវ័កទាំងឡាយអ្នកបានត្រាស់ដឹងធម៌ មិនចំពោះតែព្រះអញ្ញាកោណ្ឌញ្ញៈ ១ អង្គប៉ុណ្ណោះទេ ចុះហេតុអ្វីបានជាព្រះបរមសាស្ដា

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់បន្លឺឧទានថា អញ្ញាសិ វត ភោ កោណ្ឌញ្ញោ ចំពោះតែព្រះកោណ្ឌញ្ញៈ១ អង្គប៉ុណ្ណោះ ? ចូរប្រាប់តាមសេចក្ដីយល់ឃើញឱ្យជាក់ច្បាស់មកមើល ។

ឆ. ព្រះអញ្ញាកោណ្ឌញ្ញៈជាព្រះសាវ័កមុនដំបូងដែលបានត្រាស់ដឹងធម៌ជាបន្ទាល់របស់សេចក្ដីសម្រេចនៃការតាំងព្រះទ័យរបស់ព្រះអង្គ ។ ធម្មតាអ្នកធ្វើកិច្ចការអ្វី ដែលដឹងថាលំបាក កាលបើខំប្រឹងធ្វើទៅទាល់តែបានឃើញត្រើយនៃសេចក្ដីសម្រេច គង់តែងកើតចិត្តរីករាយថាបានការហើយបន្លឺឧទានថា សម្រេចដូចចិត្តប៉ងហើយ ។ ព្រះសាស្ដាទ្រង់បំពេញបារមីមកជាយូរណាស់ ទម្រាំតែនឹងបានសម្រេចសែនក្រ សែនលំបាក ដើម្បីនឹងទ្រង់សំដែងធម៌ប្រោសសត្វឱ្យបានត្រាស់ដឹងតាម ទាំងទ្រង់មានព្រះពុទ្ធបរិវិតក្កជាយូរហើយថា ព្រះធម៌ដែលព្រះអង្គត្រាស់ដឹងជារបស់ល្អិតសុខុមជ្រាលជ្រៅ សត្វកម្រនឹងត្រាស់ដឹងបាន ។ ប៉ុន្តែអាស្រ័យព្រះទ័យប្រកបដោយករុណា ទើបបានតាំងអធិដ្ឋានប្ដូរព្រះជន្មទៅក្នុងការសំដែងធម៌ប្រោសសត្វ ។ ការតាំងព្រះទ័យរបស់ព្រះអង្គនឹងបានសម្រេចផលនោះគឺដោយសារតែមានអ្នកត្រាស់ដឹងតាម សូម្បីមិនច្រើនត្រឹមតែមួយនាក់ក៏គង់តែទុកជាឧទាហរណ៍ ដែលនឹងត្រាស់ប្រាប់អ្នកដទៃគេទៅទៀតបាន ព្រោះថាបើមានអ្នកណាម្នាក់បានដឹងហើយ មុខជាមានអ្នកណាម្នាក់ទៀតបានដឹងៗ គ្នាទៅ ។ អ្នកត្រាស់ដឹងតាមជាដំបូង

www.budinst.gov.kh www.elibraryofcambodia.org

តាក់ជាបន្ទាល់សំខាន់ដែលនឹងឲ្យសន្និដ្ឋានថាការប្រកាសសាសនាតទៅមិនមែនជាដែលៗព្រះអញ្ញាកោណ្ឌញ្ញៈជាព្រះសាវ័កអង្គដំបូងបានត្រាស់ដឹងធម៌ ជាបន្ទាល់សាក្សីរបស់សេចក្តីសម្រេចនៃការគាំងព្រះទ័យរបស់ព្រះអង្គ ទើបបានទ្រង់បញ្ចេញឧទានថា អញ្ញាសិ វត ភោ កោណ្ឌញ្ញោ ដូចជាត្រាស់ថាបានការហើយម្ដុទ្រង់បន្លឺឧទានថា សម្រេចការហើយដូច្នោះដែរៗ

១៦៣-សួ. ធម្មចក្កប្បវត្តនសូត្រ, អនត្តលក្ខណសូត្រ និងអាទិត្ត-បរិយាយសូត្រ ព្រះសាស្ដាទ្រង់សម្ដែងប្រោសអ្នកណា? ក្នុងទីណា ?

ឆ. ធម្មចក្កប្បវត្តនសូត្រ និងអនត្តលក្ខណសូត្រ ទ្រង់សម្ដែងប្រោសបញ្ចវគ្គិយភិក្ខុក្នុងព្រៃឥសិបតនមិគទាយវ័ន នគរពារាណ-សី ។ អាទិត្តបរិយាយសូត្រ ទ្រង់សម្ដែងប្រោសភិក្ខុបុរាណជដិល ១ ពាន់ ៣ អង្គ មានព្រះឧរុវេលកស្សបៈជាដើម ក្បែរភ្នំគយាសីស-ប្រទេសដែនមគធៈ ។

១៦៤-សួ. ចុះមានហេតុដូចម្ដេច បានជាព្រះសាស្ដាទ្រង់លើកអាទិត្តបរិយាយសូត្រឡើងសម្ដែងប្រោសពួកភិក្ខុបុរាណជដិល ?

ឆ. ខ្ញុំយល់ចិត្តថា ទ្រង់សំដែងដើម្បីឲ្យត្រូវនឹងអធ្យាស្រ័យរបស់បុរាណជដិលដែលជាអ្នកធ្លាប់បូជាភ្លើងជារបស់ក្ដៅ ។

១៦៥-សួ. ហេតុអ្វីបានព្រះសាស្ដា កាលបានត្រាស់ដឹងហើយ មិនយាងទៅប្រោសព្រះពុទ្ធបិតាមាតានិងព្រះញាតិវង្សមុនជនឯទៀត ?

www.budinst.gov.kh www.elibraryofcambodia.org

ឮ. ហេតុតែទ្រង់យល់ឃើញថា គួរប្រតិស្ឋានព្រះពុទ្ធសាសនាទុកក្នុងមគធជនបទជាមុនសិន ព្រោះជាដែនដីមានអំណាចព្រមទាំងបរិបូណ៌ដោយសម្បត្តិ មានប្រជាជនច្រើនកុះករ ទាំងជាទីលំនៅនៃពួកគ្រូមេលទ្ធិច្រើន កាលបើពួកគ្រូទាំងនោះមកចុះចូលព្រះអង្គហើយ ព្រះអង្គងាយនឹងទូន្មានអ្នកដទៃតទៅទៀត ។ មួយទៀតមនុស្សក្នុងជាន់នោះ ច្រើនមានទិដ្ឋិមានះប្រកាន់ថាខ្លួនជាពួកអ្នកធំ គឺជាបិតាមាតាជីដូនជីតាមាមីងរបស់ព្រះអង្គ ។ បើព្រះអង្គបានត្រាស់ដឹងហើយ រួចយាងត្រង់ទៅប្រោសពួកសាក្យរាជក្នុងក្រុងកបិលពស្តុតែម្តង រមែងជាការលំបាកច្រើន ឬគឹងមិនបានសម្រេចផល ព្រោះលោកទាំងនោះកំពុងពេញទៅដោយទិដ្ឋិមានះប្រកាន់ថាជាអ្នកធំ ថែមទាំងមិនទាន់បាត់ខឹងក្នុងរឿងព្រះអង្គស្តេចចេញបួស ដែលគេសំគាល់ថាជាការប្រព្រឹត្តបន្ថោកវង្សត្រកូលផង ។ រួមឲ្យខ្លីថាចរិតនិស្ស័យឥន្ទ្រិយរបស់លោកទាំងនោះ នៅមិនទាន់ចាស់ក្លា លុះកាលណាព្រះអង្គស្តេចទៅប្រោសអ្នកនេះអ្នកនោះ ឲ្យបានសម្រេចប្រយោជន៍ទាល់តែព្រះកិត្តិគុណសេចក្តីល្អ របស់ព្រះអង្គល្បីទៅដល់ពួកសាក្យរាជ ៗ បាត់ខឹងកើតមានចិត្តស្រឡាញ់រាប់អានឡើងវិញ ស្តេចមកប្រោសវេលាខាងក្រោយទើបជាការងាយ ៗ ដោយហេតុដូចពោលមកនេះឯង ដែលបណ្ដាលមិនឲ្យព្រះអង្គស្តេចទៅប្រោសពួកសាក្យរាជមុនគេ ។

www.budinst.gov.kh www.elibraryofcambodia.org

១៦៦-សួ. មានអ្នកខ្លះរិះគន់ថា ព្រះពុទ្ធមុននឹងទ្រង់ទូន្មានធម៌ដល់អ្នកណាៗ ឬមុនត្រាស់សន្ទនានឹងអ្នកណាៗ ដូចកាលមុននឹងទ្រង់សម្ដែងធម្មចក្កក្ដី មុនត្រាស់ទេសនាផលរបស់ជីវកក្ដី ច្រើនតែលើកគុណខ្លួនថា តថាគតជាអ្នកប្រសើរយ៉ាងនុះយ៉ាងនេះ តថាគតដឹងធម៌យ៉ាងនោះយ៉ាងនេះជាដើម ធ្វើដូច្នោះតើយើងនឹងឆ្លើយដោះសាថាម៉េចឲ្យផុតពីពាក្យគេចោទនោះ ?

ឆ្លើ. រឿងនេះ យើងគួរឆ្លើយថា កាលបើពិចារណាមើលតែអាការខាងក្រៅស្រើៗ ក៏ឃើញត្រូវដូចជាគេចោទនោះមែន ។ ប៉ុន្តែសេចក្ដីពិតមិនមែនដូច្នោះទេ, ការណ៍ដែលព្រះអង្គលើកគុណសេចក្ដីល្អរបស់ព្រះអង្គឡើងប្រកាសជាមុនដំបូងនោះ ដោយទ្រង់ព្រះមេត្តាប្រាថ្នានឹងឲ្យអ្នកស្ដាប់ជឿទាំងក្នុងព្រះអង្គជាមុន គឺធ្វើឲ្យអ្នកស្ដាប់មានសេចក្ដីជឿចំពោះការពេញដឹងនិងការអង់អាចរបស់ព្រះអង្គ កាលបើអ្នកស្ដាប់ជឿព្រះអង្គថាល្អមែនហើយ វេលាព្រះអង្គនឹងទ្រង់ប្រដៅអ្វី គេក៏ប្រព្រឹត្តតាម ជាហេតុនាំប្រយោជន៍មកឲ្យដល់ខ្លួនឯង ។ បើអ្នកស្ដាប់មិនជឿព្រះអង្គថាល្អមែនជាពេញដឹងមែនទេ កាលណាឡើយគេនឹងធ្វើតាម ។ ដូចកាលព្រះអង្គមុននឹងទេសនាប្រោសបញ្ចវគ្គិយភិក្ខុ បើព្រះអង្គធ្វើមិនឲ្យបញ្ចវគ្គិយភិក្ខុឃើញអនុត្តរសម្មាសម្ពោធិញ្ញាណនៃព្រះអង្គបានហើយ កាលណា

www.budinst.gov.kh www.elibraryofcambodia.org

ឡើយបញ្ចវគ្គិយភិក្ខុនឹងតាំងចិត្តស្តាប់ព្រះធម្មចក្របាន មុខជានិយាយតាក់តោតតោយប្រការផ្សេង ៗ ហើយសំដែងអាការៈមិនគោរពចំពោះព្រះអង្គផង ៗ ប្រសិនជាព្រះអង្គសំដែងឲ្យអ្នកមិនជឿផ្ទះស្តាប់ ក៏ហាក់ដូចជាផ្លុំប៉ីឲ្យក្របីស្តាប់ ធម៌នោះក៏ឥតអំពើគ្មានផលដល់អ្នកស្តាប់ដូចឧបកា-ជីវកមិនជឿព្រះអង្គថាជាអ្នកប្រសើរមែន សូម្បីជួបព្រះអង្គត្រង់កណ្តាលផ្លូវបានទាំងចរចានឹងព្រះអង្គផង អាជីវកនោះក៏ឥតបានផលអ្វីដែរ ព្រោះតែខ្វះសេចក្តីជឿនោះឯង ៗ គឺជាគតពោធិសម្ភារជារបស់សំខាន់នៃអ្នកកាន់ព្រះពុទ្ធសាសនា ព្រោះហេតុនោះ ព្រះបរមសាស្តារបស់យើងទើបទ្រង់ប្រកាសសេចក្តីត្រាស់ដឹង នឹងសេចក្តីល្អរបស់ព្រះអង្គមុនពេលសម្តែងធម៌ ៗ ប៉ុន្តែ បើអ្នកស្តាប់ជឿព្រះអង្គស៊ប់ហើយ ព្រះអង្គក៏មិនប្រកាសទៀតទេ ដូចកាលមុននឹងសម្តែងអនត្តលក្ខណសូត្រ ព្រះអង្គមិនត្រាស់ផ្ទោះទៀតឡើយ ព្រោះបញ្ចវគ្គិយភិក្ខុតាំងនៅក្នុងសេខភូមិសោតាបន្នអរិយបុគ្គលហើយ ៗ បើព្រះអង្គជាអ្នកអំនួតមែន ក៏មុខជាបេះតែអួតប្រាប់អ្នកនេះ រួចប្រាប់អ្នកនោះឥតរើសមុខ ៗ ហេតុនេះ នឹងថាព្រះអង្គជាអ្នកអំនួតមិនត្រូវទេ គួរនឹកដល់ព្រះមហាករុណាធិគុណឲ្យកាន់តែច្រើនឡើងថែមទៀត ៗ

www.budinst.gov.kh www.elibraryofcambodia.org

១៦៧- សំ. ក្នុងវស្សាក្រោយដំបូង ។ ព្រះសាស្ដាបានធ្វើអ្វីឲ្យជាប្រយោជន៍ដ៏សមគួរដែលព្រះអង្គបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ គួរឲ្យយើងយកមកទុកជាក់ក្នុងចិត្តធ្វើជាគំរូបាន ?

ច. រាប់តាំងពីថ្ងៃ ១៤ កើតខែអាសាធ ស្ដេចទៅកាន់ព្រៃឥសិបតនមិគទាយវ័ន គង់ចាំវស្សានៅទីនោះ លុះដល់បញ្ជូនសាវ័កទៅប្រកាសព្រះសាសនាក្នុងនានាប្រទេស ព្រះអង្គ គំយាងទៅកាន់ឧរុវេលា·ប្រទេសក្នុងវេលាចេញវស្សាហើយ ។ ក្នុងរយៈកាលនេះ បានទ្រង់សំដែងធម៌ និងប្រទានឧបសម្បទដល់សាវ័កឲ្យសម្រេចអរហត្តផល ៦០ អង្គ គឺបញ្ចវគ្គិយភិក្ខុ ៥, ព្រះយស ១, សំឡាញ់ព្រះយស ៤ និងសំឡាញ់ព្រះយស ៥០ ទៀត ។ ទ្រង់ឲ្យមាតាបិតានិងភរិយាព្រះយសដល់នូវព្រះត្រៃសរណៈជាឧបាសកម្នាក់ ជាឧបាសិកាក្នុងលោកជាដំបូង ២ នាក់ ។

១៦៨- សំ. ពាក្យសរសើរព្រះគុណនៃព្រះសាស្ដាមានពាក្យមួយថា ព្រះអង្គឈ្លាសវៃក្នុងវិធីទេសនា ទ្រង់សំដែងធម៌ត្រូវតាមកាលៈទេសៈនិងអធ្យាស្រ័យរបស់សត្វ សម្រេចប្រយោជន៍ដល់មនុស្សគ្រប់ជាន់, ដូច្នេះចូររើសយករឿងណាមួយមកជាឧទាហរណ៍ ហើយឆ្លើយជាសំអាងក្នុងពាក្យនេះមើល!

www.budinst.gov.kh www.elibraryofcambodia.org

ញ. សូមតាំងឧទាហរណ៍មួយថា កាលព្រះសាស្តាទ្រង់សំដែងធម្មទេសនា ប្រោសព្រះបញ្ចវគ្គិយ, មហាជនក្នុងគ្រានោះកាន់តាមលទ្ធិសាសនាព្រាហ្មណ៍ ដែលនិយមសេពអត្តកិលមថានុយោគ និងកាមសុខល្លិកានុយោគថា ជាផ្លូវឲ្យសម្រេចធម៌វិសេសបាន ។ ឯបព្វជិតក្នុងគ្រានោះ មានព្រះបញ្ចវគ្គិយជាដើម ក៏ដក់ចិត្តស៊ប់នៅក្នុងផ្លូវទាំងពីរយ៉ាងជាខ្លាំងៗ កាលព្រះសាស្តាបានព្យាយាមធ្វើហួសដល់ទីបំផុតហើយ មិនបានសម្រេចផលអ្វីក៏ទ្រង់លះបង់ចេញ ព្រះអង្គវិលមកធ្វើដំណើរតាម មជ្ឈិមាបដិបទាវិញក៏បានត្រាស់ដឹងធម៌វិសេស ហើយយកមកសំដែងប្រាប់ព្រះបញ្ចវគ្គិយភិក្ខុដែលជាអ្នកជាប់ចិត្តទៅក្នុងអត្តកិលមថានុយោគនោះទើបគួរហៅថាត្រូវតាមកាលៈទេសៈ នឹងត្រូវតាមឧបនិស្ស័យរបស់សត្វ ទ្រង់ញុំាងព្រះបញ្ចវគ្គិយភិក្ខុឲ្យមានសេចក្តីជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាបាន ក្នុងទីបំផុតលោកទាំងនោះបានសម្រេចធម៌វិសេសដោយទេសនា អនត្តលក្ខណសូត្រ ។

មានឧទាហរណ៍មួយទៀតថា ជដិលកស្សប ៣ នាក់ ជាបងប្អូនប្រកាន់ខ្លួនថាជាអរហន្ត បំពេញពិធីបូជាយញ្ញ គឺដុតភ្លើងបូជាសែនព្រេនតាមលទ្ធិរបស់សាសនាព្រាហ្មណ៍ ។ កាលព្រះសាស្តាស្តេចយាងទៅប្រោស បានទ្រង់សំដែងអាទិត្តបរិយាយសូត្រសំដែងថា របស់ទាំងពួងគឺអាយតនៈខាងក្នុងនិងខាងក្រៅ មានចក្ខុនិងរូបជាដើម ជារបស់ក្តៅៗ ល។ ជាការត្រូវនឹងអធ្យាស្រ័យរបស់ជដិលទាំងនោះ ដែលនិយមការបូជាភ្លើង

www.budinst.gov.kh www.elibraryofcambodia.org

ជីដារបស់ក្តៅ ៗ ក្រៅពីឧទាហរណ៍នេះ នៅមានឧទាហរណ៍ជាច្រើនទៀត ប៉ុន្តែលើកមកប៉ុណ្ណេះល្មមជាទីសំគាល់បានហើយ ៗ

១៧០– ស. បើប្រសិនជាព្រះសាស្តាមិនយាងទៅប្រោសបុរាណជដិលឲ្យសូមឧបសម្បទាជាភិក្ខុពុទ្ធសាវ័កមុនទេ តើទ្រង់យាងទៅក្រុងរាជគ្រឹះតែមួយព្រះអង្គឯងជាដំបូង តើការយាងទៅនេះ នឹងបានផលខុសគ្នាឬទេ? ចូរអធិប្បាយ !

ឆ. ទំនងបានផលខុសគ្នា គឺថាមនុស្សក្នុងក្រុងរាជគ្រឹះនោះ ស្រឡាញ់រាប់អានបុរាណជដិលជាច្រើន បើព្រះសាស្តាស្តេចទៅតែមួយព្រះអង្គឯងទុកជាគេមិនងាយចុះចូលទេ ៗ ដូចជាកាលព្រះអង្គយាងទៅដល់ហើយគង់នៅក្នុងលដ្ឋិវ័ន, រាជបរិពាររបស់ព្រះបាទពិម្ពិសារដែលចូលមកគាល់មានអាការផ្សេង ៗ គ្នា មិនទន្ទលំទោន មិនរៀបរយ ៗ ព្រះសាស្តាត្រាស់ប្រើព្រះឧរុវេលកស្សបដែលជាទីស្រឡាញ់រាប់អានរបស់បរិពារទាំងនោះ ឲ្យប្រកាសលទ្ធិចាស់ជាឥតខ្លឹមសារឲ្យគេជឿឲ្យគេអស់សេចក្តីសង្ស័យហើយ នាំចិត្តស្តាប់ព្រះធម៌ទេសនា ៗ ដូច្នេះ ល្មមយល់បានថា ការបណ្តុះសេចក្តីនិយមរបស់មនុស្សទាំងឡាយត្រូវធ្វើឲ្យអ្នកធំដែលជាទីរាប់អានរបស់គេនិយមជាមុន ទើបនឹងសម្រេចបានល្អ ៗ

១៧១– ស. ព្រោះហេតុអ្វីបានជាព្រះសាស្តាប្រុងសំដែងធម៌ដល់ពួកបព្វជិតមុនគ្រហស្ថ ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ព្រោះបព្វជិតធ្លាប់បានគប់រកនូវប្រតិបត្តិមកជាច្រើន ហើយដូចផ្កាឈូកដែលដុះឡើងផុតពីទឹក គ្រាន់តែត្រូវរស្មីព្រះអាទិត្យក៏រីកភ្លាម ។

## យសបព្វជ្ជា

១៣១– ស. កាលព្រះសាស្តាប្រោសកុលបុត្តយសរួចហើយ ព្រះអង្គទ្រង់ប្រោសអ្នកណាតមកទៀត ?

ឆ. ទ្រង់ប្រោសយសកុលបុត្រ ជាបុត្រនាងសុជាតា ដែលបានថ្វាយមធុបាយាសដល់ព្រះសាស្តា ។ យសកុលបុត្របានស្តាប់អនុបុព្វីកថាចប់ ហើយក៏បានសម្រេចសោតាបត្តិផលក្នុងព្រៃឥសិបតនមិគទាយវ័ន ។ តពីនោះមកទៀតទ្រង់ប្រោសសេដ្ឋីជាបិតាព្រះយស នឹងភរិយាសេដ្ឋីជាមាតាព្រះយស ព្រមទាំងភរិយាព្រះយសឲ្យបានសម្រេចសោតាបត្តិផល ។ ខាងក្រោយមកព្រះយសបានឧបសម្បទាជាឯហិភិក្ខុ ។

១៣៣ ស. កាលព្រះសាស្តាប្រោសព្រះយសនឹងបិតាមាតា ភរិយានៃព្រះយសរួចហើយ ទ្រង់ប្រោសអ្នកណាទៀត ? ឈ្មោះអ្វីខ្លះ ?

ឆ. ទ្រង់ប្រោសសំឡាញ់ព្រះយស ៤ នាក់ទៀត គឺឈ្មោះ វិមលៈ ១, សុពាហុ ១, បុណ្ណជិ ១, គវម្បតិ ១ ។ តពីនោះមកទ្រង់ប្រោសសំឡាញ់ព្រះយស ៥០ ទៀត ប៉ុន្តែមិនដឹងជាឈ្មោះអ្វីខ្លះ ។ សំឡាញ់ព្រះ

www.budinst.gov.kh www.elibraryofcambodia.org

យសទាំង ៥៤ នាក់នេះ ក៏បានទទួលសម្បទាជាឯហិភិក្ខុដែរ ។

១៧៤ - ស. ចុះអ្នកណាជាឧបាសក និងឧបាសិកាមុនគេបំផុត ?

ឆ. បើជា ទ្វេវាចិកសរណគមន៍ គឺអ្នកដល់ព្រះពុទ្ធនិងព្រះធម៌ជាទីពឹងមុនគេ បានដល់ពាណិជពីរនាក់ឈ្មោះ តបុស្សៈ១, ភល្លិកៈ១ ។ បើជា តេវាចិកសរណគមន៍ គឺអ្នកដល់ព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាទីពឹង បានដល់សេដ្ឋីជាបិតាព្រះយស ហៅថា បឋមឧបាសក ។ ចំណែកមាតានិងភរិយានៃព្រះយស ហៅថា បឋមឧបាសិកា ។

១៧៥ - ស. កាលព្រះសាស្ដាគង់ក្នុងព្រៃឥសិបតនមិគទាយវ័នស្ងាត់តែមួយព្រះអង្គឯងនោះ តើមារាធិរាជចូលទៅក្រាបទូលព្រះអង្គថាដូចម្ដេច ?

ឆ. ចូលទៅក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ! ព្រះអង្គបានរួចចាកមារពន្ធន៍ទាំងពួងហើយ ប៉ុន្តែព្រះអង្គគង់មិនរួចពីដៃខ្ញុំទេ" ។ ព្រះសាស្ដាត្រាស់តបថា "ម្នាលមារអើយ ! សេចក្ដីប្រាថ្នានៃកាមគុណក្នុងរូប សំឡេង ក្លិន រស សម្ផស្សមិនមានឡើយ តថាគតអាចកំចាត់បង់នូវមច្ចុមារបាន" ។ មារស្ដាប់ហើយក៏កើតទុក្ខតូចចិត្តត្រឡប់វិលទៅវិញ ។

www.budinst.gov.kh www.elibraryofcambodia.org

# ឧរុវេលាគមនៈ

១៧៦– ស. កាលព្រះសាស្តាចេញពីព្រៃឥសិបតនមិគទាយវិញហើយ ទ្រង់យាងទៅគង់ក្នុងទីណាទៀត ?

ប. ទ្រង់យាងទៅគង់ក្នុងឧរុវេលាប្រទេស ។

១៧៧- ស. កាលទ្រង់យាងទៅតាមផ្លូវបានប្រោសអ្នកណាដែរ ?

ប. បានប្រោសភទ្ទវគ្គិយកុមារ ៣០ នាក់ក្នុងព្រៃកប្បាស ឲ្យបានជាឯហិភិក្ខុឧបសម្បទា ។

១៧៨- ស. កាលព្រះសាស្តាគង់ក្នុងឧរុវេលាប្រទេសបានប្រោសអ្នកណាខ្លះ ?

ប. ប្រោសជដិល ៣ នាក់ជាបងប្អូននឹងគ្នាគឺ ឧរុវេលកស្សបៈ មានបរិវារ ៥ រយ , នទីកស្សបៈ មានបរិវារ ៣ រយ , គយាកស្សបៈមានបរិវារ ២ រយ ឲ្យបានសម្រេចជាឯហិភិក្ខុឧបសម្បទា ទាំង ៣ នាក់នឹងបរិវារទាំងអស់ផង ។

១៧៩– ស. ព្រះសាស្តាសំដែងបាដិហារ្យចំនួនប៉ុន្មាន? ហើយទេសនាធម៌អ្វី ក្នុងកាលដែលប្រោសជដិលទាំងនោះ ?

ប. ទ្រង់សំដែងបាដិហារ្យ ចំនួន១.៥០០យ៉ាង ។ ទ្រង់ទេសនាអាទិត្តបរិយាយសូត្រ ។

7

www.budinst.gov.kh www.elibraryofcambodia.org

១៨០ សំ. កាលព្រះសាស្តាប្រោសជដិលរួចហើយ ទ្រង់យាង ទៅប្រោសអ្នកណាទៀត ?

ឆ. ទ្រង់យាងទៅប្រោសព្រះបាទពិម្ពិសារ ក្សត្រក្រុងរាជគ្រឹះ ព្រមទាំងព្រាហ្មណ៍និងគហបតី ១១ ម៉ឺននាក់ឲ្យបានសម្រេចសោតាបត្តិផល, ព្រាហ្មណ៍និងគហបតី ១ ម៉ឺនទៀត បានស្ថិតនៅក្នុងព្រះត្រៃសរណគមន៍ ។

១៨១ - សំ. ព្រះសាស្តាទ្រង់ទេសនាធម៌អ្វីប្រោសព្រាហ្មណ៍ និងគហបតីទាំងនោះ ?

ឆ. ទ្រង់ទេសនាមហានារទជាតក ដោយពិស្តារ ។

## អគ្គសាវកបព្វជ្ជា

១៨២ - សំ. ព្រះអគ្គសាវ័ករបស់ព្រះសាស្តា គឺអ្នកណា ? លោកមានគុណវិសេសជាយ៉ាងសំខាន់ដល់សាសនាដូចម្តេច បានជាព្រះសាស្តាទ្រង់តាំងទុកក្នុងដំណែងដ៏សំខាន់ដូច្នោះ ?

ឆ. គឺព្រះសារីបុត្រ និងព្រះមោគ្គល្លាន ។ លោកបានជាកម្លាំងរបស់ព្រះសាស្តាក្នុងការប្រកាសផ្សាយសាសនា ញុំាងមហាជនឲ្យកើតសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាជាច្រើន ។ សូម្បីព្រះសាស្តាក៏បានសរសើរលោកទាំងពីរព្រះអង្គនោះ ដោយឧបមាថា ព្រះសារីបុត្រប្រៀប

www.budinst.gov.kh www.elibraryofcambodia.org

ដូចមាតាអ្នកញុំាងទារកឲ្យកើត, មោគ្គល្លាន ប្រៀបដូចស្រីមេដោះចិញ្ចឹមទារកដែលកើតហើយនោះ ។ សារីបុត្ររមែងដឹកនាំមហាជនឲ្យតាំងនៅក្នុងសោតាបត្តិផល, មោគ្គល្លាន រមែងដឹកនាំមហាជនឲ្យតាំងនៅក្នុងគុណខាងលើដែលខ្ពង់ខ្ពស់ជាងនោះទៅទៀត ។

បើនិយាយឲ្យចំទៅថា ព្រះសារីបុត្រព្រះសាស្តាទ្រង់លើកដំកើងថាប្រសើរជាងគេខាងផ្លូវបញ្ញា តាមសំដែងធម្មចក្រ និងចតុរារិយសច្ចឲ្យព្រាយខ្ចាយពិស្តារបានដូចជាព្រះអង្គដែរ តាំងជាអ្នកឈ្លាសវៃក្នុងការទេសនាទូន្មានមហាជន ។ ចំណែកព្រះមោគ្គល្លានព្រះសាស្តាទ្រង់លើកដំកើងសរសើរថា ជាអ្នកមានឫទ្ធិច្រើន តាមធ្វើអ្វីៗបានដូចសេចក្តីប្រាថ្នា តាំងជាអ្នកឈ្លាសវៃក្នុងការដឹកនាំត្រកូលដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាបាន មិនធ្វើសព្វនឹងទ្រព្យសម្បត្តិរបស់គាយកឲ្យខូចខាត ដូចជាមេឃ្មុំដែលហើរចូលទៅក្នុងសួនផ្កាមិនធ្វើពណ៌នឹងក្លិនរបស់ផ្កាឲ្យជាំជាំឲ្យបាត់បង់ គ្រាន់តែក្រេបផ្អាក់យកតែទឹកជារសហើយហើរបាត់ទៅ ព្រះសាស្តាទ្រង់ត្រាស់ប្រដៅឲ្យភិក្ខុឯទៀតប្រព្រឹត្តយកតាមជាគំរូ ។

១៨៣ – សំ. ព្រះសារីបុត្រនិងព្រះមោគ្គល្លានបានបួសក្នុងលទ្ធិដទៃរួចទៅហើយ ហេតុអ្វីក៏បានជាលះបង់លទ្ធិនោះចោលទៅវិញ ហើយចូលមកបួសក្នុងព្រះពុទ្ធសាសនា ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ហេតុតែលោកមានប្រក្រតីជាអ្នកភ្ញាក់រឭកជានិច្ចមិនភ្លេចខ្លួន បានបួសក្នុងលទ្ធិរបស់អាចារ្យសញ្ជ័យវេលដ្ឋបុត្រ ហើយមិនបានសម្រេចមោក្ខធម៌ ក៏ធ្វើកតិកានឹងគ្នាថា បើអ្នកណាបានមោក្ខធម៌មុន អ្នកនោះចូរប្រាប់ដល់អ្នកម្នាក់ទៀត ។ ថ្ងៃមួយព្រះសារីបុត្របានទៅជួបនឹងព្រះអស្សជិត្ថេរ ក៏មានចិត្តជ្រះថ្លានឹងឥរិយាបថរបស់លោកបានសាកសួរដឹងថាលោកជាពុទ្ធសាវកហើយ ក៏អារាធនាឲ្យលោកសំដែងធម៌ ។ ព្រះ-អស្សជិត្ថេរបានសំដែងប្រាប់ត្រង់គោលព្រះពុទ្ធសាសនាថា "ធម៌ទាំងឡាយណាកើតឡើងព្រោះហេតុ រមែងរលត់ទៅវិញក៏ព្រោះរលត់ហេតុ" ។ ព្រះសារីបុត្រស្តាប់ធម៌នេះចប់ហើយក៏បានធម្មចក្ខុ ទើបត្រឡប់មកដំណាលប្រាប់ព្រះមោគ្គល្លាន ។ បានស្តាប់ធម៌នោះ ហើយក៏បានធម្មចក្ខុដូចគ្នា ទើបបបួលគ្នាចូលទៅគាល់ព្រះសាស្តា ។

១៨៤- សំ. អារាមឈ្មោះអ្វីដែលកើតមានឡើងជាដំបូងក្នុងព្រះពុទ្ធ-សាសនា ? កើតនៅប្រទេសណា ? អ្នកណាជាអ្នកថ្វាយ ។ ក្នុងវេលាណា ?

ឆ. អារាមឈ្មោះវេឡុវ័នគឺជាទីព្រះរាជឧទ្យានព្រៃឫស្សីតាំងនៅជិតក្រុងរាជគ្រឹះ ក្នុងដែនមគធៈ ជាទីស្ងប់ស្ងាត់សមគួរដល់សមណៈ ។ ព្រះបាទពិម្ពិសារ ក្សត្រក្រុងរាជគ្រឹះជាអ្នកថ្វាយ ។ ក្នុងវេលាដែលព្រះសាស្តាព្រមដោយភិក្ខុសង្ឃ យាងទៅទទួលភត្តាហារក្នុងព្រះរាជនិវេសន៍

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងកាលព្រះសាស្ដាស្ដេចទៅក្នុងដែនមគធៈ ដើម្បីប្រកាសព្រះសាសនាជាដំបូង ។

១៨៥– សំ. ព្រះនាមដើមរបស់ព្រះសារីបុត្រ និងព្រះមោគ្គល្លាន ហៅថាអ្វី ? លោកកើតនៅស្រុកណា ? ជាបុត្រអ្នកណា ?

ឆ. ព្រះនាមដើមរបស់ព្រះសារីបុត្រ ហៅថា ឧបតិស្សៈ លោកកើតក្នុងឧបតិស្សគ្រាម ជាបុត្រនៃនាងសារីព្រាហ្មណី ។ ព្រះនាមដើមរបស់ព្រះមោគ្គល្លាន ហៅថា កោលិតៈ លោកកើតក្នុងកោលិតគ្រាម ជាបុត្រនៃនាងមោគ្គល្លី ។

១៨៦– សំ. ចុះកាលព្រះសារីបុត្រនិងព្រះមោគ្គល្លាន ចូលទៅសូមបព្វជ្ជាឧបសម្បទាក្នុងសំណាក់ព្រះសាស្ដានោះ តើបាននាំបរិវារប៉ុន្មាននាក់ទៅផង ?

ឆ. បាននាំបរិវារ ២៥០ នាក់ទៅផង ។

១៨៧– សំ. បណ្ដាព្រះអគ្គសាវកទាំង ២ ព្រះអង្គ, លោកណាបានសម្រេចព្រះអរហត្តមុន? ព្រោះបានស្ដាប់ធម៌អ្វី ?

ឆ. ព្រះមោគ្គល្លានបានសម្រេចព្រះអរហត្តមុន តាំងពីថ្ងៃដែលលោកបួសមកបាន ៧ ថ្ងៃ ។ ព្រោះបានស្ដាប់ធាតុកម្មដ្ឋាន ក្នុងវេលាដែលលោកទៅគង់នៅក្នុងស្រុកកល្លវាឡគ្រាមក្នុងដែនមគធៈ ។ ឯព្រះ

សារីបុត្របានសម្រេចព្រះអរហត្តក្រោយ គឺរាប់ពីថ្ងៃដែលលោកបួសមកបាន ១៥ ថ្ងៃ ព្រោះបានស្តាប់វេទនាបរិគ្គហសូត្រ ដែលព្រះសាស្តាកំពុងសំដែងប្រោសទីឃនខបរិព្វាជកជាក្មួយរបស់ខ្លួនក្នុងគុហារឈ្មោះសូករខាតៈ ។

១៨៨– ស. ចុះព្រះសារីបុត្រមានបញ្ញាច្រើនណាស់ ហេតុអ្វីក៏បានជាសម្រេចព្រះអរហត្តក្រោយព្រះមោគ្គល្លានទៅវិញ ?

ប. ហេតុតែលោកមានគំនិតល្អិតជ្រាលជ្រៅទៅទៀត ព្រះទ័យលោកមិនបានស្ទុះចុះទៅក្នុងធម៌តែមួយ ប្រៀបដូចអ្នកដំណើរដើរទៅម្នាក់ឯងបានឆាប់រហ័ស បើទៅគ្នាច្រើនរមែងយឺតយូរព្រោះរង់ចាំឲ្យជួបជុំគ្នា ។

១៨៩– ស. ព្រះសាស្តាទ្រង់តាំងព្រះអគ្គសាវ័កទាំងគូ ព្រមទាំងទ្រង់សំដែងឱវាទបាតិមោក្ខនៅទីណា ? ក្នុងថ្ងៃ-ខែ-ឆ្នាំអ្វី ?

ប. ក្នុងវត្តវេឡុវ័ន ក្បែរក្រុងរាជគ្រឹះ ដែនមគធៈ ។ នៅថ្ងៃ ១៥ កើតខែមាឃ ឆ្នាំរក ។

## កបិលវត្ថុគមនៈ

១៩០– ស. កាលព្រះសាស្តាគង់ក្នុងវត្តវេឡុវ័ននោះ តើព្រះបាទសុទ្ធោទនៈប្រើអាមាត្យប៉ុន្មាននាក់ ? ហើយប៉ុន្មានដងឲ្យទៅនិមន្តព្រះសាស្តាមកកាន់ក្រុងកបិលពស្តុ ?

www.budinst.gov.kh www.elibraryofcambodia.org

ឫ. ព្រះរាជាប្រើអាមាត្យ ១០ នាក់ ក្នុងម្នាក់ ៗ មានបរិវារ ១ ពាន់ ៗ ប្រើឲ្យទៅ ១០ ដង គឺ ១ នាក់ ១ ដង ៗ

១៩១– ស. ចុះអាមាត្យទាំងអស់នោះ បានបួសបានសម្រេចធម៌អ្វីដែរឬទេ ?

ឫ. អាមាត្យទាំងអស់នោះ បានបួសហើយបានសម្រេចព្រះអរហត្តផលជាឯហិភិក្ខុឧបសម្បទា ។

១៩២– ស, ព្រះថេរៈអង្គណាដែលបានទូលនិមន្តព្រះសាស្តាឲ្យយាងទៅកាន់ក្រុងកបិលពស្តុ ?

ឫ. ព្រះកាឡុទាយិត្ថេរ ដែលជាអាមាត្យគំរប់ដប់ទៅក្រោយអាមាត្យទាំងអស់ បានទូលនិមន្តព្រះសាស្តា ។

១៩៣– ស. កាលព្រះសាស្តាយាងទៅដល់នគរកបិលពស្តុហើយទ្រង់គង់នៅទីណា ? មានព្រះសង្ឃជាបរិស័ទប៉ុន្មានអង្គ ?

ឫ. ព្រះអង្គគង់ក្នុងនិគ្រោធារាម ។ មានព្រះសង្ឃជាបរិស័ទ ២ ម៉ឺនអង្គសុទ្ធតែជាព្រះខីណាស្រព ។

១៩៤– ស. ព្រះសាស្តាទ្រង់ប្រោសព្រះញាតិវង្សដោយវិធីដូចម្តេច ?

ឫ. ដោយវិធីធ្វើយមកប្បាដិហារ្យ គឺទ្រង់និម្មិតទីចង្ក្រមកែវ

ហើយ យាងចង្ក្រមក្នុងអាកាសទ្រង់និម្មិតជាព្រះពុទ្ធមួយព្រះអង្គទៀតឲ្យឆ្លើយប្រស្នារបស់ព្រះអង្គ ។ នៅទីបំផុតទ្រង់យាងចុះពីអាកាសមកហើយត្រាស់ទេសនាមហាវេស្សន្តរជាតក ព្រោះទ្រង់ប្រារព្ធភ្លៀងបោក្ខរពស្សឲ្យជាដើមហេតុ ។

១៩៥– សំ. ចុះព្រះពុទ្ធបិតាបានសម្រេចមគ្គផលអ្វី? បានទ្រង់ព្រះផ្នួសឬទេ?

ប. កាលជួបនឹងព្រះសាស្តាគ្រាដំបូងបានសម្រេចព្រះ-អនាគាមិផល លុះដល់ជិតនឹងអស់ព្រះជន្ម ក៏បានសម្រេចព្រះអរហត្ត-ផល ហើយបរិនិព្វានទៅ ។ ព្រះអង្គមិនបានទ្រង់ព្រះផ្នួសទេ ។

## ពិម្ពាពិលាប

១៩៦– សំ. ក្នុងថ្ងៃទីពីរ ១/ ព្រះសាស្តាបានប្រោសអ្នកណា ឲ្យបានសម្រេចមគ្គផលអ្វី? ដោយទេសនាធម៌អ្វី?

ប. បានប្រោសព្រះនាងបជាបតីគោតមី ជាព្រះមាតុច្ឆា, ឲ្យបានសម្រេចព្រះសោតាបត្តិផល, ដោយទេសនាមហាធម្មបាលជាតក ។

១៩៧– សំ. ក្នុងថ្ងៃទីបី ព្រះសាស្តាទ្រង់ប្រោសអ្នកណា? ឲ្យបានសម្រេចមគ្គផលអ្វី? ដោយទេសនាធម៌អ្វី?

---

១– ថ្ងៃដែលព្រះអង្គស្តេចទៅដល់ក្រុងកបិលព័ស្តុរាប់ជាថ្ងៃទី១ ថ្ងៃបន្ទាប់មករាប់ជាថ្ងៃទី២ ។

www.budinst.gov.kh www.elibraryofcambodia.org

ប. បានប្រោសព្រះនាងពិម្ពាជាមាតាព្រះរាហុលកុមារ, ឲ្យបានសម្រេចព្រះសោតាបត្តិផល, ដោយទេសនាចន្ទកិន្នរីជាតក ។

## សាក្យបព្វជ្ជា

១៩៨- ស. ក្នុងថ្ងៃជាគំរប់បួន ព្រះសាស្ដាបានប្រោសអ្នកណា? ឲ្យបានសម្រេចមគ្គផលអ្វី?

ប. បានប្រោសព្រះនន្ទកុមារ គឺក្នុងថ្ងៃដែលព្រះនន្ទកុមារកំពុងតែធ្វើវិវាហមង្គលជាមួយនឹងនាងជនបទកល្យាណី ព្រះសាស្ដាទ្រង់នាំព្រះនន្ទកុមារទៅឯវត្តនិគ្រោធារាម ហើយទ្រង់បំបួសព្រះនន្ទកុមារ ។ ដល់ថ្ងៃក្រោយមកព្រះនន្ទបានសម្រេចព្រះអរហត្តផល ។

១៩៩- ស. ចុះព្រះនន្ទត្រូវជាព្រះញាតិនឹងព្រះសាស្ដាដូចម្ដេច?

ប. ត្រូវជាព្រះកនិដ្ឋភាតា គឺប្អូនបង្កើតរបស់ព្រះសាស្ដារួមព្រះបិតាជាមួយ ឯព្រះមាតាផ្សេងគ្នា ។

២០០- ស. ចុះព្រះមាតារបស់ព្រះនន្ទព្រះនាមអ្វី? ត្រូវជាអ្វីនឹងព្រះសាស្ដា?

ប. ព្រះនាមព្រះនាងមហាបជាបតិគោតមី, ត្រូវជាព្រះមាតុច្ឆា គឺម្ដាយមីងរបស់ព្រះសាស្ដា ។

www.budinst.gov.kh www.elibraryofcambodia.org

២០១– សំ. ថ្ងៃក្រោយមក ព្រះសាស្ដាបានប្រោសអ្នកណាទៀត ?

ឆ. រាប់តាំងពីថ្ងៃដែលព្រះសាស្ដាបំបួសព្រះនន្ទមកបាន ៧ ថ្ងៃ ព្រះអង្គទ្រង់បង្គាប់ព្រះសារីបុត្រឲ្យបំបួសព្រះរាហុលកុមារជាសាមណេរក្នុងថ្ងៃដែលព្រះរាជកុមារតាមសូមកំណប់ទ្រព្យពីព្រះអង្គ ។

២០២– សំ. វត្តជេតពន នៅក្នុងនគរណា ? អ្នកណាកសាងថ្វាយព្រះសាស្ដា ?

ឆ. នៅក្នុងនគរសាវត្ថី ។ អនាថបិណ្ឌិកសេដ្ឋីកសាងថ្វាយ ។

២០៣– សំ. មានក្សត្រសាក្យត្រកូលប៉ុន្មានព្រះអង្គ បានចេញទ្រង់ព្រះផ្នួសក្នុងសំណាក់ព្រះសាស្ដា ?

ឆ. មាន ៦ ព្រះអង្គ គឺ ភទ្ទិយៈ១, អនុរុទ្ធ១, ភគុ១, កិម្ពិលៈ១, អានន្ទ១, ទេវទត្ត១ ។

២០៤– សំ. ចុះបណ្ដាលោកទាំង ៦ ព្រះអង្គនេះ អង្គណាបានសម្រេចគុណវិសេសដូចម្ដេច ?

ឆ. ព្រះភទ្ទិយៈបានសម្រេចវិជ្ជា ៣, ព្រះអនុរុទ្ធបានទិព្វចក្ខុ សម្រេចព្រះអរហត្តផល, ព្រះភគុ និង ព្រះកិម្ពិលៈ បានសម្រេចព្រះអរហត្តផល, ព្រះអានន្ទ បានសម្រេចព្រះសោតាបត្តិផល, ព្រះទេវទត្ត បានឫទ្ធិជារបស់បុថុជ្ជន ។

www.budinst.gov.kh www.elibraryofcambodia.org

# មេត្តេយ្យព្យាករណ៍

២០៥–ស. កាលព្រះសាស្តាយាងមកកាន់នគរកបិលពស្តុ ក្នុងលើកទី ២ គង់ក្នុងនិគ្រោធារាម មានអ្នកណាយកវត្ថុអ្វីទៅថ្វាយព្រះអង្គដែរឬទេ ?

ឆ. មាន គឺព្រះនាងមហាបជាបតិគោតមី ជាព្រះមាតុច្ឆារបស់ព្រះអង្គបានយកសំពត់សាដកពីរផ្ទាំងមកថ្វាយ, ក្នុងមួយផ្ទាំងៗ បណ្តោយ ១៤ ហត្ថ ទទឹង ៩ ហត្ថដូចគ្នា ។ សំពត់នេះព្រះនាងធ្វើដោយព្រះហស្តឯង តាំងពីដាំកប្បាសមក ដរាបដល់តម្បាញបានជាសាច់សំពត់ ។

២០៦–ស. ព្រះសាស្តាទ្រង់ទទួលសំពត់ពីព្រះនាងឬទេ?

ឆ. មិនទទួលទេ, ទ្រង់បង្គាប់ឲ្យព្រះនាងថ្វាយដល់សង្ឃវិញ ។

២០៧–ស. ចុះភិក្ខុអង្គណាទទួលសំពត់នោះ ?

ឆ. ព្រះអជិតភិក្ខុទើបនឹងបួសថ្មី គង់ចុងអាសនបំផុតបានទទួលសំពត់នោះ ។

២០៨–ស. ចុះព្រះអជិតភិក្ខុនោះ តើជាបុត្រលោកណា? នៅអនាគតនឹងបានជាអ្វី ?

www.budinst.gov.kh www.elibraryofcambodia.org

ព. ព្រះអជិតភិក្ខុ ជាព្រះរាជបុត្រនៃព្រះនាងកាញ្ចនា ជាអគ្គមហេសី នៃព្រះបាទអជាតសត្តុរាជ; ទៅអនាគតលោកនឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមជា មេត្តេយ្យៈ ក្នុងភទ្ទកប្បនេះ ។

## ពុទ្ធបិតុនិព្វាន

២០៩– ស. ព្រះសាស្ដាត្រាស់ដឹងបានប៉ុន្មានវស្សា ទើបព្រះពុទ្ធបិតានិព្វាន ? ហើយអ្នកណាថ្វាយព្រះភ្លើងព្រះពុទ្ធបិតា ?

ព. បាន ៥ វស្សា ។ ព្រះសាស្ដាទ្រង់បង្គាប់ឲ្យព្រះមហាកស្សបត្ថេរ តាក់តែងជើងថ្ករស្រេចហើយ ព្រះអង្គលើកព្រះសិរនៃព្រះបិតាដោយព្រះហស្ត ព្រះអង្គទ្រង់ស្រោចដោយសុគន្ធវារីរួចលើកព្រះបរមសពដាក់ក្នុងមឈូសរតន៍ ទើបព្រះសាស្ដាលើកមឈូសដោយព្រះអង្គឯងនាំទៅតម្កើងបូជា ទ្រង់ថ្វាយព្រះភ្លើងដោយព្រះអង្គឯង ។

២១០– ស. ព្រះនាងមហាបជាបតីគោតមី បានទូលសូមបព្វជ្ជាក្នុងសំណាក់ព្រះសាស្ដាប៉ុន្មានដង ? នៅទីណាខ្លះ ?

ព. ព្រះនាងទូលសូម ៣ ដង ។ សូមដំបូងក្នុងនិគ្រោធារាម ព្រះសាស្ដាមិនអនុញ្ញាត, សូមទីពីរក្នុងកូដាគារសាលាព្រៃមហាវ័ន បានព្រះអានន្ទជួយអង្វរផង ព្រះអង្គក៏នៅមិនទ្រង់អនុញ្ញាតទៀត, សូមទីបីក្នុងវត្តជេតពននគរសាវត្ថី បានព្រះអានន្ទជួយអង្វរទៀត ព្រះសាស្ដាក៏អនុញ្ញាតឲ្យបព្វជ្ជាឧបសម្បទា ដោយគរុធម៌ ៨ ប្រការ ។

www.budinst.gov.kh www.elibraryofcambodia.org

២១១– ស. ព្រះនាងសូមបព្វជ្ជាតែមួយព្រះអង្គឯងឬទេ?

ប. នាងខត្តិយកញ្ញា ៥០០ នាក់ ជាបរិវារបានបព្វជ្ជាជាមួយនឹងព្រះនាងដែរ ។

# យមកប្បាដិហារ្យ

២១២– ស. កាលព្រះសាស្តាទ្រង់ធ្វើយមកប្បាដិហារ្យផ្ចាញ់ពួកអន្យតិរ្ថិយនិគ្រន្ថនោះ តើព្រះអង្គគង់ក្នុងទីណា?

ប. ព្រះអង្គគង់ក្នុងវត្តជេតពនក្បែរក្រុងសាវត្ថី ។

២១៣– ស. គ្រូទាំង ៦ នាក់ ដែលធ្វើបាដិហារ្យប្រឡងនឹងព្រះសាស្តានោះតើឈ្មោះអ្វីខ្លះ?

ប. គ្រូទាំង ៦ នាក់នោះ គឺឈ្មោះ បូរណកស្សបៈ ១, មក្ខលិគោសាល ១, និគ្គណ្ឋនាដបុត្រ ១, សញ្ជយវេលដ្ឋបុត្រ ១, បកុធកច្ចាយនៈ ១, អជិតកេសកម្ពលៈ ១ ។

២១៤– ស. មានរឿងដូចម្តេចបានជាព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទមិនឲ្យសាវកធ្វើបាដិហារ្យ ?

ប. មានរឿងដំណាលថា៖ កាលដែលសេដ្ឋីព្យួរបាត្រខ្លឹមចន្ទន៍ ដើម្បីចង់ល្បងឲ្យដឹងថា បើមានលោកណាជាព្រះអរហន្តមែន សូមឲ្យលោកនោះហោះទៅយកបាត្រនោះចុះ ។ វេលានោះព្រះមោគ្គល្លាន-

www.budinst.gov.kh www.elibraryofcambodia.org

ភ្លុះ ប្រើព្រះបិណ្ឌោលភារទ្វាជត្ថេរ ឲ្យសំដែងបាដិហារ្យហោះអាកាស ហើយ ហោះទៅយកបាត្រនោះបានមក ។

## ទេសនាបរិវត្តន៍

២១៥– សួ. កាលព្រះសាស្ដាធ្វើយមកបាដិហារ្យផ្ចាញ់ពួកតិរ្ថិយ ស្រេចហើយ ទ្រង់យាងទៅគង់ចាំវស្សា នៅទីណា ? ដើម្បីប្រយោជន៍អ្វី ?

ឆ. គង់ក្នុងតាវត្តិង្សពិភព, ដើម្បីទេសនាព្រះអភិធម្ម ប្រោសព្រះពុទ្ធមាតា ។

២១៦ សួ. ព្រះសាស្ដាគង់ក្នុងស្ថានតាវត្តិង្សចំនួនប៉ុន្មានខែក្នុង មនុស្សលោក ? លុះចប់ទេសនាហើយ ព្រះពុទ្ធមាតាបានសម្រេចមគ្គផល អ្វី ?

ឆ. ចំនួន ៣ ខែ ។ បានសម្រេចព្រះសោតាបត្តិផល ។

## ទេវោរោហនបរិវត្តន៍

២១៧– សួ. ព្រះសាស្ដាយាងចុះចាកទេវលោកដោយអ្វី ? មកគង់ក្នុង ទីណា ?

ឆ. ដោយជណ្ដើរទិព្វ ៣ ដែលព្រះឥន្ទនិម្មិតថ្វាយ គឺខាង ឆ្វេងជណ្ដើរមាស, ខាងស្ដាំជណ្ដើរប្រាក់, កណ្ដាលជណ្ដើរកែវ ។ មកគង់ ក្បែរទ្វារនៃនគរសង្កស្ស ។

www.budinst.gov.kh www.elibraryofcambodia.org

# អគ្គសាវកនិព្វាន

២១៨– ស. ព្រះសារីបុត្រ នឹងព្រះមោគ្គល្លាន លោកណានិព្វានមុន ? ហើយលោកណានិព្វានក្នុងទីណា ?

ឆ. ព្រះសារីបុត្រនិព្វានមុន លោកនិព្វានក្នុងនាលន្ទគ្រាម ជាលំនៅនៃមាតារបស់លោក ក្នុងបន្ទប់ដែលលោកប្រសូត ។ ចំណែកព្រះមោគ្គល្លាននិព្វានក្រោយព្រះសារីបុត្រ លោកទៅនិព្វានក្នុងកាឡសិលាប្រទេស ។

២១៩– ស. ព្រះអគ្គសាវកទាំងពីរព្រះអង្គនោះ និព្វានមុនព្រះសាស្ដា ឬក្រោយ ? ហេតុអ្វីបានជាដូច្នោះ ?

ឆ. លោកនិព្វានមុនព្រះសាស្ដា ។ ហេតុតែតាមធម្មតានៃព្រះពុទ្ធពីបុរាណមក ។

២២០– ស. មាតាព្រះសារីបុត្របានសម្រេចមគ្គផលអ្វីដែរឬទេ ?

ឆ. បានសម្រេចព្រះសោតាបត្តិផល ។

២២១– ស. ព្រះសារីបុត្រ នឹងព្រះមោគ្គល្លាននិព្វាន ក្នុងថ្ងៃ-ខែណា ?

ឆ. ព្រះសារីបុត្រនិព្វានក្នុងថ្ងៃ ១៥ កើតខែកត្តិក, ព្រះមោគ្គល្លាននិព្វានក្នុងថ្ងៃ ១៥ រោចខែកត្តិក ។

www.budinst.gov.kh www.elibraryofcambodia.org

# ពុទ្ធបរិនិព្វាន

២២២ - សួ. ចូរប្រាប់ព្រះជន្មាយុនៃព្រះសាស្ដាក្នុងវយៈកាលនេះគឺ កាលស្ដេចចេញបព្វជ្ជា កាលត្រាស់ដឹង កាលបរិនិព្វាន ?

ឆ. កាលស្ដេចចេញបព្វជ្ជាព្រះជន្មាយុបាន ២៩ ឆ្នាំ, កាលបានត្រាស់ដឹងព្រះជន្មាយុបាន ៣៥ ឆ្នាំ, កាលស្ដេចចូលបរិនិព្វានព្រះជន្មាយុបាន៨០ឆ្នាំ ។

២២៣ - សួ. តាំងពីព្រះសាស្ដាត្រាស់ដឹងហើយ ដល់បរិនិព្វានរួមវស្សាបានប៉ុន្មាន ? ព្រះជន្មប៉ុន្មាន ?

ឆ. បាន ៤៥ វស្សា ។ ព្រះជន្ម ៨០ ឆ្នាំ ។

២២៤ - សួ. ក្នុងវស្សាគំរប់ ៤៥ ព្រះសាស្ដាគង់ចាំវស្សាក្នុងទីណា ?

ឆ. ក្នុងស្រុកវេឡុវគ្រាម ។

២២៥ - សួ. ក្នុងរវាង ៤៥ វស្សានោះ ព្រះសាស្ដាទ្រង់បំពេញពុទ្ធកិច្ចប៉ុន្មានប្រការ ? គឺអ្វីខ្លះ ?

ឆ. ទ្រង់បំពេញពុទ្ធកិច្ច ៥ ប្រការ ។ គឺ: ក្នុងវេលាព្រឹកយានទៅបិណ្ឌបាត១, ក្នុងវេលារសៀលទ្រង់ទេសនាប្រោសមហាជន ១, ក្នុង-វេលាព្រលប់ទ្រង់ប្រទានឱវាទចំពោះតែពួកភិក្ខុ ១, ក្នុងវេលាកណ្ដាល

www.budinst.gov.kh www.elibraryofcambodia.org

អធ្រាត្រទ្រង់ដោះស្រាយប្រស្នានៃពួកទេវតា១, ដល់វេលាបែកបច្ចូស ទ្រង់ប្រមើលមើលនូវសត្វដែលមានភ័ព្វ និងផលភ័ព្វ ១ ។

២២៦- សំ. ក្នុងរវាងដែលទ្រង់បំពេញពុទ្ធកិច្ចនោះ បានស្ដេចចារិកទៅក្នុងនគរណាខ្លះ ?

ឆ. កាលព្រះអង្គគង់ព្រះជន្មនោះ បានស្ដេចចារិកទៅក្នុងនគរផ្សេងៗជាច្រើន គឺនគរពារាណសី ១, នគររាជគ្រឹះ ១, នគរសាវត្ថី ១, នគរកបិលព័ស្តុ ១, នគរវេសាលី ១, នគរបាដលិបុត្រ ១, នគរកោសម្ពី១, នគរវេរញ្ជា ១, នគរកុសិនារា១, នគរអាឡវី១, នគរសាកេត១, នគរចម្ប៉ា ១, នគរវេឋទីបកៈ ១, នគរអល្លកប្បៈ ១, នគរមោរិយៈ១ ។

២២៧- សំ. កាលព្រះសាស្ដាដាក់អាយុសង្ខារទ្រង់គង់ក្នុងទីណា ? ក្នុងថ្ងៃ-ខែ-ឆ្នាំអ្វី ? ដោយមានអ្នកណាក្រាបទូលអារាធនា ?

ឆ. លុះចេញវស្សាជាគំរប់ ៤៥ ហើយ ព្រះសាស្ដាយាងទៅគង់ក្នុងចាបាលចេតិយ, ទ្រង់ដាក់អាយុសង្ខារក្នុងថ្ងៃពេញបូណ៌មីខែមាឃ, ឆ្នាំម្សាញ់បញ្ចស័ក; ដោយមានមារាធិរាជក្រាបទូលអារាធនាឲ្យព្រះអង្គបរិនិព្វាន ។

២២៨- សំ. ព្រះសាស្ដាបរិនិព្វានក្នុងទីណា? ក្នុងថ្ងៃ-ខែ-ឆ្នាំអ្វី ? ក្នុងព្រះជន្មគំរប់ប៉ុន្មាន ?



www.budinst.gov.kh www.elibraryofcambodia.org

ឆ. ក្នុងសាលវ័នឧបវត្តន ចន្លោះដើមរាំងទាំងគូ(១) ក្បែរក្រុងកុសិនារា, ក្នុងថ្ងៃពេញបូណ៌មីខែវិសាខ ឆ្នាំម្សាញ់ វេលារាត្រីជិតភ្លឺ, ក្នុងព្រះជន្ម ៨០ ឆ្នាំគត់ ។

២២៩ – សំ. ក្នុងថ្ងៃព្រះសាស្ដាបរិនិព្វាន មានសាវ័កជាធំប៉ុន្មានរូប ដែលជាប្រធាននៅក្នុងទីនោះ ? អ្នកណាជាម្ចាស់ចាត់ការព្រះសព ? តំកល់ព្រះសពក្នុងទីណា ?

ឆ. មានព្រះសាវ័កជាធំពីររូប គឺព្រះអនុរុទ្ធត្ថេរ នឹងព្រះអានន្ទត្ថេរ ជាប្រធាននៅក្នុងទីនោះ ។ ពួកមល្លក្សត្រក្រុងកុសិនារា ជាម្ចាស់ចាត់ការព្រះសព ។ ព្រះសពតំកល់នៅក្នុងមកុដពន្ធនចេតិយខាងទិសបូព៌ានៃក្រុងកុសិនារា ។

២៣០ – សំ. ព្រះសាស្ដាប្រឈួនព្រះរោគអ្វី មុននឹងនិព្វាន ? គេដំកល់ព្រះសពទុកប៉ុន្មានថ្ងៃទើបថ្វាយព្រះភ្លើង ?

ឆ. ប្រឈួនព្រះរោគចុះព្រះលោហិត ឬហៅថាបក្ខន្ទិកាពាធ ។ គេដំកល់ព្រះសពទុក ៧ ថ្ងៃទើបថ្វាយព្រះភ្លើង ។

---

១- យមកសាលា តាមទំលាប់ ប្រែថា «ដើមរាំងទាំងគូ» តែសម្ដេចសង្ឃនាយក ជួន-ណាត កាលនិមន្តទៅដំណើរទៅមើលក្រុងកន្លែងនោះ ឃើញថាមិនមែនជាដើមរាំងដូចសំ ដល់សួរអ្នកស្រុក ៗ ថា សាលព្រឹក្សនុំឈ្មោះយមកសាលា ត្រូវប្រែថា «សាលព្រឹក្សទាំងគូ» វិញ ។

www.budinst.gov.kh www.elibraryofcambodia.org

២៣១– ស. កាលព្រះសាស្តាជិតបរិនិព្វាន អ្នកណាចូលទៅសួរប្រស្នា? ហើយបានជាអ្វី ?

ច. សុភទ្ទបរិញ្វាជក បានចូលទៅក្រាបទូលសួរប្រស្នា, លុះចប់ធម៌ទេសនាបានសម្រេចព្រះអរហត្តផល ជាបច្ឆិមសាវ័ក ។

២៣២– ស. កាលជិតនឹងបរិនិព្វាន ព្រះសាស្តាបានប្រទានព្រះបរមពុទ្ធោវាទជាទីបំផុតជាដូចម្តេច ?

ច. ព្រះអង្គបានប្រទានព្រះបច្ឆិមោវាទ (ឱវាទទីបំផុត) ទុកថា: "ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយចូរញុំាងកិច្ចទាំងពួង គឺប្រយោជន៍ខ្លួននឹងប្រយោជន៍អ្នកដទៃនឹងត្រៃសិក្ខា គឺសីល សមាធិ បញ្ញា ឲ្យដល់ព្រម ដោយសេចក្តីមិនប្រមាទចុះ" ។

## ធាតុភាជនិយៈ

២៣៣ ស. អ្នកណាជាអ្នកចាត់ការចែកព្រះបរមសារីរិកធាតុ ? បើមិនបានអ្នកនោះមកចាត់ការចែកទេ តើនឹងមានសេចក្តីវិនាសយ៉ាងណា ?

ច. ទោណព្រាហ្មណ៍ ។ បើមិនបានលោកនេះមកធ្វើជាមេចាត់ការចែកទេ នឹងកើតសឹកសង្គ្រាមច្បាំងគ្នាធំដុំឡើង ព្រោះពួកក្សត្រផ្សេងៗ នឹងមកដណ្តើមយកដោយពលការ, ពួកអ្នកមានកំណាចឬមានកំឡាំងជាងនឹងដណ្តើមយកព្រះធាតុទាំងអស់ទៅទុកតែក្នុងនគរខ្លួន, ពួក

www.budinst.gov.kh www.elibraryofcambodia.org

អ្នកមានកំឡាំងតិច ក៏ក្រោធខឹងហើយរួមកំឡាំងគ្នាមកច្បាំងដណ្តើមយកឲ្យបានទៅវិញ; កាលបើដូច្នេះ លោកសន្និវាសនឹងកើតកែវ គ្មានសេចក្តីស្ងប់ស្ងៀម, ព្រះបរមសារីរិកធាតុក៏មិនបានផ្សាយទូទៅច្រើនប្រទេស ។

២២៤–សំ. ព្រះសារីរិកធាតុនៃព្រះសាស្តា គេចែកជាប៉ុន្មានចំណែក? គឺអ្វីខ្លះ? ហើយចំណែកដែលនៅល្អស្អាតមិនបែកបាក់មានប៉ុន្មានព្រះអង្គ? ចូរតបមកឲ្យសព្វគ្រប់ !

ឆ. គេចែកជា ២ ចំណែក ៗ គឺព្រះសារីរិកធាតុ ដែលនៅល្អស្អាតមិនបែកបាក់ ១ ចំណែក, ព្រះសារីរិកធាតុដែលបែកបាក់ល្អិត ១ ចំណែក ។ ចំណែកព្រះសារីរិកធាតុដែលនៅល្អស្អាតមិនបែកបាក់នោះ មាន ៧ ព្រះអង្គ គឺព្រះឧណ្ហីសធាតុ (ឆ្អឹងថ្ងាស) ១, ព្រះទាឋាធាតុ (ព្រះចង្កូម) ទាំង ៤, ព្រះអក្ខកធាតុ (ឆ្អឹងដងកាំបិត) ទាំង២ រួមជា ៧ ព្រះអង្គ ។ ព្រះសារីរិកធាតុក្រៅពីនេះ បែកចេញជាបំណែកតូចនឹងបំណែកធំ ៗ

២៣៥–សំ. ចុះព្រះសារីរិកធាតុ ដែលបែកចេញជាបំណែកតូច បំណែកធំទាំងអស់នោះ តើមានខ្នាតប៉ុន្មានយ៉ាង? ខ្នាតណាមានចំនួនប៉ុន្មាននាឡិ? មានទំហំប៉ុនណា? មានពណ៌ដូចម្តេច?

ឆ. មានខ្នាត ៣ យ៉ាង ៗ គឺ ព្រះធាតុខ្នាតធំមានចំនួន ៥ នាឡិ មានទំហំប៉ុនគ្រាប់សណ្តែកបាយ មួយកំណាត់ មានពណ៌ដូចមាស; ព្រះធាតុ

www.budinst.gov.kh www.elibraryofcambodia.org

ខ្នាតកណ្ដាល មានចំនួន ៦ នាឡិ មានទំហំប៉ុនគ្រាប់អង្ករមួយកំណាត់ មានពណ៌ដូចកែវផ្លេក; ព្រះធាតុខ្នាតតូចមានចំនួន ៥ នាឡិ មានទំហំប៉ុនគ្រាប់ស្ពៃ មានពណ៌ដូចផ្កាពកុល គឺពណ៌សស្រគាំ ។

២៣៦- ស. ព្រះសារីរិកធាតុទាំងអស់នោះ បានទៅប្រតិស្ឋាននៅកន្លែងណាខ្លះ ? ចូរពប់ឲ្យគ្រប់មក !

ប. ព្រះទាឋាធាតុស្ដាំខាងលើ ប្រតិស្ឋាននៅត្រៃត្រឹង្ស, ព្រះទាឋាធាតុស្ដាំខាងក្រោម ប្រតិស្ឋាននៅសីហឡទ្វីប, ព្រះទាឋាធាតុឆ្វេងខាងលើ ប្រតិស្ឋានក្នុងដែនគន្ធារៈ, ព្រះទាឋាធាតុឆ្វេងខាងក្រោម ប្រតិស្ឋានក្នុងពិភពនាគ ព្រះអក្ខកធាតុខាងឆ្វេងទាំងពីរអង្គ ប្រតិស្ឋានក្នុងព្រះស្តូបកំពស់ ១២ យោជន៍នៅនាព្រហ្មលោក (ព្រះអក្ខកធាតុខាងស្ដាំមិនឃើញមានប្រាប់ថាប្រតិស្ឋាននៅទីណា), ព្រះកេសធាតុដែលព្រះសាស្ដាកាត់ក្នុងពេលទ្រង់ព្រះផ្នួស ប្រតិស្ឋានក្នុងចូឡាមណីចេតិយនៅនាស្ថានត្រៃត្រឹង្ស, ព្រះទន្តធាតុទាំង ៤០ គត់ ព្រះកេសធាតុ ព្រះលោមធាតុ និងព្រះនខធាតុ ពួកទេវតានាំយកព្រះកេសធាតុមួយអង្គៗ ទៅកាន់ចក្រវាឡដទៃ ៗ ក្នុងចក្រវាឡមួយ ១ អង្គ ។

២៣៧- ស. គ្រឿងបរិក្ខារមានប៉ុន្មាន ? គឺអ្វីខ្លះ ? គ្រឿងបរិក្ខារណាទៅប្រតិស្ឋានក្នុងប្រទេសណា ? ចូរប្រាប់ឲ្យគ្រប់មកមើល !

www.budinst.gov.kh www.elibraryofcambodia.org

ច. ក្នុងគម្ពីរបឋមសម្ពោធិ ត្រង់ធាតុវិភជ្ជនបរិវត្តន៍ប្រាប់ថា ពុទ្ធបរិក្ខារមាន ១០ យ៉ាង ទៅប្រតិស្ឋាននៅប្រទេសផ្សេងៗគ្នាគឺ:

១ – កាយពន្ធនិងបាត្រ នៅក្នុងនគរបាដលិបុត្រ
២ – សំពត់ឧទកសាដក „ នគរបញ្ចាលរាជ
៣ – សំពត់បច្ចត្ថរណ „ នគរកោសលរដ្ឋ
៤ – ឈើស្ទន់ „ នគរមិថិលា
៥ – សំពត់ជម្រងទឹក „ នគរវិទេហរដ្ឋ
៦ – កាំបិតកោរនិងបំពង់ម្ជុល „ នគរឥន្ទបត្ត
៧ – ទ្រនាប់ព្រះបាទនិងស្លោកបាត្រ „ ឧសិរព្រាហ្មណគ្រាម
៨ – គ្រឿងកម្រាល „ មកុដនគរ
៩ – ត្រៃចីវរ „ នគរកម្ពុរដ្ឋ
១០ – និសីទនសន្ថត: „ នគរកុរុរដ្ឋ

២៣៨ – ស. កាលព្រះសាស្ដាគង់ព្រះជន្មនៅ ទ្រង់បានប្រតិស្ឋានស្នាមព្រះបាទក្នុងទីណាខ្លះ? រួមជាប៉ុន្មានកន្លែង?

ច. ទ្រង់បានប្រតិស្ឋានទុកលើកំពូលភ្នំសុវណ្ណមាលិក ១, លើភ្នំសុវណ្ណបព៌ត ១, លើភ្នំសុមនកូដ ១, នៅយោនកបុរី ១, នៅឆ្នេរស្ទឹងនម្មទា ១ រួមជា ៥ កន្លែង ។

www.budinst.gov.kh www.elibraryofcambodia.org

២៣៩_ ស. សំវេជនីយស្ថានមានប៉ុន្មានកន្លែង? នៅក្នុងទីណាខ្លះ? ចូរចង្អុលប្រាប់ឲ្យគ្រប់មកមើល!

ឆ. មាន ៤ កន្លែងគឺ ទីប្រសូត ១, ទីត្រាស់ដឹង ១, ទីសំដែងព្រះធម្មចក្រ ១, ទីបរិនិព្វាន ១។ ឯទីប្រសូតិ នៅក្នុងព្រៃលុម្ពិនី ប្រទល់ដែនក្រុងកបិលពស្តុ និងក្រុងទេវទហៈ។ ទ្រង់ត្រាស់ដឹង នៅក្នុងដែនមគធៈ ក្រោមម្លប់ព្រះមហាពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរា ។ ទីសំដែងព្រះធម្មចក្រ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ក្បែរក្រុងពារាណសី។ ទីបរិនិព្វាន នៅត្រង់ចន្លោះដើមរាំងទាំងគូក្នុងសាលវ័នឧទ្យាន របស់មល្លក្សត្រ ក្បែរនគរកុសិនារា

២៤០ - ស. កាលព្រះពុទ្ធបរិនិព្វានហើយ ជាន់ដំបូងមានព្រះស្តូបចេតិយប៉ុន្មានកន្លែង? នៅទីណា? អ្នកណាជាអ្នកសាង?

ឆ. មានធាតុចេតិយ ៨ កន្លែង គឺព្រះបាទអជាតសត្រូវ ទ្រង់សាងក្នុងនគររាជគ្រឹះ ១ ក្សត្រលិច្ឆវីទ្រង់សាងក្នុងនគរវេសាលី ១, ក្សត្រសាក្យៈទ្រង់សាងក្នុងនគរកបិលពស្តុ ១, ថូលិយក្សត្រទ្រង់សាងក្នុងអល្លកប្បនគរ ១, ក្សត្រកោលិយៈទ្រង់សាងក្នុងរាមគ្រាម ១, ព្រាហ្មណ៍អ្នកវេឋទីបកៈ បានសាងក្នុងដែនវេឋទីបកៈ ១, ពួកមល្លក្សត្រអ្នកក្រុងបាវា បានសាងក្នុងក្រុងបាវា ១, ពួកមល្លក្សត្រអ្នកក្រុងកុសិនារា បានសាង

www.budinst.gov.kh www.elibraryofcambodia.org

គង់ក្រុងកុសិនារា ១, ទោណព្រាហ្មណ៍បានសាងទុកក្នុងក្រុងកុសិនារាដែរ, ពួកក្សត្រមោរិយៈ បានសាងក្នុងក្រុងបិប្ផលិវ័ន; រួមជាព្រះស្តូប ៨ កន្លែង, បញ្ចូលព្រះស្តូបដែលដំកល់ព្រះតុម្ពៈ និងព្រះស្តូបដែលដំកល់ព្រះអង្គារៈ ២ ទៀត ត្រូវជា ១០ កន្លែង ។

២៤១– សួ. ព្រះចេតិយរបស់ព្រះពុទ្ធជាម្ចាស់ ចែកចេញជាប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? មានន័យផ្សេងគ្នាដូចម្តេច ?

ឆ្លើ. ចែកចេញជា ៤ យ៉ាងគឺៈ ធាតុចេតិយ ១, បរិភោគ-ចេតិយ ១, ធម្មចេតិយ ១, ឧទ្ទេសិកចេតិយ ១ ។ ចេតិយទាំង ៤ នេះ មានន័យផ្សេងគ្នាដូច្នេះ គឺ ចេតិយដែលបញ្ចុះព្រះសារីរិកធាតុ ហៅថា ធាតុចេតិយ ។ ចេតិយដែលបញ្ចុះគ្រឿងពុទ្ធបរិក្ខារ ហៅថា បរិភោគចេតិយ ។ ចេតិយដែលបញ្ចុះព្រះធម៌មានបដិច្ចសមុប្បាទធម៌ជាដើម ហៅថា ធម្មចេតិយ ។ ព្រះពុទ្ធរូបដែលគេសាងឡើង ដើម្បីស្នងគុណព្រះសម្មាសម្ពុទ្ធកាលគង់ព្រះជន្មនៅ ហៅថា ឧទ្ទេសិកចេតិយ ។

២៤២– សួ. ការប្រតិស្ឋានព្រះពុទ្ធចេតិយ មានប្រយោជន៍ដូចម្តេចខ្លះ?

ឆ្លើ. មានប្រយោជន៍ដូច្នេះ គឺនឹងបានជាគ្រឿងដាស់តឿនចិត្តប្រជាជន ឲ្យនឹករឭកដល់ព្រះសាស្តារបស់យើង ឲ្យនឹករឭកដល់

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីល្អ នឹងគុណសម្បត្តិរបស់ព្រះអង្គ នឹងគុណដែលមានដល់ប្រជាជនជាច្រើន ជាគ្រឿងជំនួយឲ្យពុទ្ធបរិស័ទចំរើនពុទ្ធានុស្សតិបានងាយ ៗ ការរឭកដល់ព្រះសាស្តារបស់យើង ជាផ្លូវនាំឲ្យយើងយកតម្រាប់តាម និងដើរតាមលំអានរបស់ព្រះអង្គ សឹងមានរឿងដំណាលថា: ព្រះថេរៈមួយអង្គ កំពុងតែបោសសំអាតទីវត្ត បានឃើញព្រះពុទ្ធរូប ដែលមាននិម្មិតចំពោះព្រះភ័ក្ត្រ លោកនឹករឭកដល់ព្រះពុទ្ធជាម្ចាស់ ហើយចំរើនវិបស្សនាបានសម្រេចព្រះអរហត្តផល ។

## សង្គាយនា ៥

២៤៣– សួ. កាលសម្តេចព្រះបរមសាស្តា បរិនិព្វានផុតទៅហើយ ព្រះសង្ឃសាវ័កទាំងឡាយបាននាំព្រះពុទ្ធសាសនាតៗគ្នាមក ដោយអាការដូចម្តេច ?

ឆ្លើ. ដោយអាការដូច្នេះគឺ កាលបើមានសេចក្តីទាស់ទុសកើតឡើង គប្រជុំគ្នាជម្រះ ហើយរួបរួមសេចក្តីដែលត្រឹមត្រូវទុកជាក្បួនក្រម ដែលហៅថា សង្គាយនា ៗ សង្គាយនានោះ ដែលរាប់ជាផ្លូវការមាន ៥ ជាន់ គឺក្នុងជម្ពូទ្វីប ៣ ជាន់, ក្នុងលង្កាទ្វីប ២ ជាន់ ដូចតទៅនេះ ៖

ក– បឋមសង្គាយនា: ព្រះមហាកស្សបត្ថេរជាប្រធាន ព្រោះឮពាក្យរបស់សុភទ្ទវុឌ្ឍបព្វជិតនិយាយប្រមាថមើលងាយព្រះធម៌វិន័យឲ្យជា-

www.budinst.gov.kh www.elibraryofcambodia.org

ដើម ទើបលោកបបួលការកសង្ឃចំនួន ៥០០ អង្គ សុទ្ធតែជាព្រះអរហន្ត បានចតុប្បដិសម្ភិទាញាណ ៗ ព្រះមហាកស្សបត្ថេរជាអ្នកសួរ, ព្រះឧបាលិត្ថេរជាអ្នកឆ្លើយព្រះវិន័យបិដក, ព្រះអានន្ទត្ថេរជាអ្នកឆ្លើយព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក, ធ្វើសង្គាយនាក្នុងសត្តបណ្ណគុហា ក្បែរភ្នំវេភារៈ ក្រុងរាជគ្រឹះ, ព្រះបាទអជាតសត្រូវជាសាសនូបត្ថម្ភក៍, ធ្វើ ៧ ខែទើបចប់ស្រេច ៗ ធ្វើបឋមសង្គាយនានេះ ក្នុងកាលព្រះសាស្តាបរិនិព្វានកន្លងទៅហើយបាន ៣ ខែ ៗ

២- ទុតិយសង្គាយនា: ធ្វើខាងក្រោយព្រះសាស្តានិព្វានកន្លងទៅហើយបាន ១០០ ឆ្នាំ, ព្រះយសកាកណ្ឌបុត្រ ជាប្រធាន ព្រមដោយការកសង្ឃ ៧០០ អង្គ សុទ្ធតែជាព្រះអរហន្តបានចតុប្បដិសម្ភិទាញាណ ប្រារព្ធពួកភិក្ខុវជ្ជីបុត្រអ្នកប្រព្រឹត្តខុសធម៌វិន័យ បញ្ញត្តិប្រកាន់វត្ថុ ១០ ប្រការថាត្រឹមត្រូវឲ្យជាដើមហេតុ ព្រះរេវតត្ថេរជាអ្នកចោទសួរវត្ថុ ១០ ប្រការ, ព្រះសព្វកាមិត្ថេរជាអ្នកឆ្លើយ, ធ្វើក្នុងវាលុការាម នគរវេសាលី, ព្រះបាទកាឡាសោករាជជាសាសនូបត្ថម្ភក៍, ធ្វើ ៨ ខែទើបហើយស្រេច ៗ ទុតិយសង្គាយនានេះ ធ្វើតាមរបៀបបឋមសង្គាយនាដែរ ប្លែកតែត្រូវរម្ងាប់វត្ថុ ១០ ប្រការប៉ុណ្ណោះ ៗ

វត្ថុ ១០ ប្រការដែលពួកភិក្ខុវជ្ជីបុត្រប្រព្រឹត្តនោះគឺ:

www.budinst.gov.kh www.elibraryofcambodia.org

១)– កប្បតិ សិង្គិលោណកប្បោ វិនយប្បញ្ញត្តិ ក្នុងសន្និធិការកសិក្ខាបទ ក្នុងសុត្តវិភង្គថា របស់ជាយាវកាលិក បើភិក្ខុបានទទួលប្រគេន ហើយទុកឲ្យកន្លងរាត្រី យកមកឆាន់ត្រូវអាបត្តិបាចិត្តិយៈ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា អំបិលដែលគេដាក់ក្នុងក្ដាក់ស្នែង បើទុកឲ្យកន្លងរាត្រីទៅហើយយកមកឆាន់ជាមួយនឹងអាហារបិណ្ឌបាតដែលសាបបាន មិនត្រូវអាបត្តិឡើយ ។

២)– កប្បតិ ទ្វង្គុលកប្បោ វិនយប្បញ្ញត្តិក្នុងវិកាលភោជនសិក្ខាបទ ក្នុងសុត្តវិភង្គថា ភិក្ខុឆាន់របស់ជាយាវកាលិកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយៈ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា បើព្រះអាទិត្យទ្រេតទៅហើយប្រមាណពីរធ្នាប់ ក៏គួរនឹងឆាន់របស់ជាយាវកាលិកបាន មិនត្រូវអាបត្តិឡើយ ។

៣)– កប្បតិ គាមន្តរកប្បោ វិនយប្បញ្ញត្តិ ក្នុងបឋមបវារណាសិក្ខាបទ ក្នុងសុត្តវិភង្គថា ភិក្ខុហាមភោជនហើយក្រោកចាកអាសនៈនោះហើយ ទៅឆាន់អនតិរិត្តភោជន ត្រូវអាបត្តិបាចិត្តិយៈ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា បើភិក្ខុមានសេចក្ដីគិតថាអញនឹងចូលទៅកាន់ស្រុកដូច្នេះ ក៏ត្រូវឆាន់អនតិរិត្តភោជនបាន មិនត្រូវអាបត្តិអ្វីឡើយ ។

៤)– កប្បតិ អាវាសកប្បោ វិនយប្បញ្ញត្តិ ក្នុងឧបោសថក្ខន្ធកៈ

ទី ៤ ក្នុងខន្ធកវិន័យថា ទីអាវាសដែលនៅក្នុងសីមាជាមួយគ្នា ភិក្ខុនឹងធ្វើសង្ឃកម្មទាំងពួង មានឧបោសថកម្មជាដើម ផ្សេងគ្នាមិនគួរ បើធ្វើដូច្នេះត្រូវអាបត្តិទុក្កដ កម្មដែលធ្វើនោះសោតក៏មិនមែនជាសង្ឃកម្មនោះឡើយ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា ត្រូវធ្វើបាន ឥតមានទោសខុសអ្វីឡើយ ។

៥)— កប្បតិ អនុមតិកប្បោ វិនយបញ្ញត្តិ ក្នុងចម្បេយ្យក្ខន្ធកៈទី ៩ ក្នុងខន្ធកវិន័យថា ភិក្ខុនឹងធ្វើសង្ឃកម្មទាំងពួង ត្រូវប្រជុំភិក្ខុដែលមាននៅក្នុងសីមាជាមួយគ្នាឲ្យមកប្រជុំព្រមជាមួយហត្ថបាសគ្នាឬបាននាំឆន្ទបារិសុទ្ធិនៃភិក្ខុដែលមានកិច្ចធុរៈមិនបានមកកាន់ហត្ថបាសនោះ ទើបធ្វើបាន បើមិនធ្វើដូច្នេះ ហៅថា ធ្វើកម្មជាពួក ត្រូវអាបត្តិទុក្កដ កម្មដែលធ្វើនោះសោត ក៏មិនមែនជាសង្ឃកម្មឡើយ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា មិនចាំបាច់មកជួបជុំគ្នាដូច្នេះទេ បើមកដល់មុននឹងធ្វើសង្ឃកម្មមុនបណ្តើរទៅក៏បាន ឥតមានទោសខុសអ្វីឡើយ ។

៦)— កប្បតិ អាចិណ្ណកប្បោ ព្រះធម៌វិន័យ ក្នុងសាសនានេះមានរបៀបរៀបរៀងគ្នាជាខាតជាបន្ទាត់កំណត់ទុកថាខុសថាត្រូវ ដាំ[illegible]បមកហើយ សេចក្តីប្រតិបត្តិជាចារិតរបស់ព្រះឧបជ្ឈាយ៍អាចារ្យតៗគ្នាមក បើត្រូវសមតាមរបៀបធម៌វិន័យនោះ ទើបឲ្យសិស្សានុសិស្ស កាន់

ពួងប្រតិបត្តិតាម បើមិនត្រូវមិនសមតាមរបៀបធម៌វិន័យទេ នោះសិស្សានុសិស្សទាំងពួងមិនត្រូវប្រតិបត្តិតាមឡើយ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា សេចក្តីប្រតិបត្តិជាចរិត ទំនៀមទម្លាប់របស់ព្រះឧបជ្ឈាយ៍អាចារ្យព្រោះបីខុសក្តីត្រូវក្តី សិស្សានុសិស្សទាំងពួងត្រូវតែប្រតិបត្តិតាមឥតមានទាស់ខុសអ្វីឡើយ ។

៧)- កប្បតិ អមថិតកប្បោ ទឹកដោះស្រស់ដែលប្រែបាតភាពដើមហើយ តែមិនទាន់ក្លាយទៅជាទធិនៅឡើយ មានវិនយ-ប្បញ្ញត្តិថា ភិក្ខុហាមភោជនហើយក្រោកចាកទីអាសនៈនោះហើយ ឆាន់ទឹកដោះជាអនតិរិត្តនោះ ត្រូវអាបត្តិបាចិត្តិយៈ តាមន័យក្នុងបឋមបវារណាសិក្ខាបទ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា ភិក្ខុឆាន់បាន មិនត្រូវអាបត្តិអ្វីឡើយ ។

៨)- កប្បតិ ជឡោគិ បាតុំ តរុណសុរា គឺសុរាដែលគេដាក់គ្រឿងស្រវឹងផ្សំត្រាំជាមួយគ្នាហើយ តែនៅទន្លាយមិនទាន់ពេញជាទឹកស្រវឹងនៅឡើយ បើភិក្ខុផឹក ត្រូវអាបត្តិបាចិត្តិយៈ តាមន័យក្នុងសុរាបានសិក្ខាបទ ក្នុងសុត្តវិភង្គ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា តរុណសុរានេះ ភិក្ខុត្រូវផឹកបាន មិនត្រូវអាបត្តិអ្វីឡើយ ។

៩)- កប្បតិ អទសកំ និសីទនំ វិនយបញ្ញត្តិក្នុងនិសីទន-

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទ ក្នុងសុត្តវិភង្គថា ភិក្ខុនឹងធ្វើសំពត់និសីទនៈ ត្រូវធ្វើឲ្យមានជាយ បើមិនធ្វើជាយនោះទេ ត្រូវអាបត្តិបាចិត្តិយៈ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា សំពត់និសីទនៈ មិនបាច់ធ្វើឲ្យមានជាយក៏ប្រើប្រាស់បាន មិនត្រូវអាបត្តិឡើយ ។

១០)– កប្បតិ ជាតរូបរជតំ វិនយបញ្ញត្តិក្នុងរូបិយសិក្ខាបទ ក្នុងសុត្តវិភង្គថា ភិក្ខុមិនត្រូវទទួលមិនត្រូវត្រេកអរ ចំពោះមាស ឬ ប្រាក់ទេ បើទទួលឬត្រេកអរ ត្រូវអាបត្តិ និស្សគ្គិយបាចិត្តិយៈ ។ តែក្នុងមេណ្ឌកបញ្ញត្តិ ក្នុងភេសជ្ជក្ខន្ធកៈទី ៦ ក្នុងខន្ធកវិន័យមានព្រះពុទ្ធានុញ្ញាតឲ្យភិក្ខុត្រេកអរចំពោះចតុប្បច្ច័យ ដែលកើតអំពីរូបិយៈ គឺមាស ឬ ប្រាក់នោះបាន តែបញ្ញត្តិហាមមិនឲ្យទទួលមិនឲ្យត្រេកអរចំពោះគ្រឿងមាស ឬប្រាក់ឡើយ ។ ពួកភិក្ខុវជ្ជីបុត្រថា ភិក្ខុគួរទទួលនិងត្រេកអរចំពោះគ្រឿងមាស ឬ ប្រាក់នោះបាន មិនត្រូវអាបត្តិអ្វីឡើយ ។

ព្រះអរហន្តទាំងឡាយ បានសម្រេចសេចក្ដីថា វត្ថុទាំង ១០ ប្រការនោះ ជាផ្លូវប្រតិបត្តិខុសអំពីរបៀបព្រះពុទ្ធសាសនាក្នុងគ្រាដែលលោកធ្វើបឋមសង្គាយនានោះឯង ។

គ_ តតិយសង្គាយនា: កាលព្រះសាស្ដាបរិនិព្វានកន្លងទៅបាន ២១៨ ឆ្នាំ, ព្រះបាទធម្មាសោករាជបានសោយរាជសម្បត្តិក្នុងសកល-

www.budinst.gov.kh www.elibraryofcambodia.org

ជម្ពូទ្វីប ក្រុងបាដលិបុត្រ ទ្រង់មានព្រះទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ញុំាំងលាភសក្ការៈដ៏ច្រើនប្រព្រឹត្តទៅ ម៉្លោះហើយពួកនិគ្រន្ថអន្យតិរ្ថិយ ដែលមានសេចក្ដីត្រេកត្រអាលបាកប្រាថ្នាលាភសក្ការៈ លបចូលបួសបំបន្លំក្នុងពុទ្ធសាសនមណ្ឌល ហើយយកលទ្ធិរបស់ខ្លួនមកសំដែងអាងថាជាពុទ្ធ-សាសនា កាលបើយ៉ាងនេះ ព្រះពុទ្ធសាសនាឈ្មោះថាមានមន្ទិលកើតឡើង ។ គ្រានោះព្រះសង្ឃបែកគ្នាខានធ្វើឧបោសថកម្ម អស់ ៧ ឆ្នាំ ។ ព្រះបាទធម្មាសោករាជទ្រង់ប្រាថ្នានឹងជម្រះមន្ទិលព្រះពុទ្ធសាសនា ទើប-ត្រាស់ប្រើរាជអាមាត្យឲ្យអង្កេតចាប់ពួកនិគ្រន្ថ ផ្សឹកអស់ហើយ ទុកតែព្រះសង្ឃដែលបរិសុទ្ធ ៗ ទើបព្រះមោគ្គលីបុត្តតិស្សត្ថេរជាប្រធានជ្រើសរើសរកព្រះអរហន្តដែលបានចតុប្បដិសម្ភិទាញាណចំនួន១.០០០អង្គនាំគ្នាធ្វើសង្គាយនាលើកព្រះពុទ្ធសាសនាជាគ្រាទី ៣ ក្នុងអសោការាមក្រុង-បាដលិបុត្តមហានគរ ធ្វើតាមរបៀបបឋមសង្គាយនានិងទុតិយសង្គាយនានោះដែរ, មានព្រះបាទធម្មាសោករាជជាសាសនូបត្ថម្ភក៍, ធ្វើអស់កាល ៩ ខែទើបហើយស្រេច ។ សង្គាយនាទី ១ ទី ២ និងទី ៣ នេះ ធ្វើក្នុងជម្ពូ-ទ្វីបទាំងអស់ ។

ឃ- ចតុត្ថសង្គាយនាៈ ព្រះមោគ្គលីបុត្តតិស្សត្ថេរ បានធ្វើតតិយសង្គាយនារួចហើយ លោករំពឹងមើលទៅក្នុងអនាគតកាលបានឃើញ

ថា ព្រះពុទ្ធសាសនានឹងទៅប្រតិស្ឋានក្នុងបច្ចន្តប្បទេស លោកទើបចាត់ព្រះអរហន្តខីណាស្រពឲ្យនាំព្រះពុទ្ធសាសនាទៅប្រតិស្ឋាន ទុកនៅប្រទេសផ្សេងៗ ចំណែកព្រះមហិន្ទត្ថេរ បានទទួលថេរបញ្ជាឲ្យប្រកាសព្រះពុទ្ធសាសនានៅនាលង្កាទ្វីប ញុំាងព្រះបាទទេវានម្បិយតិស្សៈ នឹងអ្នកលង្កាឲ្យមានសទ្ធាជ្រះថ្លា ។

គ្រានោះ ព្រះនាងអនុឡាដែលជាជាយារបស់ព្រះមហានាគឧបរាជជាព្រះរាជអនុជា មានប្រាថ្នាបព្វជ្ជា ជាភិក្ខុនី ។ ព្រះបាទក្រុងលង្កាទ្រង់បញ្ជូនរាជទូតទៅក្រុងបាដលិបុត្តជម្ពូទ្វីប ដើម្បីក្រាបទូលព្រះបាទធម្មាសោករាជសូមអារាធនាព្រះសង្ឃមិត្តាថេរីព្រះរាជធីតាមកសម្រេចកិច្ចឧបសម្បទាដល់ស្ត្រីជាតិសីហឡៈ និងសូមអញ្ជើញមែកព្រះមហាពោធិព្រឹក្សមកផង ។ ព្រះបាទធម្មាសោករាជក៏ទ្រង់ព្រះរាជានុញ្ញាតតាម ។

កាលព្រះពុទ្ធសាសនារុងរឿងឡើងក្នុងលង្កាទ្វីបហើយ ព្រះបាទទេវានម្បិយតិស្សៈត្រាស់សួរព្រះមហិន្ទត្ថេរថា ព្រះពុទ្ធសាសនាបានឈ្មោះថា ប្រតិស្ឋានក្នុងលង្កាទ្វីបហើយឬនៅឡើយទេ? ព្រះថេរៈថ្វាយព្រះពរថា ព្រះពុទ្ធសាសនាដែលនឹងបានយាងចុះស៊ប់ស្ងួននោះ លុះតែបានកើតតម្កល់គម្ពីរព្រះវិន័យ គឺជាធ្វើសង្គាយនា ។ ព្រះបាទទេវានម្បិយតិស្សៈក៏ប្រារព្ធដើម្បីនឹងធ្វើសង្គាយនា ទើបទ្រង់អារាធនាព្រះមហិន្ទត្ថេរឲ្យនាំ

អ្នកបុច្ឆា, ព្រះរេវត្តមហាថេរ ជាអ្នកវិសជ្ជនា, ធ្វើតាមរបៀបនៃសង្គាយនាទាំង ៣ គ្រាខាងដើមនោះដែរ ។ ព្រះសង្ឃស្រុកលង្កាបានសូត្ររៀនចេះចាំព្រះពុទ្ធវចនៈ ដែលចុះផ្សាយ ជាមានសល់ដំណាក់តាក់តើស អាចធ្វើជាគណៈបាមោក្ខាចារ្យប្រៀនប្រដៅកុលបុត្រក្នុងទីនោះបាន ល្មមឲ្យសន្និដ្ឋានបានថា ព្រះពុទ្ធសាសនាបានឫសតាំងចុះស៊ប់ក្នុងលង្កាទ្វីបមែន ។

ចតុត្ថសង្គាយនានេះ បានធ្វើក្នុងថូបារាម ក្នុងអនុរាធបុរី មានការកសង្ឃ ៦៨.០០០ អង្គ មានព្រះបាទទេវានម្បិយតិស្សៈ ក្សត្រក្រុងលង្កាជាសាសនូបត្ថម្ភ ធ្វើអស់កាល ១០ ខែទើបហើយស្រេច ក្នុងរវាងព្រះពុទ្ធសករាជ ២៣៦ ឆ្នាំ ។

៥ – បញ្ចមសង្គាយនា៖ ព្រះបាទទេវានម្បិយតិស្សៈ ក្សត្រក្រុងលង្កាទ្វីប ទ្រង់មានបុញ្ញានុភាពប្រកបដោយព្រះបញ្ញាច្រើន បានបំពេញព្រះរាជកុសលផ្សេងៗ ជាអនេកហើយទិវង្គតទៅ ។ បន្ទាប់អំពីនោះមក ព្រះបាទឧត្តិយៈ ព្រះមហាសិវៈ និងព្រះបាទសូរតិស្សៈ បានសោយរាជ្យជាលំដាប់គ្នា ហើយទំនុកបំរុងព្រះពុទ្ធសាសនាតរៀងមក ។ ដំណោះចីរកាលមកខាងក្រោយ ឲ្យក្សត្រលង្កាទ្វីបនោះតែងខ្វល់ព្រោះថ្នាក់ពីពួកបច្ចាមិត្តរឿយៗ របៀបផលផ្លាស់ព្រះរាជវង្សថ្មី ម្ល៉ោះហើយព្រះពុទ្ធ-

សាសនាចេះតែលិចអណ្តែតៗ ទៅតាមវេនក្សត្រដែលជ្រះថ្លានិងមិនជ្រះថ្លា ។

ដល់មកសម័យព្រះបាទវដ្តគាមិនីអភ័យ បានកំចាត់បច្ចាមិត្រ អស់ហើយទ្រង់បានសោយរាជ្យ សិរីសួស្តីជាក្សត្រឯករាជ្យ ទ្រង់បានសាងវត្តអភយគិរីប្រគេនព្រះតិស្សត្ថេរព្រមទាំងទំនុកបំរុង ដោយចតុប្បច្ច័យដ៏បរិបូណ៌ ជាហេតុនាំឲ្យព្រះសង្ឃមហាវិហារកើតសេចក្តីច្រណែនលើកទោសព្រះតិស្សត្ថេរថា ច្រឡូកច្រឡំដោយគ្រហស្ថ ។ គ្រានោះព្រះសង្ឃបែកជា ២ ពួក គឺពួកខាងមហាវិហារ ១, ពួកខាងអភយគិរីវិហារ ១ ។

ក្នុងសម័យនោះ ពួកព្រះសង្ឃដែលមានបញ្ញាច្រើនបានឃើញហេតុដែលនាំឲ្យសាបសូន្យព្រះពុទ្ធសាសនាដូច្នោះហើយ ទើបនាំគ្នាលើកសង្គាយនាជាគ្រាទី ៥ បានចារឹកព្រះត្រៃបិដកជាតួអក្សរដាក់ក្នុងស្លឹករឹតកប់ថាជាគ្រាដំបូងដែលប្រើអក្សរជាគ្រឿងកត់ត្រាព្រះពុទ្ធវចនៈ ។

បញ្ចប់សង្គាយនានេះធ្វើក្នុងមហាវិហារអាលក្កទ្វីប មានការកសង្ឃ ១.០០០ អង្គ មានព្រះពុទ្ធទត្តត្ថេរជាប្រធានជាអ្នកបុច្ឆា, ព្រះតិស្សត្ថេរជាអ្នកវិសជ្ជនា ប្រារព្ធសង្ឃបែកគ្នាជា ២ ពួកឲ្យជាដើមហេតុ, ព្រះបាទវដ្តគាមិនីអភ័យ ក្សត្រក្រុងលង្កាទ្វីបជាសាសនូបត្ថម្ភក៍, ធ្វើអស់កាល ១២ខែទើបស្រេច ។

www.budinst.gov.kh www.elibraryofcambodia.org

ចំណេរចីរកាលតរៀមក លោកអ្នកប្រាជ្ញទាំងឡាយ បានតែងគម្ពីរអដ្ឋកថា ដីកា អនុដីកាព្រមទាំងសទ្ទសាស្ត្រឲ្យជាឧបការៈដល់ពុទ្ធសាសនិកជនកាន់តែច្រើនឡើង ចាល់តែប្រជាជនក្នុងនានាប្រទេសដែលគាប់អានព្រះពុទ្ធសាសនា បានមកប្រតិស្ឋានទុកជាចេតិយជាទីគោរពនិងបានតែងឡើងថែមទៀតឲ្យផ្សាយច្រើនខ្ទូទៅក្នុងពុទ្ធសាសនមណ្ឌល ។ ព្រះសង្ឃសាវ័កទាំងឡាយបាននាំព្រះពុទ្ធសាសនាត ៗ គ្នាមកដោយអាការដូចពោលមកនេះឯង ។

## ប្រស្នាភាយរងក្នុងពុទ្ធប្រវត្តិ

២៤៤– សំ. ព្រះសាស្តាទ្រង់ប្រកាសសាសនាឲ្យផ្សាយទូទៅដោយវិធីដូចម្តេច ?

ឆ. ដោយវិធីដូច្នេះគឺ: ក្នុងជាន់ដំបូង កាលព្រះអង្គបានត្រាស់ដឹងហើយ បានយាងទៅទូន្មានដោយព្រះអង្គឯងខ្លះ, លុះមានអ្នកជឿជ្រះថ្លាថ្វាយខ្លួនជាសាវ័កចូលបួសក្នុងធម៌វិន័យហើយ ទ្រង់ឃើញថាសាវ័កមានគុណធម៌ដ៏បរិបូណ៌ហើយ ក៏ទ្រង់បញ្ជូនសាវ័កដែលជាអ្នកអាចឲ្យទៅប្រកាសសាសនា តាមស្រុកនិគមរាជធានីតូចធំ ដើម្បីឲ្យកើតសទ្ធាជ្រះថ្លាដល់បរិស័ទនោះៗខ្លះ ។

២៤៥– សំ. ព្រះសាវ័កបានជាកំឡាំងរបស់ព្រះសាស្តាដូចម្តេច ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. បានជាកំឡាំងរបស់ព្រះសាស្តា ក្នុងកាលដែលព្រះអង្គគង់ព្រះជន្មនៅ ដោយបានជួយគ្រាច់ទៅប្រកាសព្រះសាសនាក្នុងស្រុកតូចធំ ៗ លុះព្រះសាស្តានិព្វានទៅហើយ បាននាំគ្នារក្សាព្រះសាសនានិងធ្វើសង្គាយនា រៀបរៀងព្រះធម៌វិន័យឲ្យមានរបៀបបែបផែនរហូតមកដល់សព្វថ្ងៃនេះ ។

២៤៦- ស. មនុស្សអ្នកកាន់ព្រះពុទ្ធសាសនាក្នុងបាលីចាត់ជាប៉ុន្មានពួក ? ណាឈ្មោះអ្វី ?

ឆ. ចាត់ជា ៤ ពួក ហៅថា បរិស័ទ ៤ គឺភិក្ខុបរិស័ទ ១, ភិក្ខុនីបរិស័ទ ១, ឧបាសកបរិស័ទ ១, ឧបាសិកាបរិស័ទ ១ ។

២៤៧- ស. បរិស័ទទាំង ៤ នោះ អ្នកណាជាដើមរបស់បរិស័ទណា ?

ឆ. អញ្ញាកោណ្ឌញ្ញៈជាដើមរបស់ភិក្ខុបរិស័ទ, ព្រះនាងបជាបតិគោតមីជាដើមរបស់ភិក្ខុនីបរិស័ទ, បិតាព្រះយសត្ថេរជាដើមរបស់ឧបាសកបរិស័ទ, មាតាព្រះយសត្ថេរ ជាដើម របស់ឧបាសិកាបរិស័ទ; បើជាទ្វេវាចិកឧបាសក គឺតបុស្សៈនិងភល្លិកៈជាដើមគេ ។

២៤៨- ស. អនុបុព្វីកថា មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ?

ឆ. មាន ៥ យ៉ាង គឺទាន ១, សីល១, ស្ថានសួគ៌១, ទោសរបស់កាម១, នេក្ខម្មៈ គឺការបួសចេញពីកាម ១ ។

www.budinst.gov.kh www.elibraryofcambodia.org

២៤៩ - ស. អ្នកដែលនឹងទទួលព្រះធម៌ទេសនាអនុបុព្វីកថាបាន នោះត្រូវប្រកបដោយអង្គប៉ុន្មាន ?

ប. ត្រូវប្រកបដោយអង្គ ៣, គឺកើតជាមនុស្ស១, ជាគ្រហស្ថ១, ហើយជាអ្នកមានឧបនិស្ស័យចាស់ក្លាគួរសម្រេចលោកុត្តរគុណក្នុងទីនោះ ១ លុះតែព្រមដោយអង្គ ៣ នេះ ទើបព្រះសាស្ដាទ្រង់សំដែងអនុបុព្វីកថាប្រោស ។

២៥០ - ស. អភិញ្ញាទេសិតធម៌ គឺអ្វីខ្លះ ? ព្រោះហេតុអ្វីបានជាហៅដូច្នោះ ?

ប. អភិញ្ញាទេសិតធម៌នោះ គឺ សតិបដ្ឋាន ៤, សម្មប្បធាន ៤, ឥទ្ធិបាទ ៤, ឥន្ទ្រិយ ៥, ពលៈ ៥, ពោជ្ឈង្គ ៧, មគ្គ ៨ ។ បានជាហៅថា អភិញ្ញាទេសិតធម៌ ព្រោះហេតុថាធម៌ទាំងនេះព្រះអង្គទ្រង់សំដែង ដើម្បីឲ្យសត្វដឹងច្បាស់ឲ្យឃើញពិតក្នុងធម៌ដែលសត្វគួរដឹងគួរឃើញ ។

២៥១ - ស. ធម៌ទាំងនោះ បើមិនហៅថា អភិញ្ញាទេសិតធម៌ទេនឹងហៅថាអ្វីបានទៀត ? ព្រោះហេតុអ្វី ?

ប. ហៅថា ពោធិបក្ខិយធម៌ក៏បាន, ព្រោះហេតុថាធម៌ ៣៧ ប្រការនោះ ជាចំណែកនៃសេចក្ដីត្រាស់ដឹង ។

២៥២ - ស. ក្នុងគ្រាពុទ្ធកាលមនុស្សទាំងឡាយកាន់យកចិត្តទុកដាក់

www.budinst.gov.kh www.elibraryofcambodia.org

និរោគធម៌ជាច្រើនមកហើយ មែនឬទេ ? ប៉ុន្តែហេតុអ្វី បានជាមិនឮល្បីឲ្យប្រាកដថា ឈ្មោះអ្នកណាខ្លះ ដែលបានរួចផុតទុក្ខទៅហើយ ? កាលព្រះសាស្តាបានត្រាស់ដឹងឡើង ទ្រង់ទេសនាប្រាប់ឧបាយឲ្យផុតចាកទុក្ខយ៉ាងណា ? ចូរអាងគោលឲ្យសមមកមើល !

ឆ. មែនៗ ប៉ុន្តែអ្នកទាំងនោះមិនបានរួចផុតទុក្ខទេ ព្រោះមិនទាន់ដឹងទីកន្លែងដែលសូន្យទុក្ខ ដែលជាទីរួចឲ្យបានបាន លុះតែព្រះសាស្តាបានត្រាស់ដឹងឡើងទ្រង់បង្ហាញប្រាប់ឧបាយថា ទុក្ខនឹងកើតឡើងបានក៏ព្រោះតែតណ្ហា នឹងរលត់ទៅបានក៏ព្រោះតែប្រតិបត្តិតាមផ្លូវមជ្ឈិមាបដិបទាមានអង្គ ៨ ដូចមានសេចក្តីប្រាកដក្នុងព្រះធម្មចក្កប្បវត្តនសូត្រជាបឋមទេសនាស្រាប់ហើយ ។

២៥៣– សំ. ចូរបង្ហាញតួយ៉ាងឲ្យឃើញថា ព្រះសាស្តាទ្រង់កែប្រែសាសនាព្រាហ្មណ៍មកមើល ហើយអធិប្បាយឲ្យឃើញថាល្អវិសេសជាងសាសនាចាស់យ៉ាងណា ?

ឆ. ព្រះសាស្តាទ្រង់សំដែងព្រះធម៌ទេសនាដើម្បីកែប្រែសាសនាព្រាហ្មណ៍នោះមានច្រើនយ៉ាង ប៉ុន្តែក្នុងទីនេះ នឹងបង្ហាញដោយឯកទេស ។ សាសនាចាស់ប្រកាន់ថា មនុស្សដែលនឹងបានឈ្មោះថាជាព្រាហ្មណ៍អ្នកខ្ពង់ខ្ពស់ព្រោះជាប់សែស្រឡាយមកអំពីព្រហ្ម ព្រមទាំង

www.budinst.gov.kh www.elibraryofcambodia.org

ប្រកាន់ការទួលទឹកលាងបាបក្នុងស្ទឹងដ៏ស័ក្តិសិទ្ធិតាមសម័យ ដោយហេតុឲ្យបរិ-សុទ្ធជាដើមដែលជាបច្ច័យនៃការប្រកាន់គោត្រជាហេតុឲ្យរង្កៀសគ្នាដោយជាតិ, ប្រកាន់សេចក្តីបរិសុទ្ធិដោយហេតុខាងក្រៅ ដែលជាការបែកជាន់ចែកថ្នាក់មនុស្សមិនឲ្យរួមសាមគ្គីគ្នា កាត់ផ្លូវចំរើននៃវណ្ណៈដទៃ ធ្វើឲ្យផងចូលចិត្តខុសពេញចិត្តត្បើនៃអំពើអាក្រក់ក្នុងមេត្តាដល់ជាតិដទៃ ។ សម្តេចព្រះបរមសាស្តាទ្រង់ថ្លែថា មនុស្សដែលនឹងបានឈ្មោះថាជាព្រាហ្មណ៍ (អ្នកវិសេសសមនពិត) ក៏ព្រោះតែគុណសម្បត្តិ, អ្នកដែលបរិសុទ្ធក៏ព្រោះតែស្អាតចិត្តប្រាសចាកកិលេសជាគ្រឿងសៅហ្មងជាដើម ដែលជាការកាត់សេចក្តីរង្កៀសគ្នាក្នុងរបស់មនុស្សត្រូវ បង្កសាមគ្គីគ្នា បើកផ្លូវសេចក្តីចំរើនដល់មនុស្សគ្រប់ជាន់ឲ្យឃើញសេចក្តីពិតមែនដោយការស្តាប់ និងរៀនសូត្រហើយប្រតិបត្តិតាម ។ សេចក្តីនេះមានព្រះធម៌ទេសនាដែលព្រះសាស្តាទ្រង់ប្រទានដល់ព្រាហ្មណ៍ហុហុកជាតិជាគ្រឿងអាង ។

២៥៤–សំ. កាលដែលព្រះសាស្តាត្រាស់យកផលិតទាំង ៣ ឲ្យជួយជាកំឡាំងប្រតិស្ឋានព្រះសាសនាក្នុងដែនមគធៈនោះ មិនតែចង្អុលឲ្យឃើញថាព្រះអង្គទាល់បញ្ហាអស់សេចក្តីឥតអាចទៅហើយឬទៅថាដូចម្តេចទៅវិញ?

បា. កាលបើគិតស៊ើបទៅក៏ឃើញថាព្រះអង្គទាល់បញ្ហាអស់សេចក្តីអត់អាចមែន ប៉ុន្តែបើពិនិត្យពិចារណាឲ្យល្អិតទៅទៀត គ្រប់

www.budinst.gov.kh www.elibraryofcambodia.org

ជាបន្ទាល់ឲ្យឃើញថាព្រះសាស្តាមានព្រះបញ្ញាជ្រាលជ្រៅ មានដំណើរឧបាយវិធីយ៉ាងឯក ជាអ្នកដឹងកាលៈទេសៈ ធ្វើការគួរដល់ហេតុ បានទទួលសេចក្តីស្រួលជាផល. បើប្រើមនុស្សដែលអង់អាចឲ្យជាកំឡាំងសូម្បីធ្វើការកែបន្តិចបន្តួច ក៏អាចញុំាងការធំឲ្យសម្រេចបាន គួរជាទិដ្ឋានុគតិរបស់អនុជនបានយ៉ាងល្អ ប៉ុណ្ណោះក៏បន្ទាល់ឲ្យឃើញថា ព្រះអង្គមានព្រះបញ្ញាឈ្លាសវៃត្រឹមណា មិនមែនព្រះអង្គទាល់គំនិតបញ្ញាទេ ។

២៥៤–សិ. មនុស្សក្រៅព្រះពុទ្ធសាសនាគេនិយាយគ្នាថាព្រះពុទ្ធសាសនាបានជាផ្សាយទៅបានឆាប់រហ័សនោះ ព្រោះផ្សាយទៅក្នុងពួកជនជាន់ខ្ពស់ជាមុន ហើយបានអាស្រ័យកម្លាំងរបស់ជនទាំងនោះ ជួយទំនុកបំរុង ទើបផ្សាយទៅបានរហ័សមិនវិសេសនឹងនឹកស្មានអ្វីជាងសាសនារបស់គេដែលផ្សាយទៅក្នុងជនជាន់ទាបជាមុនទេ រឿងនេះ មានសេចក្តីពិតត្រឹមណា សូមឆ្លើយតាមយល់ ?

បុ. ការផ្សាយទៅរហ័សឬយឺតក្នុងមនុស្សជាន់ខ្ពស់ ឬជាន់ទាបជាមុននោះ មិនសូវជាសំខាន់ប៉ុន្មានទេ ឯការសំខាន់នៅត្រង់សាសនានោះ ជារបស់ពិតល្អឬមិនពិតប៉ុណ្ណោះ, បើល្អពិតហើយនឹងផ្សាយទៅក្នុងមនុស្សជាន់ខ្ពស់ ឬ ជាន់ទាបមុនក៏បាន; តែជាសម្រាប់អ្នកមានគំនិតល្អិតជ្រាលជ្រៅ គួរតែផ្សាយទៅក្នុងមនុស្សជាន់ខ្ពស់មុន ព្រោះថាមនុស្ស

www.budinst.gov.kh www.elibraryofcambodia.org

ជាន់ខ្ពស់ជាអ្នកមានគំនិតបញ្ញាដ៏ខ្ពង់ខ្ពស់ កាលបើមនុស្សជាន់ខ្ពស់នោះទទួលរាប់រងហើយ មិនបាច់ព្រួយថ្វីដល់មនុស្សជាន់ទាប ដែលជាមនុស្សស្តាប់ងាយជឿងាយ. ដោយមិនចេះប្រើវិចារណញ្ញាណឬក៏គ្មានវិចារណញ្ញាណនឹងប្រើ កាលបើឃើញមនុស្សជាន់ខ្ពស់ទទួលរាប់រងហើយ ក៏បណ្ដោយទទួលតាមនាំៗ ។ ការផ្សាយទៅក្នុងមនុស្សជាន់ខ្ពស់មុនមានសេចក្ដីល្អជាច្រើនប្រការ គឺ: ១- នឹងធ្វើឲ្យរស់សប្បាយ ក្នុងរឿងជារបស់ល្អថ្លៃថ្នូរ, ២- នឹងផុតពាក្យតិះដៀលថាល្អតែខាងផ្លូវបញ្ឆោតមនុស្សងឹតងល់, ៣- នឹងធ្វើឲ្យផុតការមើលងាយ ថាជារបស់ថោកទាបមិនសមគួរដល់អ្នកល្អជាដើម ។ ប៉ុន្តែបើបានទទួលការរាប់រងរបស់ជនជាន់ទាបនោះផងទៀតហើយ ក៏នឹងបានផលល្អដល់អ្នកផ្សាយមួយជាន់ទៀតដូចជាគេហុចរបស់ឲ្យអ្នកដឹងថ្លៃពិនិត្យមើល មិនបង្ហួនទៅហុចតែឲ្យសត្វពាហនៈ កាត់ថ្លៃថ្នូរឆ្លោះទេ ការដែលបានឆ្លើយមកនេះ សេចក្ដីពិតនឹងមានយ៉ាងណា ក៏សូមឲ្យសន្និដ្ឋានទៅចុះ ។

២៥៦- ស. ព្រះសាស្តាជាអ្នកត្រាស់ដឹងព្រះធម៌ព្រះអង្គឯង, ព្រះធម៌ជាពាក្យប្រដៅរបស់ព្រះអង្គមែនឬទេ ? ពាក្យដែលថាព្រះអង្គទ្រង់គោរពព្រះធម៌នោះតើទ្រង់ធ្វើដូចម្ដេច ? សូមអធិប្បាយនឹងលើករឿងមកតាំងឲ្យឃើញពិតផង !

www.budinst.gov.kh www.elibraryofcambodia.org

ឬ. ព្រះធម៌ជាពាក្យប្រៀនប្រដៅរបស់ព្រះអង្គមែនហើយ ប៉ុន្តែព្រះអង្គគោរពក្នុងព្រះធម៌នោះ គឺទ្រង់ធ្វើយ៉ាងនេះ៖

ក) មិនទ្រង់លះបង់ព្រះពុទ្ធកិច្ច, ស្ទើរលើករឿងត្រង់ ធ្វើធម្មទេសនាធិដ្ឋាន កាលគង់ក្រោមដើមអជបាលនិគ្រោធ, មុនដំបូង ទ្រង់ពិចារណាធម៌ដែលបានត្រាស់ដឹង ជាគុណជ្រាលជ្រៅ ក្រមនុស្ស អ្នកត្រេកអរក្នុងកាមគុណនឹងដឹងតាមបាន ព្រះហឫទ័យក៏បង្អោនទៅដើម្បី ព្រងើយកន្តើយ មិនគិតសំដែងធម៌ឲ្យប្រៀនប្រដៅជន ប៉ុន្តែព្រះករុណាមក ដាស់តឿនព្រះហឫទ័យឲ្យទ្រង់ប្រារព្ធដល់ពុទ្ធវេនេយ្យ ដែលមានផ្សេងៗគ្នា ដែលគួរនឹងបានទទួលប្រយោជន៍អប់រំទៅតាមលំដាប់ ទើបទ្រង់តាំងព្រះទ័យនឹងសំដែងធម៌, រឿងនេះ បង្ហាញឲ្យឃើញថា ព្រះអង្គទ្រង់គោរព ក្នុងធម៌គឺពុទ្ធកិច្ច មិនសោយវិមុត្តិសុខតែមួយព្រះអង្គឯង ។ នឹងមួយទៀតថា ព្រះអង្គបានទតឃើញឧបនិស្ស័យរបស់អ្នកណានៅជិតឆ្ងាយ សូម្បីជាមនុស្សកាចអាក្រក់រឹងរូសក៏ដោយ ក៏ទ្រង់យាងទៅទូន្មានដែរ ។

ខ) ទ្រង់ប្រព្រឹត្តធម៌គឺគុណសេចក្តីល្អជាគោល, គប្បីឃើញ ក្នុងវេលាជិតនឹងបរិនិព្វានត្រាស់ទូន្មានភិក្ខុសង្ឃថា ធម្មទីបា ភិក្ខវេ វិហរថ ធម្មប្បដិសរណា អនញ្ញសរណាដែលប្រែថា "ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយ ចូរនៅមានធម៌ជាទីពំនាក់ មានធម៌ជាទីពឹង កុំយកវត្ថុដទៃជាសរណៈ

www.budinst.gov.kh www.elibraryofcambodia.org

ទីពឹងឡើយ ៗ ក្នុងទីដទៃមានរឿងដំណាលថា ទ្រង់ព្រះពុទ្ធតម្រិះថា មនុស្សមិនមានទីគោរពរមែងនៅលំបាក ប៉ុន្តែព្រះអង្គសំឡឹងមើលអ្នកដទៃ មិនឃើញថា គួរជាទីគោរពរបស់ព្រះអង្គៗ ទើបទ្រង់តាំងព្រះទ័យកាន់យកព្រះធម៌ជាទីគោរពរបស់ព្រះអង្គ ៗ

ក) មិនទ្រង់បំពារបំពានអំណាចនៃហេតុ, គប្បីឃើញក្នុងកាលប្រទានព្រះពុទ្ធានុញ្ញាតឲ្យមាតុគ្រាម ឧបសម្បទជាភិក្ខុនីដើមដំបូង ព្រះអង្គមិនព្រមប្រទាន តាំងក្រោយព្រះអានន្ទក្រាបទូលសួរថា ស្ត្រីជាភព្វបុគ្គល ដើម្បីនឹងសម្រេចធម៌ពិសេសដូចបុរសបានឬទេ? ព្រះអង្គត្រាស់ថាបាន ៗ ព្រះអានន្ទក្រាបទូលសូមឲ្យប្រទានព្រះពុទ្ធានុញ្ញាត ៗ សូម្បីមិនពេញព្រះហឫទ័យ ក៏នៅតែទ្រង់ព្រះអនុញ្ញាតដែរ ៗ ធ្វើយទក ប៉ុណ្ណោះ ល្មមជាសំអាងបានហើយ ៗ

២៥៣– សំ. បុថុជ្ជនមានការរីករាយប្រព្រឹត្តប្រែប្រួលណាស់ ៗ ព្រះអង្គទ្រង់បំពេញពុទ្ធកិច្ច នៅជាមួយនឹងពួកបុថុជ្ជន មានរឿងគួរឲ្យរំខានព្រះហឫទ័យជាយ៉ាងនានា ៗ ដូចជាចាប់ក្តាមដាក់ចង្អេរ ហេតុអ្វីក៏ទ្រង់អត់ធន់នៅបាន បើទុកជាព្រះអង្គបរិសុទ្ធយ៉ាងក្រៃលែង មិនមានកិលេសដែលជាហេតុឲ្យធុញទ្រាន់ព្រះទ័យ ក៏មែន ប៉ុន្តែបើទ្រង់គង់នៅតែស្ងៀមទៅ ក៏មិនខូចសេចក្តីបរិសុទ្ធិនោះដែរ ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ហេតុតែព្រះមហាករុណា មកចងភ្ជាប់ឲ្យទ្រង់គន់នៅបាន ព្រោះបានពិចារណាឃើញរួចហើយ ក្នុងកាលធ្វើធម្មទេសនាគិតផ្ទួនជាប្រៀបដូចផ្កាឈូកមានបែបផ្សេងៗគ្នា តាំងពីល្អូតឡើងផុតទឹករហូតដល់លិចនៅក្នុងទឹក ត្រូវនឹងបានទទួលអប់រំក្នុងធម៌ជាន់ខ្ពស់ឡើងទៅដោយលំដាប់ ទ្រង់សំដែងធម៌តាំងពីខប្រតិបត្តិក្នុងផ្លូវដ៏រាក់សិនរៀងរហូតឡើងទៅដល់ត្រៃសិក្ខា គឺតាមព្រះពុទ្ធប្រណិធាននេះ ។ កុំថាដល់ព្រះពុទ្ធជាម្ចាស់ឡើយ សូម្បីតែស្ត្រីជាម្តាយរបស់កូនក្មេង ក៏គង់តែអប់រំសេចក្តីខាងនឹងការរស់របស់កូនក្មេងបានដែរ មិនបណ្តែតបណ្តោយឲ្យកូនទៅតាមយថាកម្មតាមចិត្តវាទេ ។

២៥៨_សំ. ការបូជាព្រះអង្គយ៉ាងណា ដែលព្រះអង្គត្រាស់ថាជាការបូជាយ៉ាងក្រៃលែង ? ហេតុអ្វីបានជាត្រាស់យ៉ាងនោះ ?

ឆ. ការប្រតិបត្តិតាមពាក្យប្រដៅរបស់ព្រះអង្គដែលហៅថាព្រះសាសនា បានឈ្មោះថា បដិបត្តិបូជា ។ នេះព្រះអង្គត្រាស់ថាជាការបូជាយ៉ាងក្រៃលែង ។ ព្រោះការបូជាម្យ៉ាងទៀតដែលហៅថាអាមិសបូជា គឺការបូជាដោយអាមិសមានផ្កាធូបទៀនជាដើម ជាការបូជាខាងក្រៅ សូម្បីមានផលក៏មិនស្មើនឹងការប្រតិបត្តិតាម ។ បើបុគ្គលឃើញតែត្រឹមការបូជាដោយអាមិសទៅតាំងអស់គ្នា មិនមានអ្នកណាសិក្សារៀនព្រះបរិយត្តិធម៌

www.budinst.gov.kh www.elibraryofcambodia.org

និងប្រតិបត្តិតាម ព្រះសាសនាក៏នឹងសាបសូន្យអន់ថយចុះលុះដល់អន្តរធានទៅបាត់ ព្រោះមិនមានគោល ៗ បើមានបុគ្គលសូត្ររៀនហើយប្រតិបត្តិតាមដរាបណា ព្រះសាសនាក៏ឈ្មោះថា តាំងនៅបានដរាបនោះ ព្រោះមានគោល ៗ គោលដោយខ្លី ព្រះសាសនាគឺពាក្យប្រៀនប្រដៅនឹងតាំងនៅបានក៏ព្រោះមានមនុស្សរៀនសូត្រហើយប្រតិបត្តិតាម នឹងវិនាសអស់ទៅក៏ព្រោះមិនមានមនុស្សសូត្ររៀនមិនប្រតិបត្តិតាម ៗ ព្រោះហេតុនោះ សម្តេចព្រះមានព្រះភាគ ទើបទ្រង់សរសើរថា ការប្រតិបត្តិតាម ជាការបូជាដ៏ក្រៃលែង ៗ

២៥៩ — ស. ព្រះឱវាទដែលទ្រង់ប្រទានដល់បរិស័ទទាំង ៤ នោះមានដូចម្តេចខ្លះ? ចូរសំដែងល្មមឲ្យឃើញជាតួយ៉ាងមកមើល!

ឆ. បរិស័ទទាំង ៤ នោះរួមចូលជា ២ ពួកគឺ បព្វជិតបរិស័ទ ១ ពួក, គ្រហស្ថបរិស័ទ ១ ពួក ៗ ព្រះឱវាទដែលទ្រង់ប្រទានដល់បព្វជិតបរិស័ទរួមចូលក្នុងសិក្ខា ៣ គឺ សីល, សមាធិ, បញ្ញា ៗ ព្រះឱវាទដែលទ្រង់ប្រទានដល់គ្រហស្ថបរិស័ទរួមចូលក្នុងប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ខាងមុខ ឯប្រយោជន៍បច្ចុប្បន្ន គឺឲ្យឧស្សាហ៍ធ្វើការងារ, ចេះរក្សាទ្រព្យដែលបានមកព្រោះការងារ, ចេះចិញ្ចឹមជីវិតល្មមសមគួរតាមកំឡាំងទ្រព្យ, ចេះសេពគប់មនុស្សល្អជាមិត្រ , ចេះចាយវាយទ្រព្យ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងផ្លូវដែលជាប្រយោជន៍, ទោះប្រព្រឹត្តដល់បុគ្គលដែលខ្លួនជាប់ជំពាក់ផង តាមសមគួរ; ប្រយោជន៍ខាងមុខទ្រង់ប្រដៅឲ្យសន្សំគុណសម្បត្តិគឺ សទ្ធា សីល ចាគៈ បញ្ញា ឬ ចំពេញ ហិរិ ឱត្តប្បៈនិងសុតៈឲ្យគ្រប់ជាអរិយទ្រព្យ ៧ជាដើម ។

២៦០- សំ. ចូរពណ៌នាពីរឿងដែលព្រះសាស្តាទ្រង់គ្រប់គ្រងភិក្ខុបរិស័ទតាំងពីដំបូងមកមើល?

ឆ. ព្រះសាស្តាទ្រង់គ្រប់គ្រងភិក្ខុបរិស័ទដោយអាការៈយ៉ាងនេះ គឺកាលមុនដំបូងដែលទើបនឹងបានត្រាស់ថ្មី ព្រះអង្គទ្រង់ប្រទានឯហិភិក្ខុឧបសម្បទា ដល់កុលបុត្រដែលមានសទ្ធាក្នុងផល គឺឧបសម្បទចំពោះព្រះភក្ត្រដោយអាការត្រាស់ថា «អ្នកចូរជាភិក្ខុមកចុះ» ដូច្នេះជាដើម ហើយអ្នកនោះក៏សម្រេចជាឯហិភិក្ខុ ។ លុះកាលតមក ព្រះសាសនាផ្សាយទូទៅក្នុងទិសផ្សេង ៗ មានជនទាំងឡាយកើតសទ្ធាជ្រះថ្លាក្នុងព្រះសាសនាច្រើនឡើង មកសូមឧបសម្បទ ព្រះអង្គក៏ប្រទានតិសរណគមនូបសម្បទា គឺឧបសម្បទដោយអាការដែលទទួលត្រៃសរណគមន៍ចំពោះមុខសង្ឃ ។ លុះកាលតទៅមក ប្រជុំជនមានសទ្ធាជ្រះថ្លាកាន់តែច្រើនឡើងតាមលំដាប់មកសូមបព្វជ្ជាឧបសម្បទ ព្រះអង្គទើបទ្រង់ប្រទានញត្តិចតុត្ថកម្មវាចាឧបសម្បទា គឺការឧបសម្បទ

www.budinst.gov.kh www.elibraryofcambodia.org

ដោយអាការប្រកាសឲ្យសង្ឃដឹងថា "សង្ឃឲ្យឧបសម្បទដល់កុលបុត្រឈ្មោះនោះហើយ" ប្រកាសឲ្យសង្ឃដឹងថា "សង្ឃបានឲ្យឧបសម្បទដល់កុលបុត្រឈ្មោះនោះ ៣ ដងទៀត" កុលបុត្រនោះក៏សម្រេចជាភិក្ខុបាន ។ មួយទៀត ការឧបសម្បទ ដោយញត្តិចតុត្ថកម្មវាចានោះត្រូវប្រកបដោយសម្បត្តិ ៤ គឺវត្ថុសម្បត្តិ ១, បរិសសម្បត្តិ ១, សីមាសម្បត្តិ ១, កម្មវាចាសម្បត្តិ ១ ជា ៤ ប្រការព្រមទាំងត្រូវធ្វើកិច្ចខាងដើមឲ្យរួចស្រេចជាមុន ហើយព្រះអង្គទ្រង់បញ្ញត្តិតែងតាំងព្រះធម៌វិន័យ ដើម្បីឲ្យពួកពុទ្ធបរិស័ទប្រព្រឹត្តតាម ។

២៦១- សួ. ព្រះអង្គព្រាជ្ញាថាយ៉ាងណា បានជាទ្រង់ឲ្យលើកលែងតិសរណគមនូបសម្បទាចេញ ហើយទ្រង់អនុញ្ញាតឲ្យឧបសម្បទដោយញត្តិចតុត្ថកម្មវាចាវិញ ដែលត្រូវបន្ថែមសេចក្ដីលំបាកនិងខាតវេលាជាច្រើនមកទៀត ?

ច. ព្រះអង្គព្រាជ្ញា និងឲ្យការឧបសម្បទនោះសម្រេចដោយសង្ឃសាមគ្គី គឺប្រឹក្សាយល់ព្រមព្រៀងគ្នា ទើបទ្រង់ឲ្យលើកលែងតិសរណគមនូបសម្បទាដែលជាការសម្រេចដោយបុគ្គលចេញ ។

២៦២- សួ. បើសង្កេតមើលក្នុងពុទ្ធប្រវត្តិ ក្នុងច្បាប់ដទៃក្ដី និងដឹងបានច្បាស់ ជាព្រះសាស្ដាគង់នៅក្នុងនគរណា ច្រើនជាងគេ ? និងអាងអ្វីជាបន្ទាល់ ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. ព្រះអង្គគង់ក្នុងក្រុងសាវត្ថី ច្រើនជាងនគរដទៃៗ តាំងពីទាន-វចនះតាំងដើម ព្រះសូត្រដោយច្រើនជា ឯកំ សមយំ ភគវា សាវត្ថិ-យំ វិហរតិ ដូច្នេះជាបន្ទាល់ ។

២៦៣-សំ. ព្រះធម៌ទាំងអស់ដែលព្រះសាស្ដាបានប្រកាសហើយក្នុងរវាង ៤៥ ឆ្នាំនោះ បើរួមចូលគ្នាទៅតែម្យ៉ាងតើបានដល់អ្វី ? ហេតុដូចម្ដេចបានជាឆ្លើយយ៉ាងនោះ ?

ឆ. មានឧទាហរណ៍ដែលគប្បីឆ្លើយក្នុងប្រស្នានេះជាដូចកាលព្រះអង្គទ្រង់សំដែងអរិយសច្ច ៤ គឺទ្រង់សំដែងថា សេចក្ដីកើតនិងសេចក្ដីរលត់រមែងប្រព្រឹត្តទៅតាមហេតុ សេចក្ដីកើតនឹងមានក៏ព្រោះហេតុកើត សេចក្ដីរលត់នឹងមានក៏ព្រោះហេតុរលត់ៗ សេចក្ដីកើតស្លាប់នឹងសុខទុក្ខ សុទ្ធតែនៅក្នុងអំណាចនៃហេតុ ហើយទ្រង់សំដែងមគ្គជាផ្លូវកណ្ដាល មិនឲ្យធ្លាក់ទៅខាងផ្លូវធូរថយនិងតឹងតាម មិនឲ្យតឹងរឹងហួសទាស់តែលំបាកឥតប្រយោជន៍ ដើម្បីឲ្យពុទ្ធបរិស័ទ ប្រកាន់យកជាបដិបទានៃខ្លួន ឬមួយដូចកាលដែលទ្រង់សំដែងថា ឥដ្ឋផល មិនមែនជារបស់ដែលបុគ្គលនឹងគប្បីបានដោយសេចក្ដីប្រាថ្នានឹងអង្វរទេ រមែងបានដោយបដិបទា ដែលជាហេតុនៃផលនោះៗ ឯង ហើយទ្រង់ដឹកនាំបរិស័ទឲ្យតាំងនៅក្នុងសេចក្ដីមិនប្រមាទ ។

www.budinst.gov.kh www.elibraryofcambodia.org

២៦៤– សំ. មាឃបូជានឹងវិសាខបូជា ដែលពួកពុទ្ធបរិស័ទ ចាត់ធ្វើជាបុណ្យប្រចាំឆ្នាំ ក្នុងថ្ងៃពេញបូណ៌មីខែមាឃនិងថ្ងៃពេញបូណ៌មីខែវិសាខ ជារៀងរាល់ឆ្នាំនោះតើ ព្រោះប្រារព្ធហេតុអ្វី ?

ឆ. មាឃបូជាដែលធ្វើក្នុងថ្ងៃពេញបូណ៌មីខែមាឃ ព្រោះប្រារព្ធហេតុនៃថ្ងៃនោះ ត្រូវនឹងថ្ងៃចតុរង្គសន្និបាត ដែលព្រះសាស្ដាទ្រង់សំដែងនូវឱវាទបាតិមោក្ខដល់ព្រះអរហន្ត១.២៥០ អង្គ តាំងទ្រង់ដាក់ព្រះជន្មាយុសង្ខារ ។ វិសាខបូជាដែលធ្វើក្នុងថ្ងៃ ពេញបូណ៌មីខែវិសាខនោះ ព្រោះប្រារព្ធហេតុនៃថ្ងៃនោះ ត្រូវនឹងថ្ងៃព្រះសាស្ដាប្រសូត, ត្រាស់ដឹង និងបរិនិព្វាន ។

## ចតុរង្គសន្និបាត

២៦៥– សំ. ការសន្និបាតដូចម្ដេចដែលហៅថា ចតុរង្គសន្និបាត ?

ឆ. ដែលហៅថា ចតុរង្គសន្និបាត ព្រោះថាការប្រជុំនោះប្រកបដោយអង្គ ៤ មានចុងក្នុងកាលគត្លីរ បញ្ចេក្ខនី អង្គកចាំនៃចង្អៀនិកាយប្រាប់ថា:

១) មាឃនក្ខត្តេន យុត្តោ បុណ្ណមីឧបោសថទិវសោ ថ្ងៃឧបោសថព្រះចន្ទពេញវង់ (១៥ កើត) ប្រកបដោយផ្កាយនក្ខត្តឫក្សប្រចាំខែមាឃ ។



www.budinst.gov.kh www.elibraryofcambodia.org

២) កេនចិ អនាមន្តិតានិ ហុត្វា អត្តនោយេវ ធម្មតាយ សន្និបតិតានិ អឌ្ឍតេរសានិ ភិក្ខុសតានិ ភិក្ខុ ១.២៥០ អង្គ ឥតអ្នកណានិមន្ត មកប្រជុំគ្នាខ្លួនឯងតែម្តង តាមធម្មតារបស់ខ្លួន ។

៣) តេសុ ឯកោបិ បុថុជ្ជនោ វា សោតាបន្នសកទាគាមិអនាគាមិសុក្ខវិបស្សកអរហន្តេសុ វា អញ្ញតរោ នត្ថិ សព្វេ ឆឡភិញ្ញា វ ភិក្ខុទាំងនោះ ជាបុថុជ្ជន ឬជាសោតាបន្ន ឬសកទាគាមី ឬអនាគាមី ឬព្រះអរហន្តសុក្ខវិបស្សកៈ សូម្បីតែ ១ រូបមិនមានឡើយ មានសុទ្ធតែជាព្រះអរហន្តបានអភិញ្ញា ៦ គ្រប់រូប ។

៤) ឯកោបិ ចេត្ថ សត្ថកេន កេសេ ឆិន្ទិត្វា បព្វជិតោ នាម នត្ថិ សព្វេ ឯហិភិក្ខុយេវ សូម្បីតែភិក្ខុ ១ រូបដែលកោរសក់ដោយកាំបិតកោរហើយបួសក៏គ្មាន សុទ្ធតែជាឯហិភិក្ខុទាំងអស់ ។

២៦៦– សួ. ចតុរង្គសន្និបាតនេះ ព្រះសាស្តាទ្រង់ធ្វើក្នុងទីណា ? មានហេតុដូចម្តេចបានជាទ្រង់ធ្វើ ?

ឆ. ទ្រង់ធ្វើក្នុងវត្តវេឡុវ័ន ។ មានហេតុដើម្បីទ្រង់សំដែងនូវឱវាទបាតិមោក្ខ ។

២៦៧– សួ. បាតិមោក្ខមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

www.budinst.gov.kh www.elibraryofcambodia.org

ឆ. មាន ២ យ៉ាងគឺ:

១) ឱវាទបាតិមោក្ខ ទ្រង់សំដែងជាគាថាទាំង ៣ យ៉ាងថា សព្វបាបស្ស អករណំ= កុំធ្វើបាបទាំងពួងដោយកាយវាចាចិត្ត ១, កុសលស្សូបសម្បទា= ញ៉ាំងកុសលឲ្យដល់ព្រមដោយកាយវាចាចិត្ត ១, សចិត្តបរិយោទបនំ= ជំរះចិត្តរបស់ខ្លួនឲ្យបរិសុទ្ធផូរផង់ចាកគ្រឿងសៅហ្មង មាន លោភៈ ទោសៈ មោហៈ ជាដើម ១ ។

២) អាណាបាតិមោក្ខ ទ្រង់បញ្ញត្តជាមាតិកា ដូចក្នុងសិក្ខាបទ ២២៧ ដែលទ្រង់បញ្ញត្តឲ្យភិក្ខុសំដែងរាល់កន្លះខែ មានបាលីថា សុណាតុ មេ ភន្តេ សង្ឃោ ជាដើម ។

២៦៨-សួ. ចុះព្រះពុទ្ធគ្រប់អង្គ វេលាធ្វើឧបោសថជាមួយនឹងភិក្ខុសង្ឃ ទ្រង់សំដែងបាតិមោក្ខអ្វី ? មានកំណត់វេលាដូចគ្នាគ្រប់អង្គឬផ្សេងគ្នា ?

ឆ. ទ្រង់សំដែងតែឱវាទបាតិមោក្ខ ដោយព្រះអង្គឯង មិនសំដែងអាណាបាតិមោក្ខទេ ។ មិនកំណត់វេលាដូចគ្នាទេ គឺព្រះពុទ្ធវិបស្សី ៦ ឆ្នាំ សំដែងម្តង, ព្រះពុទ្ធជាម្ចាស់របស់យើងកន្លះខែសំដែងម្តង, ព្រះពុទ្ធមានព្រះជន្មវែង ទ្រង់សំដែងរហូតដល់ផុតសាសនា បើព្រះជន្មខ្លី ទ្រង់សំដែងតែក្នុងបឋមពោធិកាល ។

www.budinst.gov.kh www.elibraryofcambodia.org

២៦៩– សួ. ព្រះសាស្តានៃយើងទ្រង់សំដែងឱវាទបាតិមោក្ខបានចំនួនប៉ុន្មានវស្សា ? វេលាទ្រង់ឈប់សំដែង ទ្រង់គង់ក្នុងទីណា ? បានត្រាស់ប្រាប់ភិក្ខុសង្ឃថាដូចម្តេចខ្លះ ?

ឆ. បានចំនួន ២០ វស្សា ក្នុងបឋមពោធិកាល ។ វេលាទ្រង់ឈប់សំដែង ទ្រង់គង់ក្នុងបុព្វារាម លើប្រាសាទនាងវិសាខា បានត្រាស់ប្រាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ តពីនេះទៅមុខទៀត តថាគតឈប់ធ្វើឧបោសថសំដែងឱវាទបាតិមោក្ខហើយ, អ្នកទាំងឡាយគប្បីធ្វើឧបោសថសំដែងអាណាបាតិមោក្ខចុះ ព្រោះតថាគតធ្វើឧបោសថសំដែងបាតិមោក្ខជាមួយនឹងបរិស័ទដែលមិនបរិសុទ្ធនោះ មិនបានជាការទេ ។ តាំងពីកាលនោះមក ភិក្ខុទាំងឡាយក៏សំដែងតែអាណាបាតិមោក្ខដរាបដល់សព្វថ្ងៃនេះ ។

២៧០– សួ. ព្រះបាទពិម្ពិសារ បានក្រាបទូលប្រកាសសេចក្តីប្រាថ្នាប៉ុន្មានប្រការ ដែលព្រះអង្គតាំងទុកតាំងពីនៅជាព្រះរាជកុមារ ចំពោះព្រះសាស្តា ? ព្រះប្រាថ្នាទាំងនោះបានសម្រេចឬទេ ?

ឆ. មាន ៥ ប្រការគឺ:

១) សូមឲ្យជនទាំងឡាយ ដែលតាក់តែងរាជសម្បត្តិ គប្បីអភិសេកយើងក្នុងរាជសម្បត្តិ ជាព្រះរាជាដែនមគធរដ្ឋ ។

www.budinst.gov.kh www.elibraryofcambodia.org

២) សូមឲ្យអរិយព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ស្ដេចមកប្រតិស្ឋានព្រះសាសនាក្នុងផែនដីនៃយើងដែលបានអភិសេកហើយ ។

៣) សូមឲ្យខ្លួនយើងបានចូលទៅក្នុងយដ្ឋព្រះដ៏មានព្រះភាគជាម្ចាស់នោះ ។

៤) សូមឲ្យព្រះដ៏មានព្រះភាគជាម្ចាស់នោះ ទ្រង់សំដែងធម៌ដល់យើង ។

៥) សូមឲ្យយើងបានត្រាស់ដឹងនូវធម៌របស់ព្រះដ៏មានព្រះភាគជាម្ចាស់នោះ ។

សេចក្ដីប្រាថ្នាទាំង ៥ នេះ បានសម្រេចដល់ព្រះបាទពិម្ពិសារគ្រប់ប្រការ ។

២៣១–ស, ព្រះសាស្ដាទ្រង់បំពេញសត្ថុកិច្ច គឺទ្រង់ប្រោសប្រជាជនដោយប្រយោជន៍ប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ. មានប្រយោជន៍ ៣ យ៉ាងគឺ:

១)– ទិដ្ឋធម្មិកត្ថ. ប្រយោជន៍ដែលនឹងគប្បីបានក្នុងបច្ចុប្បន្ន ។

២)– សម្បរាយិកត្ថ= ប្រយោជន៍ដែលនឹងគប្បីបានក្នុងអនាគត ។

www.budinst.gov.kh www.elibraryofcambodia.org

៣)- **បរមត្ថ** = ប្រយោជន៍យ៉ាងក្រៃលែងគឺព្រះនិព្វាន ។

២៧១- ស. ធម៌អ្វីហៅថា សាមុក្កំសិកធម៌ ? ធម៌នេះព្រះសាស្តាសំដែងចំពោះតែមនុស្សប្រកបដោយអង្គប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ. អរិយសច្ចតាំង ៤ ប្រការហៅថា សាមុក្កំសិកធម៌ ។ ធម៌នេះព្រះសាស្តាទ្រង់សំដែងចំពោះតែគ្រហស្ថប្រកបដោយអង្គ ៣ គឺ៖

១)- **ជាមនុស្ស** = មិនមែនអមនុស្សដូចទេវតាយក្សប្រេតជាដើម ។

២)- **ជាគ្រហស្ថ** = មិនមែនជាអ្នកបួស ។

៣)- **មានឧបនិស្ស័យចាស់ក្លា** = គួរសម្រេចលោកុត្តរធម៌ក្នុងទីនោះ ។ បើមិនព្រមដោយអង្គ ៣ នេះទេ ព្រះអង្គទ្រង់ប្រដៅដោយសុត្តគោវាទដទៃតាមការណ៍គួរ ។

២៧២- ស. ព្រះសាស្តាកាលទ្រង់ប្រដៅប្រជាជន តើទ្រង់ប្រដៅដោយអាការៈប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ. ដោយអាការៈ ៤ យ៉ាងគឺ៖

១)- **សន្ទស្សនា** = ទ្រង់សំដែងកម្មដែលមានទោសគួរលះវៀរ និងកម្មមិនមានទោសគួរប្រកប ឲ្យអ្នកស្តាប់ឃើញដោយល្អ ដូចធ្វើក្នុងទីចំពោះមុខ ។

www.budinst.gov.kh www.elibraryofcambodia.org

(២) សមាទបនា = ដឹកនាំឲ្យអ្នកស្ដាប់ស្ញើកាន់ដោយល្អ ដែលជាកិច្ចគួរលះបង់នឹងគួរប្រព្រឹត្តជាដើម ។

៣ សមុត្តេជនា = ឲ្យអ្នកស្ដាប់ក្លាហានឡើងដោយល្អ ក្នុងកាលដែលនឹងលះបង់ក្ដីនឹងចំរើនជាដើម ។

(៤) សម្បហំសនា = ពណ៌នាគុណនៃសេចក្ដីលះបង់ នឹងសេចក្ដីចំរើននោះៗ ឲ្យអ្នកស្ដាប់រីករាយសប្បាយចិត្ត ។

២៧៤ — សំ. ព្រះសាស្ដាទ្រង់សំដែងធម៌ប្រដៅប្រជាជន ដើម្បីប្រយោជន៍ប៉ុន្មានប្រការ គឺអ្វីខ្លះ ?

ប. ដើម្បីប្រយោជន៍ ១០ ប្រការគឺ:

១) វិសំយោគាយ = ដើម្បីនឹងឲ្យរួចសំយោគកិលេស ជាគ្រឿងប្រកបសត្វ មិនបានសំដែងដើម្បីនឹងឲ្យព័ន្ធព័ន្ធខ្លួនប្រកបដោយកិលេសជាគ្រឿងប្រកប ។

២) អនុបាទាយ = ដើម្បីនឹងឲ្យឃ្លាតចេញនូវឧបាទានទាំង ៤ គឺ កាមុបាទាន, ទិដ្ឋុបាទាន, សីលព្វតុបាទាន, អត្តវាទុបាទាន ។

៣) មទនិម្មទនាយ = ដើម្បីឲ្យបាត់សេចក្ដីស្រវឹង ។

www.budinst.gov.kh www.elibraryofcambodia.org

៤) បិបាសវិនយាយ = ដើម្បីនឹងឲ្យតាំបង់នូវតណ្ហាដូចជាការស្រេកទឹក ។

៥) អាលយសមុគ្ឃាតាយ = ដើម្បីនឹងឲ្យដកចោលនូវអាល័យឆន្ទស្នេហាសេចក្តីស្រឡាញ់ ។

៦) វដ្ដុបច្ឆេទាយ = ដើម្បីនឹងឲ្យចូលទៅកាត់ចោលនូវវដ្តៈ ។

៧) តណ្ហាក្ខយាយ = ដើម្បីនឹងឲ្យអស់ទៅនៃតណ្ហាជាគ្រឿងក្តៅក្រហាយ ។

៨) វិរាគាយ = ដើម្បីនឹងឲ្យវិនាសប្រាសចាកកិលេសដ៏ប្រលាក់ចិត្ត ។

៩) និរោធាយ = ដើម្បីនឹងឲ្យរលត់សូន្យរលត់មិនសល់នៃកិលេសនឹងកងទុក្ខ ។

១០) និព្វានាយ = ដើម្បីព្រះនិព្វាន សេចក្តីរលត់មិនសល់នៃភ្លើងកិលេសមានរាគៈជាដើមឲ្យសូន្យអស់ជានិរវសេស ។

សម្តេចព្រះដ៏មានព្រះភាគទ្រង់សំដែងធម៌ប្រដៅវេនេយ្យសត្វទេវតាមនុស្សដោយអាការវិធីដើម្បីប្រយោជន៍គុណ គឺ វិមុត្តិ អនុត្តរៈឲ្យសត្វផុតចាកសង្សារទុក្ខទាំងពួងដោយប្រការដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

២៧៥ – ស. ពុទ្ធបរិស័ទបំណែកភិក្ខុ នឹងភិក្ខុនី ដែលចូលមកឧបសម្បទក្នុងព្រះធម៌វិន័យដោយវិធីផ្សេងៗគ្នា ប៉ុន្តែបើរួមជាប្រភេទមានប៉ុន្មានយ៉ាង តើអ្វីខ្លះ ? ឧបសម្បទាណាសម្រេចដោយអ្វី ?

ច. មាន ៤ យ៉ាងគឺ ៖

១) ឯហិភិក្ខុឧបសម្បទា = ឧបសម្បទដោយឯហិភិក្ខុ ។

២) តិសរណគមនូបសម្បទា = ឧបសម្បទដោយការដល់សរណគមន៍ ៣ ។

៣) ញត្តិចតុត្ថកម្មឧបសម្បទា = ឧបសម្បទដោយញត្តិចតុត្ថកម្ម ។

៤) អដ្ឋវាចិកូបសម្បទា = ឧបសម្បទដោយញត្តិចតុត្ថកម្ម-វាចាក្នុងសង្ឃទាំង ២ ពួក រួមជា ៨ កម្មវាចានេះចំពោះតែនាងភិក្ខុនី ។ ឧបសម្បទា ២ ខាងដើម សម្រេចដោយបុគ្គល ។ ឧបសម្បទា ២ ខាងចុង សម្រេចដោយសង្ឃ ។

២៧៦ – ស. ភិក្ខុសាមណេរក្នុងសម័យបច្ចុប្បន្ននេះ ទទួលឧបសម្បទ និងបព្វជ្ជាដោយវិធីដូចម្តេច ?

ច. កាលជាខាងក្រោយមក ទ្រង់អនុញ្ញាតឲ្យបំបួសភិក្ខុដោយញត្តិ

www.budinst.gov.kh www.elibraryofcambodia.org

ចតុត្ថឧបសម្បទា ហើយទ្រង់បញ្ឈប់ឧបសម្បទា២ខាងដើមចេញ ប៉ុន្តែទ្រង់ផ្លាស់តិសរណគមនូបសម្បទាឲ្យជាវិធីបព្វជ្ជារបស់សាមណេរវិញ ។

២៧៧ - ស. បណ្ដាបុរសនិងស្ត្រីអ្នកឧបសម្បទនិងបព្វជ្ជាក្នុងធម៌វិន័យ ហៅថាអ្វី ? ប្រែថាម៉េច ? មានប៉ុន្មានពួក ? គឺអ្វីខ្លះ ?

ឆ. ហៅថា សហធម្មិកៈ ប្រែថា "អ្នកប្រព្រឹត្តធម៌រួមគ្នា" មាន ៥ ពួកគឺ ភិក្ខុ១, ភិក្ខុនី ១, សិក្ខមានា១, សាមណេរ១, សាមណេរី ។

២៧៨ - ស. ច្បាប់ទម្លាប់ដែលព្រះសាស្ដាទ្រង់បញ្ញត្តសម្រាប់ពួកភិក្ខុហៅថាអ្វី ? ទ្រង់ឃើញអំណាចប្រយោជន៍ប៉ុន្មានប្រការ បានជាទ្រង់បញ្ញត្ត ?

ឆ. ហៅថា វិន័យ ។ ទ្រង់ឃើញអំណាចប្រយោជន៍ ១០ ប្រការគឺៈ

១) សង្ឃសុដ្ឋុតាយ= ដើម្បីកិរិយាទទួលថាល្អហើយនៃសង្ឃ ។

២) សង្ឃផាសុតាយ= ដើម្បីការនៅសប្បាយនៃសង្ឃ ។

៣) ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ= ដើម្បីនឹងសង្កត់សង្កិននូវបុគ្គលអ្នកមិនមានសីល ។

៤) បេសលានំ ភិក្ខូនំ ផាសុវិហារាយ= ដើម្បីការនៅសប្បាយនៃភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ។

www.budinst.gov.kh www.elibraryofcambodia.org

៥) ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ= ដើម្បីនឹងបិទនូវអាសវៈទាំងឡាយដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាលឃើញប្រាកដ

៦) សម្បរាយិកានំ អាសវានំ បដិឃាតាយ= ដើម្បីនឹងកំចាត់បង់នូវអាសវៈទាំងឡាយដែលនឹងកើតមានក្នុងកាលខាងមុខ

៧) អប្បសន្នានំ វា បសាទាយ= ដើម្បីសេចក្ដីជ្រះថ្លានៃជនទាំងឡាយដែលមិនជ្រះថ្លា គឺដើម្បីញុំាងជនទាំងឡាយអ្នកមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង

៨) បសន្នានំ វា ភិយ្យោភាវាយ= ដើម្បីសេចក្ដីកើតក្រៃលែងនៃជនទាំងឡាយអ្នកជ្រះថ្លាហើយ គឺឲ្យជនអ្នកជ្រះថ្លារួចហើយនឹងរឹតតែជ្រះថ្លាខ្លាំង ៗ ឡើង

៩) សទ្ធម្មដ្ឋិតិយា= ដើម្បីការតាំងនៅនៃព្រះសទ្ធម្ម

១០) វិនយានុគ្គហាយ= ដើម្បីនឹងអនុគ្រោះនូវវិន័យ

២៧៩– ស. ព្រះពុទ្ធោវាទដែលទ្រង់ទេសនាប្រដៅពុទ្ធបរិស័ទក្នុងរវាង ៤៥ ឆ្នាំ បើរួមឲ្យខ្លីមកមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? ហៅថាអ្វី ?

ប. មាន ២ យ៉ាងគឺ ព្រះធម៌ ១, វិន័យ ១ ៗ ហៅថាបាវចន គឺពាក្យដែលជាប្រធាន ៗ

www.budinst.gov.kh www.elibraryofcambodia.org

២៨០–សំ. ចុះព្រះធម៌នឹងព្រះវិន័យទាំង ២ នោះ លោកសំដៅយកអ្វីជាផលទីបំផុតតែម្យ៉ាង ?

ឆ. លោកសំដៅយកវិមុត្តិរសតែម្យ៉ាង ជាផលទីបំផុតរបស់ព្រះធម៌នឹងព្រះវិន័យ ប្រៀបដូចមហាសមុទ្រទោះបីទុកជាធំជ្រៅប៉ុនណាក៏ទឹកមានរសប្រៃដូចគ្នាតែមួយ នេះជាសេចក្តីអស្ចារ្យនៃមហាសមុទ្រដូចម្តេចមិញ សូម្បីតែព្រះធម៌វិន័យដែលជានិយសាសនានេះដ៏វិចិត្រដោយធម្មប្បភេទនឹងបញ្ញត្តិវិសេសយ៉ាងណា ក៏មានវិមុត្តិសេចក្តីផុតវិសេសចាកបច្ចត្តិកិលេសបាបធម៌ជារស ជាផលទីបំផុតដូច្នោះដែរ ។

២៨១–សំ. ព្រះធម៌វិន័យ ពាក្យប្រដៅរបស់សម្តេចព្រះបរមសាស្តានោះ ចែកដោយអង្គមានប៉ុន្មានយ៉ាងគឺអ្វីខ្លះ ? ហៅថាអ្វី ?

ឆ. មានអង្គ ៩ យ៉ាង ហៅថានវង្គសត្ថុសាសនៈ គឺៈ

១) សុត្តៈ បានដល់ពាក្យសំដែងសេចក្តីមានរឿងប្រកបផង ។
២) គេយ្យៈ បានដល់របៀបពាក្យដែលជាចុណ្ណិយបទ នឹងគាថាៗ
៣) វេយ្យាករណៈ បានដល់របៀបពាក្យចុណ្ណិយបទសុទ្ធ ។
៤) គាថា បានដល់របៀបពាក្យជាគាថាសុទ្ធ ។

www.budinst.gov.kh www.elibraryofcambodia.org

៥) ឧទាន បានដល់របៀបពាក្យដែលព្រះដ៏មានព្រះភាគទ្រង់លើកឡើងអាស្រ័យដោយព្រះសោមនស្សញ្ញាណ ។

៦) ឥតិវុត្តកៈ បានដល់របៀបពាក្យដែលមាន ។ខ្ទុសនិខ្ទុសនិតទ ។

៧) ជាតក បានដល់របៀបពាក្យដែលសំដែងបុព្វចរិត ។

៨) អព្ភូតធម្ម បានដល់របៀបពាក្យសំដែងអច្ឆរិយធម៌ ។

៩) វេទល្លៈ បានដល់របៀបពាក្យដែលអ្នកសួរបានសេចក្តីដឹងធម៌ច្បាស់ និងសេចក្តីត្រេកអរហើយសួរតៗ ជាលំដាប់ទៅ ។

២៨២–ស. ហេតុប៉ុន្មានប្រការដែលធ្វើឲ្យផែនដីកម្រើកញាប់ញ័របាន ?

ឆ. ព្រះសាស្តាទ្រង់ត្រាស់ប្រាប់អានន្ទថា ហេតុដែលឲ្យផែនដីញាប់ញ័រមាន ៨ ប្រការគឺ:

១) ខ្យល់កំរើក

២) អ្នកមានឫទ្ធិបណ្តាល

៣) ព្រះពោធិសត្វចុះចាកតុសិតសួគ៌មកកាន់ព្រះគភ៌

៤) ព្រះពោធិសត្វប្រសូត

៥) ព្រះតថាគតត្រាស់ដឹង

www.budinst.gov.kh www.elibraryofcambodia.org

៦) ព្រះតថាគតទ្រង់ដាក់ព្រះជន្មាយុសង្ខារ

៧) ព្រះតថាគតទ្រង់សំដែងបឋមទេសនា

៨) ព្រះតថាគតនិព្វាន ។

២៨៣– សំ. កាលព្រះសាស្ដាគង់ក្នុងភណ្ឌគ្រាមបានប្រទានឱវាទដល់ភិក្ខុសង្ឃសំដែងអំពីអរិយធម៌ប៉ុន្មានប្រការ គឺអ្វីខ្លះ? មានសេចក្ដីអធិប្បាយដូចម្ដេច ?

ច. ទ្រង់សំដែងអំពីអរិយធម៌ ៤ ប្រការថា ព្រោះហេតុដែលមិនបានចាក់ធ្លុះចំពោះអរិយធម៌៤ប្រការ គឺសីល ១, សមាធិ ១, បញ្ញា ១, វិមុត្តិ ១; ទើបជាហេតុឲ្យសព្វសត្វត្រាច់រង្គាត់នៅក្នុងវដ្ដសង្សារ ហេតុនោះ សូមភិក្ខុសង្ឃបំពេញអរិយធម៌ឲ្យបរិបូណ៌ ដើម្បីជាប្រយោជន៍ដល់ខ្លួននិងប្រជាជនតទៅទៀត ហើយទ្រង់ប្រទានឱវាទដទៃទៀតរួមចូលក្នុងសីល សមាធិ បញ្ញា ព្រោះសិក្ខាទាំង ៣ នេះជាផ្លូវនៃវិមុត្តិ ដែលជាខ្លឹមសាររបស់ព្រះធម៌វិន័យ ។

២៨៤– សំ. កាលព្រះសាស្ដាគង់ក្នុងភោគនគរក្បែរអានន្ទចេតិយ ទ្រង់សំដែងមហាបទេស ៤ ផ្នែកខាងព្រះសូត្រ ដល់ភិក្ខុសង្ឃដើម្បីជាគ្រឿងវិនិច្ឆ័យធម៌វិន័យ មានសេចក្ដីថាដូចម្ដេចខ្លះ?

ច. មានសេចក្ដីថា "បើអ្នកណានីមួយមកអាងព្រះបរមសាស្ដា

www.budinst.gov.kh www.elibraryofcambodia.org

សង្ឃ គណៈ ឬ បុគ្គល ហើយសំដែងថានេះជាធម៌ជាវិន័យ ក៏កុំគប្បីជឿជាមុន គប្បីប្រៀបធៀបជាមួយសូត្រនិងវិន័យមុនសិន បើឃើញថាត្រូវគ្នា ទើបគួរជឿបាន បើឃើញថាប្លែកគ្នាខុសគ្នា ក៏មិនគួរជឿ" ។

២៨៥– ស. បុគ្គលដូចម្តេចឈ្មោះថាថូបារហបុគ្គល ? មានប៉ុន្មាន ? គឺលោកណាខ្លះ?

ឆ. អច្ឆរិយបុរសដែលគួរបញ្ចុះក្នុងព្រះស្តូបឈ្មោះថា ថូបារហបុគ្គល មាន ៤ គឺ:

សម្តេចព្រះសម្មាសម្ពុទ្ធ១, ព្រះបច្ចេកសម្ពុទ្ធ១, ព្រះតថាគតសាវ័ក១, ព្រះបាទចក្រពត្តិរាជ ១ ។

២៨៦– ស. ព្រះពុទ្ធចរិយាមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? មានសេចក្តីអធិប្បាយប្លែកគ្នាដូចម្តេច?

ឆ. មាន ៣ យ៉ាងគឺ លោកត្ថចរិយា= ទ្រង់ប្រព្រឹត្តជាប្រយោជន៍ដល់លោក ១, ញាតត្ថចរិយា= ទ្រង់ប្រព្រឹត្តជាប្រយោជន៍ដល់ព្រះញាតិ ឬដោយឋានៈជាព្រះញាតិ១, ពុទ្ធត្ថចរិយា=ទ្រង់ប្រព្រឹត្តជាប្រយោជន៍ដោយឋានៈជាព្រះពុទ្ធ ១ ។

មានសេចក្តីអធិប្បាយប្លែកគ្នាដូច្នេះ

ក) លោកត្ថចរិយា= បានដល់កិរិយាដែលទ្រង់ប្រព្រឹត្តជាប្រ

www.budinst.gov.kh www.elibraryofcambodia.org

ប្រយោជន៍ដល់មហាជន ដែលរាប់ជាសត្វលោកទូទៅ ដូចទ្រង់ផ្សាយព្រះញាណទតមើលនិស្ស័យសត្វលោករាល់ថ្ងៃ អ្នកណាមកប្រាកដក្នុងសំណាញ់ញាណរបស់ព្រះអង្គៗ ក៏យាងទៅប្រោសអ្នកនោះ ៗ មួយទៀតទ្រង់សង្គ្រោះមនុស្សទាំងឡាយដោយឋានៈជាមនុស្សដូចគ្នា ក៏រាប់បញ្ចូលក្នុងលោកត្ថចរិយានេះដែរ ។

ខ) ញាតត្ថចរិយា= បានដល់កិរិយាដែលទ្រង់សង្គ្រោះពួកព្រះញាតិដោយឋានៈជាព្រះញាតិ ដូចយ៉ាងទ្រង់អនុញ្ញាតឲ្យពួកសាក្យ-រាជជាព្រះញាតិដែលចូលជាពួកតិរ្ថិយហើយ នឹងត្រឡប់ចូលមកឧប-សម្បទក្នុងព្រះពុទ្ធសាសនាមិនបាច់នៅតិរ្ថិយបរិវាស ៤ ខែមុន ដូចពួកតិរ្ថិយដទៃទេ នេះជាញាតត្ថចរិយាដោយចំពោះ ។ បើនឹងពិនិត្យមើលព្រះពុទ្ធចរិយាដែលប្រព្រឹត្ត ដើម្បីសង្គ្រោះព្រះញាតិនោះឃើញថា ការដែលទ្រង់យាងទៅទេសនាប្រោសព្រះញាតិនៅនគរកបិលពស្តុ ការដែលទ្រង់យាងទៅហាមឃាត់ព្រះញាតិពួកសាក្យៈនិងកោលិយៈដែលវិវាទគ្នាដោយហេតុដណ្តើមទឹកស្ទឹងបញ្ចូលស្រែក្តី ក៏ចាត់ចូលក្នុងញាតត្ថចរិយានេះដែរ ។

គ) ពុទ្ធត្ថចរិយា= នោះបានដល់ពុទ្ធកិច្ចដែលទ្រង់បំពេញឲ្យជាប្រយោជន៍ដល់មហាជន ដោយឋានៈជាព្រះពុទ្ធ ដូចទ្រង់បញ្ញត្តសិក្ខា-

www.budinst.gov.kh www.elibraryofcambodia.org

បទដ៏ជាគាថាព្រហ្មចរិយៈខ្លះ ដ៏ជាអភិសមាចារខ្លះ ដើម្បីសង្កត់សង្កិនពួកភិក្ខុអ្នកឥតអៀនខ្មាសហៅថាទុម្មង្កុ អ្នកអៀនខ្មាសដោយក្រ គឺមិនសូវអោះអៀនខ្មាសខ្លះ ហៅថា អលជ្ជី អ្នកឥតខ្មាសខ្លះ ដើម្បីដាក់របៀបដឹកនាំសេចក្ដីប្រព្រឹត្តនៃពួកភិក្ខុអ្នកប្រាថ្នាល្អ ដែលហៅថាបេសលៈខ្លះ អ្នកមានសេចក្ដីអៀនខ្មាស ដែលហៅថាលជ្ជីខ្លះ ហើយទ្រង់ប្រកាសសាសនាឲ្យពុទ្ធបរិស័ទ តាំងគ្រហស្ថតាំងបព្វជិតបានដឹងជ្រួតជ្រាបព្រះសទ្ធម្មទៅ ទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនាឲ្យស្ថិតស្ថេរចិរកាលផ្សាយមកដល់សព្វថ្ងៃនេះ ទើបពោលដោយទ្វីភាពបញ្ចូលគុណពុទ្ធបរិយាទាំងអស់ ។

២៨៧-ស. ព្រះគុណនៃព្រះសាស្ដាមានច្រើនប្រការណាស់ ប៉ុន្តែលោកបំប្រួញចូលគុណសម្បទាប៉ុន្មានយ៉ាងគឺអ្វីខ្លះ ? សម្បទាណាចែកចេញជាប៉ុន្មានយ៉ាងទៅទៀត ?

ឆ. លោកបំប្រួញចូលគុណសម្បទា ៣ គឺ:

១) ហេតុសម្បទា= បានដល់ព្រះមហាករុណាសមាយោគៈ គឺការដែលព្រះអង្គទ្រង់ប្រកបដោយព្រះករុណាធំក្នុងសត្វទាំងអស់ និងកាភិសង្ខារៈ បានដល់ការដែលទ្រង់ខុសប្បហ៊កសាងព្រះបារមីពុទ្ធការកធម៌មិនរួញរាព្រះទ័យ ដែលជាហេតុបញ្ចូនឲ្យផ្ដល់ផល ។

២) ផលសម្បទា= បានដល់ការដល់ព្រមដោយគុណសម្បត្តិ

ដ៏ជាផល ដែលជាប់មកអំពីហេតុសម្បទា ចែកចេញដោយប្រភេទជា ៤ ប្រការគឺៈ

ក) ញាណសម្បទា= បានដល់ការដល់ព្រមដោយព្រះបញ្ញាញាណដ៏ភ្លឺច្បាស់ក្នុងមគ្គផល ។

ខ) បហានសម្បទា= បានដល់ការដល់ព្រមដោយកិរិយាលះកិលេសព្រមទាំងវាសនាបានដាច់ស្រឡះ ។

គ) អានុភាវសម្បទា= បានដល់ការដល់ព្រមដោយអានុភាពគឺទ្រង់សំដែងឫទ្ធិផ្សេងៗបាន ។

ឃ) រូបកាយសម្បទា= បានដល់ការដល់ព្រមដោយទ្វត្តឹស-មហាបុរិសលក្ខណៈ គឺអសីត្យានុព្យញ្ជនៈ ជានយនាភិសេករបស់សកលលោក ។

៣) សត្តូបការសម្បទា= បានដល់ការដែលទ្រង់នូវឧបការដល់សត្វមិនមានប្រមាណ ចែកបានជា ២ ប្រការគឺៈ

ក) អាសយសម្បទា= បានដល់ការដែលព្រះអង្គមានព្រះហឫទ័យត្រជាក់ត្រជុំដោយព្រះករុណាជានិច្ច សូម្បីក្នុងសត្វដែលធ្វើខុសមានទេវទត្តជាដើម ។

www.budinst.gov.kh www.elibraryofcambodia.org

៩) បយោគសម្បទា= បានដល់ការដែលព្រះអង្គ ទ្រង់សំដែងធម៌ដោយមិនឃើញដល់អាមិសឡើយ ទ្រង់ប្រាថ្នាតែប្រយោជន៍ដល់អ្នកស្តាប់ពិតៗ ។

ព្រះគុណនៃសម្តេចព្រះដ៏មានព្រះភាគ រាប់តាំងតំពីប្រសូតរហូតដល់បរិនិព្វាន បំព្រួញចូលក្នុងសម្បទាទាំង ៣ ដោយប្រការដូច្នេះ ។

២៨៨–សំ. ធម្មសមោធាន គឺធម៌ដែលឲ្យសម្រេចព្រះពុទ្ធភូមិ មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ. មាន ៨ យ៉ាងគឺ:

១) មនុស្សសម្បត្តិ= ជាមនុស្ស កាលចាប់ផ្តើមតាំងសេចក្តីប្រាថ្នាពោធិញ្ញាណ ។

២) លិង្គសម្បត្តិ= ដល់ព្រមដោយភេទ គឺបុរស, ស្ត្រីប្រាថ្នាមិនបាន ; បើជាស្ត្រី ត្រូវប្រាថ្នាឲ្យកើតជាបុរសមុនសិន ។

៣) ហេតុសម្បត្តិ= ដល់ព្រមដោយឧបនិស្ស័យជាហេតុកសាងកុសលច្រើន (រាប់បាន ១ សែនមហាកប្ប ហើយ តាំងនៅក្នុងភូមិសាវកបារមីអាចសម្រេចព្រះអរហត្តក្នុងជាតិនោះ) ។

៤) សត្ថុទស្សនសម្បត្តិ= បានជួបឃើញព្រះពុទ្ធជាម្ចាស់ (គឺតាំងសេចក្តីប្រាថ្នាចំពោះព្រះភក្ត្រ ព្រះពុទ្ធហើយបានទទួលពុទ្ធព្យាករណ៍) ។

www.budinst.gov.kh www.elibraryofcambodia.org

៥) បញ្ញាសម្បត្តិ=បានបញ្ញា ( ទ្រង់ភេទបព្វជិតជាភិក្ខុ សា-មណេរឬឫសី , មុនី ឬតាបសអ្នកជាកម្មវាទី ) ។

៦) គុណសម្បត្តិ= ប្រកបដោយគុណវិសេស មានឈានសមាបត្តិជាដើម ។

៧) អធិការសម្បត្តិ= បំពេញបុញ្ញាភិសម្ភារ យ៉ាងលើសលប់-ដូចមហាបរិច្ចាគ ៥ ។

៨) ឆន្ទតាសម្បត្តិ= មានឆន្ទៈដ៏ខ្លាំងក្លាក្នុងពោធិញ្ញាណ។

ធម៌ទាំង៨ ប្រការនេះ ជាអភិនីហារឲ្យសម្រេចសព្វញ្ញុតញ្ញាណរបស់ព្រះពោធិសត្វ ។

២៨៩ ស. ចូរប្រាប់ថ្ងៃ ខែ ឆ្នាំនិងពេលព្រះជន្មក្នុងកាលនីៗមានកាលព្រះសាស្ដាចុះចាប់បដិសន្ធិជាដើម ឲ្យសព្វគ្រប់មកមើល ?

ឆ. ព្រះសាស្ដាចុះចាប់បដិសន្ធិក្នុងថ្ងៃ ៥ ១៥ ៨ ឆ្នាំរកា វេលារាត្រីជិតភ្លឺមុន ព.ស. ៨១ ឆ្នាំ ។

កាលប្រសូតក្នុងថ្ងៃ ៦ ១៥ ៦ ឆ្នាំច វេលាថ្ងៃជិតត្រង់មុន ព.ស.-៨០ ឆ្នាំ ។

កាលសោយរាជសម្បត្តិក្នុងថ្ងៃ ៧ ១៥ ៨ ឆ្នាំឆ្លូវ មុន ព.ស. ៦៤-ឆ្នាំ ព្រះជន្មាយុបាន១៦ ឆ្នាំ ។

www.budinst.gov.kh www.elibraryofcambodia.org

កាលចេញបព្វជ្ជាក្នុងថ្ងៃ ៤ ១៥ ៦ ឆ្នាំរកា វេលាបែកបច្ចូស មុន ព.ស. ៨៥ ឆ្នាំ ព្រះជន្មាយុបាន ៣៥ ឆ្នាំ ។

កាលសំដែងបឋមទេសនាក្នុងថ្ងៃ ១ ១៥ ៨ ឆ្នាំរកា មុន ព.ស. ៤៥ ឆ្នាំ ។

កាលដាក់ព្រះជន្មាយុសង្ខារក្នុងថ្ងៃ ១ ១៥ ៣ ឆ្នាំរោងមុន ព.ស. ២ ឆ្នាំ ។

កាលបរិនិព្វានក្នុងថ្ងៃ ៣ ១៥ ៦ ឆ្នាំម្សាញ់ វេលាបែកបច្ចូស មុន ព.ស. ១ ឆ្នាំ ព្រះជន្មាយុបាន ៨០ ឆ្នាំ ។

កាលកំណត់ពុទ្ធសករាជ គឺចាប់ផ្ដើមតាំងពីថ្ងៃ ១ ១៥ ៦ ឆ្នាំមមី ។

កាលគ្រប់ប្រាំពាន់ឆ្នាំនៃព្រះសាសនា ក្នុងឆ្នាំជូត ។

២៩០-សំ. ចុះកាលដែលមិនទាន់មានពុទ្ធសករាជនោះតើ អ្នកស្រុកឥណ្ឌាបូរាណប្រើសករាជអ្វី? ប្រើមកបានប៉ុន្មានឆ្នាំ?

ចំ. គេប្រើមហាព្រហ្មិន្ទសករាជ ប្រើមកបានប្រមាណ ២.០០០ ឆ្នាំសេស ទើបកើតមានពុទ្ធសករាជឡើង ។

ប្រស្នាពុទ្ធប្រវត្តិ ចប់តែប៉ុណ្ណេះ

www.budinst.gov.kh www.elibraryofcambodia.org

១– គាថាសោឡសជនបទ

អង្គា មគធំ កាសី   វជ្ជីមល្លា កោសលំ
ចេតី វំសំ កុរុញ្ចាបិ   សុរសេនញ្ច អស្សកំ
បញ្ចាលម្បិ ច មច្ឆញ្ច   គន្ធារញ្ចាបិ កម្ពោជំ
អវន្តិមេ ច សោឡស   ជម្ពុទីបេ បកាសិតា ។

ជនបទទាំងឡាយ ១៦ នេះគឺ អង្គៈ១, មគធៈ១, កាសី១, វជ្ជី១, មល្លៈ១, កោសល១, ចេតី១, វំសៈ១, កុរុ១, សុរសេនៈ១, អស្សកៈ១, បញ្ចាលៈ១, មច្ឆៈ១, គន្ធារៈ១, កម្ពោជៈ១, អវន្តិ១ បានមានប្រាកដហើយក្នុងជម្ពូទ្វីប ។

២ – គាថាប្រាប់ឈ្មោះខែដែលព្រះសាស្តាចាប់បដិសន្ធិជាដើម

កក្កដេ គព្ភោ ច   សោណេ បុរនិក្ខមិ
ឱសភេ រាជសម្បត្តិ   សសេ បព្វជិតោ ជិនោ ។
កក្កដេ សព្វញ្ញុ ពុទ្ធោ   តត្ត ចក្កំ បវត្តយិ
និព្វានគមនំ សប្បេ   សហស្សំ បញ្ច មូសិកេ ។

៣ – គាថាប្រាប់ឈ្មោះថ្ងៃដែលព្រះសាស្តាចាប់បដិសន្ធិជាដើម

ឧក្កន្តោ ច គុរុវារស្មឹ   សុក្រវារេ ច និក្ខមិ
សម្ពុទ្ធោ ពុធវារស្មឹ   អង្គារេ បរិនិព្វុតោ ។

www.budinst.gov.kh www.elibraryofcambodia.org

៤ — គាថាប្រាប់ឈ្មោះខែដែលព្រះសាស្តាចាប់បដិសន្ធិជាដើម

អាសាឡ្ហបុណ្ណមោក្កន្តោ    វិសាខេ យេវ និក្ខមិ
វិសាខបុណ្ណមីសម្ពុទ្ធោ    វិសាខេ បរិនិព្វុតោ ។

ទាំងពាគាថានេះសេចក្តីប្រែមានក្នុងប្រស្នាលេខ ២៨៩ ហើយ ។

៥ — គាថាដែលពួកទេវតាទូលអារាធនាព្រះមហាបុរសឲ្យចុះមក ត្រាស់ជាព្រះពុទ្ធថា៖

កាលោយន្តេ មហាវីរ    ឧប្បជ្ជ មាតុកុច្ឆិយំ
សទេវកំ តារយន្តោ    ពុជ្ឈស្សុ អមតំ បទំ ។

"បពិត្រព្រះអង្គអ្នកមានព្យាយាមដ៏ច្រើន កាលនេះសមគួរដល់ព្រះអង្គ ហើយសូមព្រះអង្គឲ្យតចុះទៅកើតក្នុងគភ៌មាតុក្កោន ហើយសូមចម្លងសត្តនិករក្នុងមនុស្សលោកព្រមទាំងទេវលោក ឲ្យផុតចាកទុក្ខភ័យ៖ សូមព្រះអង្គឲ្យបានត្រាស់ដឹងនូវផ្លូវប្រតិបត្តិដែលដឹកនាំចូលកាន់ព្រះអមតមហានិព្វាន" ។

៦ — គាថាដែលព្រះមហាបុរសរមិលមើលនូវមហាវិលោកនៈ ទាំង ៥ ថា៖

កាលំ ទេសញ្ច ទីបញ្ច កុលំ មាតរមេវ ច

"ទ្រង់មើលនូវកាល១, ប្រទេស១, ទ្វីប១, ត្រកូល១, មាតា១" ។

www.budinst.gov.kh www.elibraryofcambodia.org

៧— គាថាចាតុរង្គមហាបធាន

កាមំ តចោ នហារូ ច អដ្ឋិ ច អវសិស្សតុ
ឧបសុស្សតុ មេ សរីរេ សព្វំ មំសលោហិតំ ។
យន្តំ បុរិសត្ថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ
ន តំ អបាបុណិត្វា វីរិយស្ស សណ្ឋានំ ភវិស្សតិ ។

«ស្បែក, សរសៃ, ឆ្អឹងចូរសល់នៅចុះ, សាច់និងឈាមក្នុងសរីរកាយរបស់យើងទាំងអស់ចូរស្ងួតទៅក៏ដោយ គុណវិសេសដ៏លើសឯណា ដែលជាវិស័យគួរដល់នឹងគប្បីបានដោយកំឡាំង និងសេចក្តីព្យាយាមប្រឹងប្រែងនៃបុរស កាលបើមិនសម្រេចគុណវិសេសនោះទេ យើងនឹងមិនលះបង់សេចក្តីព្យាយាមចោលចេញឡើយ» ។

៨— គាថាដែលមារាធិរាជពោលសរសើរព្រះសាស្តា

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
សទេវកស្មិំ លោកស្មិំ នត្ថិ តេ បដិបុគ្គលោ
តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនិ
តុវំ អនុសយេ ឆេត្វា តិណ្ណោ តារេសិមំ បជំ ។

«បពិត្រព្រះអង្គជាបុរិសអាជានេយ្យ ជាអ្នកឧត្តមបុរសក្នុងលោក

នេះ ខ្ញុំព្រះអង្គសូមថ្វាយវន្ទនាការជុលីព្រមដោយទ្វារទាំង ៣ គឺកាយ-វចី-មនោប្រណាមក្រោមបទ្មយុគលបាទ បុគ្គលក្នុងមនុស្សលោកព្រមទាំងទេវលោក នឹងប្រៀបផ្ទឹមឲ្យស្មើនឹងព្រះអង្គជាអ្នកប្រសើរមិនមានឡើយ ព្រះអង្គបានត្រាស់ជាព្រះស្រីសពេជ្ញស្រេចហើយប្រាប់ច្បាស់នូវចតុរារិយសច្ច ជាសាស្ដាចារ្យ មានព្រះតេជៈគ្របសង្កត់ឈ្នះពួកមារ ជាកំពូលអ្នកប្រាជ្ញ ឈ្លាសវៃក្នុងអនុស្ស័យនៃសត្វលោកទាំងអស់ នឹងចម្លងនូវវេនេយ្យនិករឲ្យផុតចាកចតុរោឃគន្ថារ ដាក់ដល់ត្រើយអមតមហានិព្វាន្ត ដ៏ក្សេមក្សាន្ត ប្រាសចាកសង្សារទុក្ខក្នុងគ្រានេះ ” ។

៩ — បឋមឧទានគាថាដែលព្រះពុទ្ធទាំងពួងមិនលះបង់ តែងទ្រង់បន្លឺក្នុងវេលាបានត្រាស់ដឹងថ្មីៗ ដើម្បីចំអកឲ្យតណ្ហាថា ៖

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

៖ កាលតថាគតមិនទាន់បានជួបប្រទះ (នូវពោធិញ្ញាណ) វង់វៃត

ស្វែងរកនូវជាងផ្ទះគឺតណ្ហា អ្នកធ្វើនូវផ្ទះគឺអត្តភាព ហើយអន្ទោលទៅអស់សង្សារមានជាតិមិនតែមួយ, ជាតិគឺកិរិយាកើតរឿយ ៗ រមែងនាំមកនូវសេចក្តីទុក្ខ, ម្នាលជាងផ្ទះគឺតណ្ហា (ឥឡូវនេះ) តថាគតបានឃើញអ្នកច្បាស់ហើយ, អ្នកនឹងធ្វើនូវផ្ទះគឺអត្តភាព (នេះ) ឲ្យតថាគតទៀតពុំបានឡើយ, ឆ្អឹងជំនីរគឺកិលេសទាំងអស់របស់អ្នក តថាគតបានបំបាក់ហោលហើយ, ទាំងកំពូលនៃផ្ទះគឺអវិជ្ជារបស់អ្នក តថាគតក៏បានកំចាត់បង់ហើយ; ចិត្តរបស់តថាគតបានដល់ហើយនូវព្រះនិព្វាន ដែលមានសង្ខារទៅប្រាសហើយ, តថាគតបានដល់ហើយនូវព្រះអរហត្តគឺការអស់ទៅនៃតណ្ហាទាំងឡាយ” ។

១០— គាថាសម្រាប់នមស្សការសត្តមហាឋានថា:

បឋមំ ពោធិបល្លង្កំ ទុតិយំ អនិមិសក្កំ
តតិយំ ចង្កមំ សេដ្ឋំ ចតុត្ថំ រតនឃរំ
បញ្ចមំ អជបាលញ្ច មុចលិន្ទេន ឆដ្ឋមំ
សត្តមំ រាជាយតនំ សព្វញ្ញុទ្ទេហិ សេវិតំ
ឯតេ សត្ត មហាឋានា ជម្ពុទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោ ។

“មហាឋាន (ទីដ៏ប្រសើរ) មាន ៧ កន្លែង ដែលព្រះពុទ្ធជាម្ចាស់

www.budinst.gov.kh www.elibraryofcambodia.org

គ្រប់ព្រះអង្គធ្លាប់សេពហើយ គឺទី ១ ពោធិបល្ល័ង្ក, ទី ២ អនិមិសចេ-
តិយ, ទី ៣ ទីចង្ក្រមដ៏ប្រសើរ, ទី ៤ ផ្ទះកែវ, ទី ៥ ដើមអជបា-
លនិគ្រោធ, ទី ៦ ស្រះមុចលិន្ទ, ទី ៧ ដើមកែះ ។ មហាឋានទាំង ៧ នេះ
តាំងនៅក្នុងជម្ពូទ្វីបដែលមនុស្សនឹងទេវតាទាំងឡាយ តែងធ្វើសក្ការបូជា
ខ្ញុំព្រះអង្គសូមថ្វាយបង្គំទីតាំង ៧ នោះអំពីចម្ងាយ" ។

១១- គាថាសម្រាប់នមស្សការសត្តុត្តរចេតិយ

កកុសន្ធោ ធមករកំ កោនាគមនោ កាយពន្ធំ
សាដកំ កស្សបោ ពុទ្ធោ គោតមោ អដ្ឋិ កេសធាតុយោ

"ព្រះពុទ្ធកកុសន្ធៈបញ្ចុះធមក្រក, ព្រះពុទ្ធកោនាគមនៈ បញ្ចុះវិត្ថព
ព្រះពុទ្ធកស្សបៈបញ្ចុះសាដក, ព្រះពុទ្ធគោតមបញ្ចុះកេសធាតុនិងសរីរៈ"

១២- គាថាដែលព្រះសាស្ដាទ្រង់ទទួលអារាធនាសហម្បតិព្រហ្ម
និងសំដែងធម៌ប្រោសសត្វថា:

អបារុតា តេ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ
វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។

www.budinst.gov.kh www.elibraryofcambodia.org

"ម្នាលសហាយព្រាហ្មណ៍! សត្វទាំងឡាយឯណា មានសោកបរិទេវ ក្រអឺរអ៊ី ស្លាប់ ហើយបញ្ចេញនូវសទ្ទាគឺសេចក្ដីយំ, ទ្វារទាំងឡាយនៃនគរឈ្មោះអមតៈ តថាគតបើករង់ចាំនូវសត្វទាំងឡាយនោះស្រេចហើយ; សត្វទាំងឡាយឯណា មានសញ្ញាគឺសេចក្ដីសំគាល់ថា ស្លាប់ គឺមិនជាការលំបាកគ្មានប្រយោជន៍ តថាគតក៏មិនសំដែងនូវធម៌ដ៏ស្ងាត់ខ្ពង់ ដល់សត្វទាំងឡាយនោះឡើយ" ។

## ១៣ - គាថាព្រះពុទ្ធកិច្ច ៥ ប្រការ

បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ
បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហនំ
បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ
ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោ ។

"ព្រះមុនីជាកំពូលអ្នកប្រាជ្ញទ្រង់ជំរះ គឺជាទ្រង់ប្រព្រឹត្តនូវពុទ្ធកិច្ចទាំង ៥ ប្រការ គឺ ១- ក្នុងវេលាព្រឹកទ្រង់យាងទៅបិណ្ឌបាត, ២- ក្នុងវេលារសៀលទ្រង់សំដែងធម៌ទេសនាដល់សាធារណជន, ៣- ក្នុងវេលាព្រលប់ទ្រង់ប្រទានឱវាទចំពោះពួកភិក្ខុ, ៤- ក្នុងវេលាកណ្ដាលអធ្រាត្រទ្រង់ដោះស្រាយប្រស្នានៃពួកទេវតា, ៥- ដល់វេលាបច្ចូសទ្រង់ប្រមើលមើលនូវសត្វដែលមានភព្វ និងអភព្វ" ។

www.budinst.gov.kh www.elibraryofcambodia.org

១៤ - គាថាពុទ្ធការកធម៌ ឬបារមី

ទានំ សីលញ្ច នេក្ខម្មំ បញ្ញាវិរិយេន បញ្ចមំ
ខន្តិ សច្ចមធិដ្ឋានំ មេត្តុបេក្ខាតិមេ ទស ។

"ធម៌ទាំង ១០ នេះគឺ ទាន ១, សីល ១, នេក្ខម្មៈ ១, បញ្ញា ១, វិរិយៈ ១, ខន្តិ ១, សច្ចៈ ១, អធិដ្ឋាន ១, មេត្តា ១, ឧបេក្ខា ១ (ហៅថាពុទ្ធការកធម៌ ឬបារមី)" ។

១៥ - គាថាធម្មសមោធាន

មនុស្សត្តំ លិង្គសម្បត្តិ ហេតុ សត្ថារទស្សនំ
បព្ពជ្ជា គុណសម្បត្តិ អធិការោ ច ឆន្ទតា
អដ្ឋ ធម្មសមោធានា អភិនីហារោ សមិជ្ឈតិ ។

"អភិនីហារ រមែងសម្រេចព្រោះការរួបរួមគុណធម៌ទាំង ៨ ប្រការ គឺ ភាពជាមនុស្ស ១, ដល់ព្រមដោយភេទ ១, ហេតុ ១, ជួបនឹងព្រះសាស្ដា ១, បព្ពជ្ជា ១, គុណសម្បត្តិ ១ អធិការ (ការធ្វើយ៉ាងក្រៃលែង) ១, សេចក្ដីពូលចិត្ត ១" ។

១៦ - គាថាសម្រាប់មនុស្សការព្រះពុទ្ធបាទ

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ
តិលោកកេតុំ តិភវេកនាថំ

www.budinst.gov.kh www.elibraryofcambodia.org

យោ លោកសេដ្ឋោ សកលំ កិលេសំ
ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

"ព្រះសព្វញ្ញុពុទ្ធអង្គឯណាវិសេសផុតត្រៃលោក កាត់ផ្តាច់កិលេសទាំងអស់ ញុំាំង ជនឲ្យត្រាស់ដឹងតាម ច្រើនឥតប្រមាណ ។ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះសព្វញ្ញុពុទ្ធអង្គនោះ ព្រះអង្គបានឆ្លងដល់ត្រើយនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក ព្រះអង្គជាទីពឹងរបស់សត្វក្នុងត្រៃភព" ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ
យំ សច្ចពន្ធគិរិកេ សុមនាចលគេ
យំ តត្ថ យោកបុរេ មុនិនោ ច បាទំ
តំ បាទលញ្ឆនមហំ សិរសា នមាមិ

"ខ្ញុំសូមក្រាបថ្វាយបង្គំនូវស្នាមព្រះបាទនៃព្រះមុនីនាថ ដែលព្រះអង្គទ្រង់ដាក់ទុកនៅផ្នុកខ្សាច់ទៀបឆ្នេរនៃស្ទឹងនម្មទា ១ កន្លែង, នៅភ្នំគិរីសច្ចពន្ធ ១ កន្លែង, នៅភ្នំសុមនកូដ ១ កន្លែង, នៅយោនកបុរី ១ កន្លែង (រួមជា ៤ កន្លែង)"

សុវណ្ណមាលិកេ សុវណ្ណបព្វតេ
សុមនកូដេ យោនកបុរេ

www.budinst.gov.kh www.elibraryofcambodia.org

នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ
អហំ វន្ទាមិ ទូរតោ ។

"ខ្ញុំសូមក្រាបថ្វាយបង្គំអំពីចម្ងាយ នូវឋានដែលមានព្រះបាទទាំង៥កន្លែង ដែលព្រះមុនីនាថទ្រង់ដាក់ទុកលើកំពូលភ្នំសុវណ្ណមាលិកៈ ១កន្លែង, លើភ្នំសុវណ្ណបព៌ត ១កន្លែង, លើភ្នំសុមនកូដ ១កន្លែង, នៅយោនកបុរី ១កន្លែង, នៅឆ្នេរស្ទឹងនម្មទា ១កន្លែង (រួមជា ៥កន្លែង)" ។

១៧- គាថាសម្រាប់នមស្ការព្រះធាតុចេតិយ

មហាគោតមសម្ពុទ្ធោ កុសិនារាយនិព្វុតោ
ធាតុវិត្ថារកំ កត្វា តេសុ តេសុ វិសេសតោ ។

"ខ្ញុំសូមក្រាបថ្វាយបង្គំចំពោះព្រះបរមសារីរិកធាតុ នៃព្រះមហាគោតមសម្ពុទ្ធ ដែលទ្រង់ចូលនិព្វាន ក្រោមដើមសាលព្រឹក្ស ជិតក្រុងកុសិនារា។ ការចែកចាយព្រះធាតុទៅក្នុងទីទាំងឡាយផ្សេងៗគ្នា ខ្ញុំសូមក្រាបថ្វាយបង្គំព្រះធាតុទាំងឡាយគ្រប់ទីនោះៗ" ។

ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច សត្ថុមា
អសម្ភិន្នា វតា សត្ត សេសា ភិន្នាវ ធាតុយោ ។

www.budinst.gov.kh www.elibraryofcambodia.org

"ព្រះសារីរិកធាតុទាំងនោះ ដែលនៅល្អសាតមិនបែកបាក់ប្រាំពីរព្រះអង្គគឺ ព្រះឧណ្ហីសធាតុ (ឆ្អឹងថ្ងាស) ១, ព្រះទាឋាធាតុ (ព្រះចង្កូម) ទាំងបួន,

ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ
ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ ។

"ព្រះទាឋាធាតុមួយអង្គប្រតិស្ឋានក្នុងត្រៃត្រឹង្សបុរី ព្រះទាឋាធាតុមួយអង្គប្រតិស្ឋានក្នុងពិភពនាគ ព្រះទាឋាធាតុមួយអង្គប្រតិស្ឋានក្នុងដែនគន្ធារៈ ព្រះទាឋាធាតុមួយអង្គប្រតិស្ឋានក្នុងសីហឡទ្វីប" ។

ឥមា ចតូសុ ឋានេសុ សត្ថុ ទាឋា បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

"ព្រះទាឋាធាតុទាំងឡាយឯណា ដែលព្រះសាស្តាទ្រង់ប្រតិស្ឋានក្នុងទីទាំង ៤ កន្លែងនោះឯង ខ្ញុំសូមក្រាបថ្វាយបង្គំចំពោះព្រះទាឋាធាតុទាំងនោះ ដែលមនុស្សនឹងទេវតាទាំងឡាយតែងធ្វើសក្ការបូជា" ។

ឧទ្ធំ ទក្ខិណទាឋា ច តាវតឹសេ បតិដ្ឋិតា
អធោ ទក្ខិណទាឋា ច សីហឡទីបេ បតិដ្ឋិតា
វាមទាឋា ច ឧទ្ធម្បិ គន្ធាររដ្ឋេ បតិដ្ឋិតា
វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ

"ព្រះទាឋាធាតុស្តាំខាងលើ ព្រះឥន្ទនាំទៅប្រតិស្ឋានក្នុងត្រៃត្រឹង្ស

www.budinst.gov.kh www.elibraryofcambodia.org

មានពណ៌ដូចកែវផ្លេក ព្រះធាតុខ្នាតតូចមានពណ៌ដូចផ្កាពកុល គឺពណ៌សស្រគាំ ៗ ខ្ញុំសូមក្រាបថ្វាយបង្គំចំពោះព្រះសារីរិកធាតុទាំងឡាយនោះ" ។

ឯកោ ថូបោ រាជគហេ ឯកោ វេសាលិយា អហុ
ឯកោ កបិលវត្ថុស្មិំ ឯកោ ច អលកប្បកេ
ឯកោ ច រាមគាមស្មិំ ឯកោច វេដ្ឋទីបកេ
ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ ។

"ព្រះស្តូបមួយតាំងនៅក្រុងរាជគ្រឹះ ព្រះស្តូបមួយតាំងនៅក្រុងកបិលពស្តុ ព្រះស្តូបមួយតាំងនៅក្រុងអលកប្បកៈ ព្រះស្តូបមួយតាំងនៅនារាមគ្រាម ព្រះស្តូបមួយតាំងនៅនាវេដ្ឋទីបកៈ ព្រះស្តូបមួយតាំងនៅក្រុងបាវេយ្យកៈ ព្រះស្តូបមួយតាំងនៅនាមល្លរដ្ឋ ព្រះស្តូបមួយតាំងនៅក្រុងកុសិនារា (រួមជា ៨ កន្លែង)" ។

ឯតេ សារីរិកា ថូបា ជម្ពូទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ

"ព្រះស្តូបទាំង ៨ កន្លែងនោះ ជាទីបញ្ចុះព្រះសារីរិកធាតុក្នុងជម្ពូទ្វីប ខ្ញុំសូមក្រាបថ្វាយបង្គំ ចំពោះព្រះសារីរិកធាតុទាំងនោះដែលមនុស្សនិងទេវតាទាំងឡាយតែងធ្វើសក្ការបូជា" ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអក្ខកធាតុ (ឆ្អឹងដង្កាំបិត) ទាំងពីរ (រួមជា៧ព្រះអង្គ) ព្រះសារីរិកធាតុក្រៅពីនេះ បែកចេញជាបំណែកតូចធំទាំងអស់" ។

មហន្តា បញ្ចនាឡិ ច មជ្ឈិមា ច ឆ នាឡិយោ
ខុទ្ទកា បញ្ចនាឡិ ច សម្ពិន្នា តិវិធា មតា ។

" ព្រះសារីរិកធាតុដែលបែកចេញជាបំណែកតូចធំ លោកពោលថា មាន ៣ យ៉ាងគឺ. ព្រះធាតុខ្នាតធំវាល់បានចំនួន៥នាឡិ, ព្រះធាតុខ្នាតកណ្តាលវាល់បានចំនួន ៦ នាឡិ, ព្រះធាតុខ្នាតតូចវាល់បាន ចំនួន ៥នាឡិ ( រួមជា ១៦ នាឡិ ) " ។

មហន្តា ភិន្នមុគ្គា ច មជ្ឈិមា ភិន្នតណ្ឌុលា
ខុទ្ទកា សាសបមត្តា ឯវំ ធាតុប្បមាណិកា ។

" ព្រះសារីរិកធាតុមានខ្នាតបីយ៉ាងគឺ ព្រះធាតុខ្នាតធំទំហំប៉ុនគ្រាប់សណ្តែកបាយដែលគេកាត់មួយកំណាត់ ; ព្រះធាតុខ្នាតកណ្តាលទំហំប៉ុនគ្រាប់អង្ករដែលគេកាត់មួយកំណាត់ , ព្រះធាតុខ្នាតតូចទំហំប៉ុនគ្រាប់ស្ពៃ" ។

មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិកប្បភា
ខុទ្ទកា ពកុលវណ្ណា តាបិ វន្ទាមិ ធាតុយោ

" ព្រះសារីរិកធាតុខ្នាតធំមានពណ៌ដូចមាស ព្រះធាតុខ្នាតកណ្តាល

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org